ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៩ លេខ ១ | ខែមីនា ២០១៥ | តម្លៃ ១.៥០០រ

# សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥៖ មានន័យដូចម្ដេច សម្រាប់សេដ្ឋកិច្ចកម្ពុជា និងពាណិជ្ជកម្ម?

## សេចក្ដីផ្ដើម

### សហគមន៍សេដ្ឋកិច្ចអាស៊ាន និង គោលការណ៍ប្រាំចំណុច នៃ សេរីភាវូបនីយកម្មសេដ្ឋកិច្ច

សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ជាសសរស្ដម្ភមួយ ក្នុងចំណោមសសរទាំងបីនៃសមាហរណកម្មអាស៊ាន។ AEC មានគោលដៅធ្វើឲ្យអាស៊ានក្លាយជាទីផ្សារ និងមូលដ្ឋានផលិតកម្មរួមគ្នាតែមួយ ដើម្បីជំរុញតំបន់នេះឲ្យមានលក្ខណៈប្រកួតប្រជែង សន្ទុះខ្លាំង និងធ្វើសមាហរណកម្មចូលគ្នា កាន់តែខ្លាំងឡើងនៅចុងឆ្នាំ២០១៥។ AEC ត្រូវធ្វើសេរីភាវូបនីយកម្មវិស័យសំខាន់ចំនួន ៥ សំដៅសម្រួលចលនាទំនិញ សេវាកម្ម មូលធន និងពលករជំនាញនៅក្នុងអាស៊ាន។




*វគ្គពិភាក្សាស្ដីពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ - បានត្រៀមរួចរាល់ ឬមិនទាន់រួចរាល់! សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ភ្នំពេញ ខែមីនា ឆ្នាំ២០១៥។*

- **លំហូរទំនិញដោយសេរី** ទាមទារនូវការលុបបំបាត់របាំងផ្នែកពន្ធគយ និងមិនមែនពន្ធគយ ដែលរារាំងពាណិជ្ជកម្មក្នុងតំបន់។ វាក៏គ្របដណ្ដប់លើវិធានការពាក់ព័ន្ធនឹងការសម្រួលពាណិជ្ជកម្ម ដូចជា ការធ្វើសុខដុមនីយកម្មពន្ធគយ និងការធ្វើឲ្យនីតិវិធីពន្ធគយមានលក្ខណៈកាន់តែសាមញ្ញ និងចុះសម្រុងគ្នា តាមរយៈច្រកចេញចូលអាស៊ានតែមួយ។ លំហូរទំនិញដោយសេរី វាជួយជំរុញសមាហរណកម្មទីផ្សារ និងកំណើនពាណិជ្ជកម្មក្នុងតំបន់អាស៊ាន។ អត្រាពន្ធគយមធ្យមក្នុងអាស៊ាន បានថយចុះពី ១៣% ក្នុងឆ្នាំ១៩៩៣ មកជិតដល់ 0% ក្នុងឆ្នាំ២០១៣ (KPMG 2014) ហើយវាបង្ហាញពីទំនាក់ទំនងវិជ្ជមាន ជាមួយកំណើន មួយជាបី នៃពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ពីឆ្នាំ២០០០ ដល់ ២០១៣ ដោយកើនដល់ ៦០៧ពាន់លានដុល្លារ (EIU 2014)។
- **លំហូរសេវាកម្មដោយសេរី** ទាមទារនូវការលុបបំបាត់ការដាក់កំហិតផ្សេងៗលើជំនួញសេវាកម្ម ដូចជា កម្មសិទ្ធិរបស់ជនបរទេស, លទ្ធភាពចូលទីផ្សារ និងលំហូរអ្នកផ្ដល់សេវា ជាដើម។ ប្រទេសសមាជិកអាស៊ាន បានកាត់បន្ថយកំហិតផ្សេងៗ ដែលរារាំងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនលើអនុវិស័យ យ៉ាងហោចណាស់ ៨០ ដែលឥឡូវនេះភាគច្រើនអនុញ្ញាតឲ្យជនបរទេស កាន់កាប់ភាគហ៊ុនច្រើនជាងប្រជាជន

---

អត្ថបទនេះ រៀបចំឡើងដោយ ហ៊ីង វុត្ថា អ្នកស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច និង Larry Strange ទីប្រឹក្សាជាន់ខ្ពស់ នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ Hing Vutha and Larry Strange. 2015. "ASEAN Economic Community 2015: What Does it Mean for Cambodia's Economy and for Business?"Cambodia Development Review 19(1): 1-5.។

## មាតិកា

សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥៖
មានន័យដូចម្ដេចសម្រាប់សេដ្ឋកិច្ចកម្ពុជា និងពាណិជ្ជកម្ម ...១
នយោបាយអេកូឡូស៊ី នៃទំនប់វារីអគ្គិសនីកំចាយ ....................៦
លំហូរកម្លាំងពលកម្មស្ត្រីនៅក្នុងមហាអនុតំបន់មេគង្គ ...........១២
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស .........................១៧
– ស្ថានភាពក្នុងប្រទេស...............................១៩
– សូចនាករ..........................................២១
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......................................២៨

ម្ចាស់ស្រុក។ វិស័យសេវាកម្មជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ចជាពិសេស លើធាតុចេញ និងការបង្កើតការងារ ហើយវិស័យនេះនឹងរីកចម្រើន ប្រសិនបើអាចកាត់បន្ថយរបាំងនានា។

- **លំហូរទុនវិនិយោគដោយសេរី** ផ្តល់នូវកិច្ចការពារកាន់តែប្រសើរឡើង សម្រាប់រាល់វិនិយោគិននៅក្នុងអាស៊ាន និងការធ្វើវិនិយោគរបស់ពួកគេ ក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត, ច្បាប់ និងបទបញ្ញត្តិវិនិយោគ, គោលនយោបាយ និងនីតិវិធីវិនិយោគ ដែលកាន់តែមានតម្លាភាព មានលក្ខណៈចុះសម្រុងគ្នា និងច្បាស់លាស់ទៀងទាត់, ព្រមទាំងការធ្វើសេរីភាវូបនីយកម្មរបបវិនិយោគជាបណ្តើរៗ។ អង្កេតឆ្នាំ២០១៣ មួយ ស្តីពី ភាពប្រកួតប្រជែងរបស់អាស៊ាន បង្ហាញថា វិនិយោគិននៅតែចាប់អារម្មណ៍ខ្លាំងនឹងតំបន់អាស៊ាន ហើយអាជីវករកាន់តែច្រើនឡើងមើលឃើញថា អាស៊ាន គឺជាតំបន់មួយ ដែលត្រូវយកមកគិតគូរនៅពេលធ្វើការសម្រេចចិត្តវិនិយោគ។ វិនិយោគផ្ទាល់ពីបរទេស (FDI) ក្នុងអាស៊ាន បានកើនឡើងជាហូរហែ ដោយមានកំណើនជាមធ្យម ១៤% ចាប់ពីឆ្នាំ២០០០ មក។ នៅឆ្នាំ២០០០ វិនិយោគផ្ទាល់ពីបរទេសប្រចាំឆ្នាំក្នុងអាស៊ាន មានត្រឹម ០,៩៣ពាន់លានដុល្លារ ប៉ុន្តែនៅឆ្នាំ២០១៣ បានកើនដល់ ២១,៣ពាន់លានដុល្លារ (EIU 2014)។
- **លំហូរមូលធនដោយសេរី** ជួយពង្រឹងសមាហរណកម្ម និងការអភិវឌ្ឍទីផ្សារមូលធនអាស៊ាន តាមរយៈការធ្វើសុខដុមនីយកម្មថែមទៀតលើស្តង់ដារទីផ្សារមូលធន, កិច្ចព្រមព្រៀង និងការទទួលស្គាល់ទៅវិញទៅមក លើផ្នែកគុណសម្បត្តិការអប់រំ និងបទពិសោធន៍របស់អ្នកមានជំនាញវិជ្ជាជីវៈផ្នែកទីផ្សារ, និងការកែលំអរចនាសម្ព័ន្ធពន្ធកាត់ទុក (ASEAN 2008)។ លំហូរមូលធនដោយសេរី ក៏ជំរុញឲ្យមានលំហូរមូលធនកាន់តែច្រើន តាមរយៈការលុបបំបាត់ ឬការបន្ថយការរឹតបន្តឹងលើលំហូរមូលធន និងប្រតិបត្តិការតាមគណនីចរន្តនាពេលបច្ចុប្បន្ន។ នៅពេលដែលទីផ្សារមូលធនផ្សារភ្ជាប់គ្នាកាន់តែខ្លាំងឡើង ក្រុមហ៊ុននឹងមានលទ្ធភាពទទួលបានសាច់ប្រាក់ងាយស្រួលច្រើនជាងមុន (KPMG 2014)។
- **លំហូរកម្លាំងពលកម្មជំនាញដោយសេរី** ជួយឲ្យអ្នកមានវិជ្ជាជីវៈ មានលំហូរច្រើនជាងមុនក្នុងអាស៊ាន។ "លំហូរដោយសេរី" មានន័យថា ជាលំហូរមានការគ្រប់គ្រងដោយបទបញ្ញត្តិក្នុងតំបន់ ដោយផ្អែកលើច្បាប់ និងបទបញ្ញត្តិក្នុងប្រទេស។ សកម្មភាពអនុវត្តកិច្ចព្រមព្រៀងនេះ រួមមានការជួយសម្រួលការចេញទិដ្ឋាការ និងលិខិតអនុញ្ញាតការងារ សម្រាប់អ្នកមានជំនាញវិជ្ជាជីវៈមកពីប្រទេសអាស៊ាន, ការពង្រឹងសហប្រតិបត្តិការក្នុងបណ្តាញសាកលវិទ្យាល័យអាស៊ាន, និងការអភិវឌ្ឍសមត្ថភាព និងគុណសម្បត្តិសំខាន់ៗ សម្រាប់ការងារ/មុខរបរ និងជំនាញបណ្តុះបណ្តាល។ កិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមក (MRA) ផ្តល់នូវយន្តការចម្បងៗសម្រាប់ត្រួតពិនិត្យលំហូរកម្លាំងពលកម្មជំនាញក្នុងអាស៊ាន។ បច្ចុប្បន្ន អាស៊ាន សម្រេចបាន ៨ MRA ស្តីពី សេវាវិស្វកម្ម, សេវាគិលានុបដ្ឋាន, ស្ថាបត្យកម្ម, ការពិនិត្យវាស់វែងដី, ការប្រកបរបរផ្នែកវេជ្ជសាស្ត្រ, ការប្រកបរបរផ្នែកទន្តសាស្ត្រ, ការប្រកបរបរផ្នែកគណនេយ្យ, និងជំនាញផ្នែកទេសចរណ៍។ ព័ត៌មានលំអិតខ្លះៗនៃកិច្ចព្រមព្រៀងទាំងនេះ កំពុងតែចងក្រងឡើង ហើយនឹងត្រូវអនុវត្តក្រោយឆ្នាំ២០១៥។
- **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs)** ស្របគ្នានឹង AEC អាស៊ានបានបង្កើត បណ្តាញកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទូលំទូលាយទ្វេភាគី និងពហុភាគី ជាមួយប្រទេសមានសេដ្ឋកិច្ចធំៗបំផុតលើពិភពលោក រួមមាន ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និង ញូហ្សីលែន ហើយក៏ក្លាយជាមជ្ឈមណ្ឌល FTA មួយនៅអាស៊ីក្នុងការពិតជាក់ស្តែង។ ដោយអាចរក្សាបាននូវសារៈសំខាន់ស្នូល រចនាសម្ព័ន្ធ និង FTA នានា បង្កើតបានជាក្របខ័ណ្ឌផ្នែកគោលនយោបាយ និងច្បាប់ សម្រាប់ពាណិជ្ជកម្ម និងការធ្វើវិនិយោគជាមួយ និងនៅក្នុងអាស៊ាន (KPMG 2014)។

## សហគមន៍សេដ្ឋកិច្ចអាស៊ានបានលូតលាស់យឺតៗ ប៉ុន្តែកំពុងឈានទៅមុខហើយ

ប្រព័ន្ធដាក់ពិន្ទុរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Scorecard) ដែលវាស់វែងលទ្ធផលសម្រេចបានតាមប្រទេសជាសមាជិកនីមួយៗ ធៀបនឹងការតម្រូវសំខាន់ៗរបស់ AEC នោះ បង្ហាញថា ក្នុងការអនុវត្ត AEC អាស៊ានបានជឿនលឿនទៅមុខច្រើន ប៉ុន្តែមិនបានស្មើគ្នាល្អទេ។ នៅត្រឹមចុងឆ្នាំ២០១៣ អាស៊ានបំពេញបានស្រេចបាច់ ២២១វិធានការ (៧៩,៧%) ក្នុងចំណោម ២៧៧វិធានការ។ ការលូតលាស់ធំបំផុត សម្រេចបានក្នុងផ្នែកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ដែលជាសសរស្តម្ភទី៣ នៃ AEC។ ការជឿនលឿនក្នុងផ្នែកផ្សេងទៀតនៃ AEC មិនសូវបានច្រើនទេ ដោយមានអត្រាអនុវត្តបាន ៨១% សម្រាប់សមាសភាគទីផ្សារតែមួយ និងមូលដ្ឋានផលិតកម្ម (សសរស្តម្ភទី១), ៧៧% ដូចគ្នា សម្រាប់សមាសភាគតំបន់សេដ្ឋកិច្ចប្រកបដោយភាពប្រកួតប្រជែងខ្ពស់ (សសរស្តម្ភទី២) និងសមាសភាគធ្វើសមាហរណកម្មទៅក្នុង សេដ្ឋកិច្ចសាកល (សសរស្តម្ភទី៤)។

ទោះបីប្រព័ន្ធដាក់ពិន្ទុ បានបង្ហាញលទ្ធផលបែបនេះក៏ដោយ ក៏នៅមានការខ្វែងមតិគ្នាក្នុង ការវាយតម្លៃពីការជឿនលឿនទៅមុខនៃ AEC។ មានមតិរិះគន់ថា ដំណើរការអាស៊ានឈានទៅសម្រេច AEC ឆ្នាំ២០១៥ វា "យឺតពេក" ដោយមានការរីកចម្រើនតិចតួចក្នុងបញ្ហាចម្បងៗមួយចំនួន។ វិស័យដែលមានបញ្ហានានា រួមមានការប្រើរបាំងមិនមែនពន្ធគយ ដូចជា នីតិវិធីគយស្មុគស្មាញ (Austria 2013), ការដាក់កំហិតលើសិទ្ធិកាន់កាប់ភាគហ៊ុនបរទេស និងកម្មសិទ្ធិដី, ឧបសគ្គរាំងស្ទះលំហូរកម្លាំងពលកម្ម ឬអ្នកមានជំនាញវិជ្ជាជីវៈ ឆ្លងកាត់ព្រំដែន (Das et al. 2013) និងកង្វះសុខដុមនីយកម្ម និងស្តង់ដារូបនីយកម្មនៃនីតិវិធីពន្ធគយ។ ការដាក់កំហិតលើកម្មសិទ្ធិ និងវិនិយោគបរទេស នៅតែជាឧបសគ្គធំបំផុត ចំពោះពាណិជ្ជកម្ម (Woetzel et al. 2014)។

អ្នកមានគំនិតសុទិដ្ឋិនិយម យល់ថា ការជឿនលឿនទៅមុខនៃ AEC ជាជំហានចម្បងមួយ ឆ្ពោះទៅកាន់ការធ្វើសមាហរណកម្ម

ក្នុងតំបន់កាន់តែធំទូលាយ និងស៊ីជម្រៅ។ ទោះបីមានការយល់ដឹងមិនបានស្មើគ្នាពី AEC និងផលពាក់ព័ន្ធរបស់វា សម្រាប់អាជីវកម្មក៏ដោយ ក៏វិនិយោគិនធំៗ និងថ្នាក់ដឹកនាំអាជីវកម្មភាគច្រើន មានទស្សនៈវិជ្ជមានចំពោះជោគជ័យ និងទិសដៅនៃ AEC និងមានក្រុមហ៊ុនកាន់តែច្រើន បានជឿតាមចក្ខុវិស័យរបស់អាស៊ាន (KPMG 2014; ECN 2013)។ ក្រុមហ៊ុននៅក្នុងអង្កេតបានប្រាប់ថា គោលនយោបាយសមាហរណកម្មអាស៊ានចាប់ផ្ដើមមានសារៈសំខាន់សម្រាប់ពួកគេហើយ។ លោក Pushpanathan Sundram នាយកគ្រប់គ្រងក្រុមហ៊ុន EAS Strategic Advice និយាយថា "ការផ្លាស់ប្ដូរមានល្បឿនយឺត ហើយជួនកាលវាយឺតគួរឲ្យខកចិត្តណាស់ ប៉ុន្តែអ្វីដែលសំខាន់គឺទិសដៅនៃការផ្លាស់ប្ដូរ" (ECN 2013, 11)។

លទ្ធផលនៃប្រព័ន្ធដាក់ពិន្ទុបង្ហាញថា កម្ពុជាអនុវត្តបានល្អក្នុងការបំពេញការតម្រូវសំខាន់ៗ ដោយឈរនៅលំដាប់ទី៣ នៅពីក្រោយសិង្ហបុរី និងម៉ាឡេស៊ី។ សរុបមកលទ្ធផលអនុវត្តរបស់កម្ពុជា បានលើសពីកម្រិតមធ្យម ក្នុងការបំពេញតាមសូចនាករផ្សេងៗ ដែលត្រូវនាំទៅដល់ការអនុវត្តបានពេញលេញតាមការតម្រូវរបស់ AEC លើកលែងតែការអនុវត្តសូចនាករនីតិវិធីផ្នែកពន្ធដារ និងពន្ធគយ ដែលជាផ្នែកមួយរដ្ឋាភិបាលត្រូវមានការប្ដេជ្ញាចិត្តមុតមាំដើម្បីធ្វើកំណែទម្រង់។

## សហគមន៍សេដ្ឋកិច្ចអាស៊ានផ្ដល់ឱកាសសម្រាប់ការធ្វើអាជីវកម្ម

ក្រុមហ៊ុនភាគច្រើន នៅក្នុងអង្កេតសម្រាប់ការសិក្សារបស់ ECN (2013) និង Wong and Wirjo (2013) យល់ឃើញថា AEC គឺជាឱកាស ច្រើនជាង ការគំរាមកំហែង ហើយក្រុមហ៊ុនអាចបានចំណេញពីសេដ្ឋកិច្ចបើកចំហ និងធ្វើសមាហរណកម្មចូលគ្នាកាន់តែខ្លាំងនៅក្នុងអាស៊ាន និងការតភ្ជាប់កាន់តែប្រសើរជាមួយទីផ្សារ និងបណ្ដាញផលិតកម្មពិភពលោក។ អាស៊ានកាន់តែទាក់ទាញចំណាប់អារម្មណ៍វិនិយោគិនទាំងខាងក្នុង និងខាងក្រៅតំបន់ច្រើនហើយ ដោយសារមានដំណើររឿងជោគជ័យជាច្រើន។ ជោគជ័យទី១ គឺកំណើនសេដ្ឋកិច្ចយ៉ាងលឿន និងជាប់លាប់របស់អាស៊ាន។ ពីឆ្នាំ១៩៩៩ ដល់ ២០១២ តំបន់អាស៊ាន មានអត្រាកំណើនពិតប្រចាំឆ្នាំជាមធ្យម ៥,៥% នាំឲ្យផសស (GDP) សរុបគ្នា កើនឡើង មួយជាពីរ រហូតជិតដល់ ៣ពាន់ពាន់លានដុល្លារ (KPMG 2014)។ ទន្ទឹមគ្នានឹងការរីកចម្រើនយ៉ាងលឿននៃសេដ្ឋកិច្ចក្នុងតំបន់ អាស៊ាន ក៏មានប្រជាជនយ៉ាងច្រើន (៦១៧លាននាក់) និងកំណើនចំនួន និងឥទ្ធិពលនៃគ្រួសារថ្នាក់កណ្ដាលដែរ។ គេព្យាករណ៍ថា ចំនួនគ្រួសារថ្នាក់កណ្ដាលនៅក្នុងអាស៊ាន ត្រូវកើនឡើងពី ៤០លានគ្រួសារ ក្នុងឆ្នាំ២០១០ ដល់ ៨៥លានគ្រួសារក្នុងឆ្នាំ២០១៧ ហើយនឹងបង្កើនកម្លាំងចំណាយប្រើប្រាស់ (ECN 2013)។ ទី២ អាស៊ានបានសម្រេចជោគជ័យ ក្នុងការប្រែក្លាយខ្លួនទៅជាមជ្ឈមណ្ឌលផលិតកម្មដ៏សស់រវើកមួយនៅលើពិភពលោក។ ឥឡូវនេះ អាស៊ានមានឱកាសកាន់តែធំឡើង ដើម្បីកសាងខ្លួនឲ្យក្លាយទៅជាមជ្ឈមណ្ឌលផលិតកម្មកាន់តែធំឡើងទៀត ដោយសារមានកម្លាំងពលកម្មមានតម្លៃទាប និងកំណើនតម្លៃពលកម្មនៅប្រទេសចិន។ លើសពីនេះទៀត AEC អាចកាត់បន្ថយចំណាយផលិតកម្ម និងលើកកម្ពស់ប្រសិទ្ធភាពផលិតកម្ម តាមរយៈការពង្រឹងសេដ្ឋកិច្ចមាត្រដ្ឋាន និងជំនាញឯកទេសសម្រាប់ក្រុមហ៊ុនផលិតកម្មនានា (ECN 2013)។ ក្រុមហ៊ុនមកពីសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ចិន កូរ៉េខាងត្បូង ជប៉ុន និងអូស្ត្រាលី កំពុងស្វែងរកប្រសិទ្ធភាពផ្នែកផលិតកម្ម និងចំណាយ ដូច្នេះហើយ អាស៊ានក៏ក្លាយជាតំបន់ទាក់ទាញមួយសម្រាប់ការធ្វើវិនិយោគ។

AEC មានអត្ថប្រយោជន៍ច្រើនសម្រាប់កម្ពុជា។ ដោយញុំាងឲ្យមានកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់អាស៊ីកាន់តែធំទូលាយ ជាពិសេស ជាមួយប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង អាស៊ាន នឹងជំរុញតំណភ្ជាប់ផ្នែករូបវន្ត, បង្កើនលទ្ធភាពប្រើប្រាស់ទីផ្សារ ធនធាន និងវិនិយោគក្នុងតំបន់, បង្កើនការចូលរួមក្នុងបណ្ដាញផលិតកម្មក្នុងតំបន់, ពន្លឿនកំណែទម្រង់ដ៏ចាំបាច់នានានៅក្នុងស្រុក និងកែលំអបរិយាកាសធ្វើអាជីវកម្ម និងវិនិយោគ។ កត្តាទាំងអស់នេះ ចូលរួមចំណែកជួយពន្លឿនកំណើនផលិតភាព ការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច (Hing and Strange 2014)។ AEC រំពឹងថានឹងជួយឲ្យ ផសស ពិតរបស់កម្ពុជាកើនបាន ៤,៤ ឯកតាភាគរយ ការនាំចេញកើន ៥,៣ ឯកតាភាគរយ និងវិនិយោគឯកជនកើន ២៤,៨ ឯកតាភាគរយ (Itakura 2013)។ ទោះយ៉ាងនេះក្ដី មូលធនមនុស្ស និងកម្រិតអប់រំនៅកម្ពុជា ដើរក្រោយប្រទេសភាគច្រើននៅក្នុងតំបន់។ ជាលទ្ធផល នៅក្នុងទីផ្សារពលកម្មបច្ចុប្បន្ន ឃើញមានកង្វះខាតជំនាញ និងភាពមិនស៊ីគ្នាផ្នែកជំនាញយ៉ាងធ្ងន់ធ្ងរ។ ក្នុងរយៈពេលខ្លី កម្ពុជាអាចទទួលបានប្រយោជន៍ពី AEC តាមរយៈលំហូរដោយសេរីជាងមុននៃកម្លាំងពលកម្មមានជំនាញ ពីប្រទេសសមាជិកអាស៊ានផ្សេងទៀត ដើម្បីបំពេញកង្វះខាតជំនាញក្នុងពេលនេះ។ ប៉ុន្តែក្នុងរយៈពេលវែង កម្ពុជាត្រូវកសាងកម្លាំងពលកម្មឲ្យមានជំនាញ និងការអប់រំកាន់តែប្រសើរ ប្រសិនបើចង់ក្លាយជាប្រទេសមានជោគជ័យក្នុងការប្រកួតប្រជែងនៅក្នុង AEC និងតំបន់ក្រៅពីនេះទៀត (Madhur 2014)។

កម្ពុជា បានអនុវត្តរួចហើយនូវកំណែទម្រង់សំខាន់ៗមួយចំនួន ដើម្បីកែលំអបរិយាកាសសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងការត្រៀមខ្លួនសម្រាប់ AEC និងសមាហរណកម្មក្នុងតំបន់កាន់តែធំទូលាយ។ កម្ពុជាសព្វថ្ងៃ មានផ្ដល់គ្រឿងលើកទឹកចិត្តជាច្រើនផ្នែកវិនិយោគ ជាពិសេស កម្មសិទ្ធិលើភាគហ៊ុន ១០០% ការមិនដាក់កំហិត លើការផ្ញើប្រាក់ចំណេញត្រឡប់ទៅប្រទេសដើមវិញ អត្រាពន្ធទាបលើប្រាក់ចំណេញក្រុមហ៊ុន និងការលើកលែងពន្ធផ្សេងៗ។ ប៉ុន្តែនៅមានសកម្មភាពត្រូវអនុវត្តជាច្រើនទៀត ដើម្បីបង្កើតនូវបរិយាកាសធ្វើវិនិយោគមានស្ថិរភាព និងកាន់តែទាក់ទាញខ្លាំងឡើងដល់វិនិយោគិន។ បរិយាកាសវិនិយោគបច្ចុប្បន្ននេះ គួបផ្សំនឹងអត្ថប្រយោជន៍បន្ថែមនៃ AEC ផ្ដល់នូវលក្ខខណ្ឌវិជ្ជមានសម្រាប់ការធ្វើវិនិយោគ និងកំណើន។ គ្រាន់តែក្នុងមួយឆ្នាំកន្លងទៅនេះ កម្ពុជាសម្រេចបានកំណើនវិនិយោគផ្ទាល់ពីបរទេសគួរឲ្យកត់សម្គាល់ ហើយក្រុមហ៊ុនល្បីៗរបស់សហរដ្ឋអាមេរិក ដូចជា Domino's Pizza, Kohler Faucets និង Home

Top (សិទ្ធិប្រើឈ្មោះពាណិជ្ជកម្មជាផ្លូវការរបស់ក្រុមហ៊ុន Do It Best នៅកម្ពុជា) បានចូលមកក្នុងទីផ្សារកម្ពុជា (Todd 2015)។

ការប្រមើលឃើញនូវ ទីផ្សារ និងបណ្តាញផលិតកម្មធ្វើសមាហរណកម្មចូលគ្នាក្នុងតំបន់អាស៊ាន បានផ្តល់ឲ្យកម្ពុជានូវឱកាសផ្នែកវិនិយោគ និងពាណិជ្ជកម្មយ៉ាងច្រើន សម្រាប់ជំរុញការអភិវឌ្ឍវិស័យឯកជន និងវិបុលភាព (Hing 2013)។ កម្ពុជាមិនទាន់បានចូលរួមជាដុំកំភួនទេ នៅក្នុងបណ្តាញបែងចែកផលិតកម្មក្នុងតំបន់ ប៉ុន្តែការប្តូរទិសថ្មីមួយនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ជាសកលរបស់តំបន់អាស៊ី បានផ្តល់នូវឱកាសថ្មីមួយសម្រាប់ប្រទេសសេដ្ឋកិច្ចកំពុងផុសឡើងនៅអាស៊ីអាគ្នេយ៍ ដូចជា ប្រទេសកម្ពុជា។ ដោយសារការកើនឡើងនៃបន្ទុកចំណាយផលិតកម្មសហគ្រាសជាច្រើន កំពុងផ្លាស់ប្តូរទីតាំងផលិតកម្មរបស់ខ្លួនចេញពីប្រទេសចិន ទៅកាន់ប្រទេសដទៃទៀតដែលមានបន្ទុកចំណាយទាបជាង។ និន្នាការនេះ អាចមើលឃើញច្បាស់តាមការធ្វើវិនិយោគរបស់សហគ្រាសជប៉ុនពីរ គឺ Minebea ដែលជាសហគ្រាសឈានមុខលំដាប់ពិភពលោក ក្នុងការផលិតម៉ាស៊ីនខ្នាតមីក្រូ និង Sumitomo Electric ដែលជាផលិតករឈានមុខមួយខាងផ្នែកបណ្តាញខ្សែភ្លើង ដោយពួកគេបានបង្កើតគ្រឹះស្ថានផលិតកម្មទំនើបបំផុតនៅកម្ពុជា ដើម្បីផ្គត់ផ្គង់ទីផ្សារពិភពលោក។

## កំណែទម្រង់ ការបង្ហាញរូបភាពថ្មី និងការកំណត់យុទ្ធសាស្ត្រប្រទេសកម្ពុជា ដើម្បីទាញយកប្រយោជន៍ជាអតិបរមាពី AEC និងសមាហរណកម្មក្នុងតំបន់ដ៏ធំទូលាយ

កម្ពុជាមិនទាន់ទាញយកបានអត្ថប្រយោជន៍ពី AEC ទេ ដូចអាចមើលឃើញតាម បរិមាណតិចនៃពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសអាស៊ានដទៃទៀត និងការចូលរួមតិចនៅក្នុងបណ្តាញបែងចែកផលិតកម្មក្នុងតំបន់។ ប្រសិនបើចង់បានអត្ថប្រយោជន៍ជាអតិបរមាពី AEC និងសមាហរណកម្មក្នុងតំបន់ដ៏ធំទូលំទូលាយ ព្រមទាំងចង់បានតម្លៃបន្ថែមច្រើនទៀតសម្រាប់អាជីវកម្មនោះ ប្រទេសកម្ពុជាត្រូវតែធ្វើកំណែទម្រង់ថែមទៀតដូចខាងក្រោម៖

- **កែលំអបរិយាកាសវិនិយោគ៖** ទោះបីមានការរីកចម្រើនគួរឲ្យកត់សំគាល់ក្នុងផ្នែក ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាព័ត៌មាន, និងការសម្រួលពាណិជ្ជកម្មក៏ដោយ ក៏បរិយាកាសវិនិយោគនៅកម្ពុជា នៅតែមានលក្ខណៈទាក់ទាញ តិចជាងប្រទេសភាគច្រើននៅក្នុងអាស៊ាន ដោយមានចំណាត់ថ្នាក់ទាបនៅក្នុងការវាយតម្លៃផ្នែកសេដ្ឋកិច្ច និងអាជីវកម្ម។ ដើម្បីក្លាយជាទីតាំងដែលក្រុមហ៊ុនពហុជាតិនានាគេចង់ជ្រើសយកនោះ៖ កម្ពុជាត្រូវបង្កើនភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម, បង្កើតគ្រឿងលើកទឹកចិត្តត្រឹមត្រូវសម្រាប់អាជីវកម្ម និងធ្វើកិច្ចការជាច្រើនទៀត។ អាទិភាពផ្សេងៗទៀត ក្នុងការដោះស្រាយភាពខ្សោយផ្នែកបរិយាកាសវិនិយោគនេះ រួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធ, ការរៀបចំនីតិវិធីគយឲ្យមានលក្ខណៈរលូនគ្នា, ការបង្កើនប្រសិទ្ធភាពផ្នែកឡូជីស្ទិក, និងការធ្វើវិនិយោគលើមូលធនមនុស្ស។ ការពង្រីកតំបន់សេដ្ឋកិច្ចពិសេស តាមការកែលំអហេដ្ឋារចនាសម្ព័ន្ធ, ការដោះស្រាយបញ្ហាការិយាធិបតេយ្យ និងការលំបាកផ្នែករដ្ឋបាល, ការបង្កើតទំនាក់ទំនងផ្តល់/ទទួលការងារឲ្យអាចបត់បែនបានច្រើនជាងមុន, និងការធានាលទ្ធភាពរកបានទាំងកម្លាំងពលកម្មមានជំនាញទាប និងជំនាញខ្ពស់ៗ ក៏ជាកត្តាជំរុញវិនិយោគដែរ។
- **កែលំអផ្នែកឡូជីស្ទិក និងធ្វើឲ្យសាមញ្ញនីតិវិធីគយ៖** កម្ពុជាស្ថិតក្នុងចំណោមប្រទេសអាស៊ាន ដែលមានសេវាផ្នែកឡូជីស្ទិកមានប្រសិទ្ធភាពទាបបំផុត ដោយសារហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងមានគុណភាពអន់ ព្រមទាំងកង្វះប្រសិទ្ធភាព នៃនីតិវិធីជម្រះពន្ធគយដោយមន្ត្រីគយ និងទីភ្នាក់ងារត្រួតពិនិត្យនៅតាមព្រំដែន។ អន្តរាគមន៍ខាងគោលនយោបាយ អាចមានតាំងពីការកែលំអហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងពាណិជ្ជកម្ម រហូតដល់ការគ្រប់គ្រងឲ្យបានកាន់តែប្រសើរនៅព្រំដែន តាមការកែទម្រង់ និងធ្វើទំនើបកម្មបែបបទគយ និងការចែករំលែកព័ត៌មានឲ្យបានកាន់តែទូលំទូលាយ, ការប្រកួតប្រជែងកាន់តែខ្លាំងក្នុងសេវាដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស, និង លទ្ធភាពទទួលបានដោយងាយនូវព័ត៌មាន ស្តីពី កិច្ចព្រមព្រៀងដឹកទំនិញឆ្លងកាត់ប្រទេស។
- **វិនិយោគលើមូលធនមនុស្ស៖** ផលសម្រេចក្នុងការអប់រំកម្លាំងពលកម្ម និងការកសាងមូលធនមនុស្សនៅកម្ពុជា នៅដើរយឺតជាងប្រទេសភាគច្រើនក្នុងតំបន់ ហើយបង្កឧបសគ្គចម្បងមួយ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច។ កម្ពុជាត្រូវធ្វើវិនិយោគច្រើនណាស់លើការបង្កើនកម្រិតជំនាញ និងការអភិវឌ្ឍមូលធនមនុស្ស។ ការលើកកម្ពស់ប្រព័ន្ធអប់រំ គួរជាចំណុចផ្តោតចម្បងគេ នៅក្នុងគោលនយោបាយ ពីព្រោះការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ផ្តល់ឲ្យពួកយុវជននូវជំនាញជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ ហើយការអប់រំកម្រិតឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជួយកសាងសមត្ថភាពជាបន្តទៀត។ ដើម្បីមានសមត្ថភាពប្រកួតប្រជែង ហើយអាចផ្តល់ឱកាសការងារល្អៗបាន កម្ពុជាត្រូវការចាំបាច់នូវយុវជនជំនាន់ក្រោយដែលមានជំនាញខ្ពស់ ជាពិសេសខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។
- **លើកកម្ពស់ការចូលរួម និងការពិគ្រោះយោបល់ផ្នែកអាជីវកម្ម៖** សម្រាប់ផ្នែកអាជីវកម្ម ទោះបីកម្ពុជាមានយន្តការថ្នាក់ជាតិសម្រាប់ការពិគ្រោះយោបល់ រវាងរដ្ឋាភិបាល នឹងវិស័យឯកជនក៏ដោយ ក៏ការចូលរួមរបស់វិស័យឯកជននៅក្នុងដំណើរការអាស៊ាន មានលក្ខណៈមិនស្មើគ្នាទេ ហើយនៅខ្វះខាតការយល់ដឹងពីអត្ថប្រយោជន៍ និងឱកាសផ្សេងៗផុសចេញពី កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងសមាហរណកម្មក្នុងតំបន់ទៀតផង (Chan and Strange 2012)។ ម្យ៉ាងទៀត វិធាន បទបញ្ញត្តិ និងនីតិវិធីដ៏ស្មុគស្មាញនានា បានក្លាយជាបន្ទុកមួយ និងបង្កការភ័ន្តច្រឡំក្នុងចំណោមសហគ្រាស

អាជីវកម្ម។ អាស៊ាន និងរដ្ឋាភិបាលកម្ពុជា គួរពង្រឹងដំណើរការផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់ជាមួយផ្នែកអាជីវកម្មស្ដីពីគំនិតផ្ដួចផ្ដើមនានារបស់ AEC។ ក្រុមប្រឹក្សាអាជីវកម្មអាស៊ាន បានផ្ដល់យោបល់ថា គួរមានកិច្ចប្រឹងប្រែងច្រើនថែមទៀត ក្នុងការផ្ដល់ព័ត៌មានទៅដល់សហគ្រាសខ្នាតតូច និងមធ្យមក្នុងតំបន់ ដើម្បីកាត់បន្ថយក្ដីបារម្ភថា AEC គឺជាការគម្រាមកំហែងដល់អាជីវកម្មរបស់ពួកគេ ព្រមទាំងដាស់ស្មារតីអំពីឱកាសនានាដែល AEC អាចផ្ដល់ឲ្យ។

- **បង្កើត និងអនុវត្តគោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម៖** សេដ្ឋកិច្ចកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ផ្អែកលើវិស័យកសិកម្ម ផលិតកម្មសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ ប៉ុន្តែមានសញ្ញាគួរឲ្យសង្ឃឹមច្រើននៃការធ្វើពិពិធកម្ម ទៅកាន់សហគ្រាសឧស្សាហកម្មធុនស្រាល និងកសិអាជីវកម្ម។ ប្រសិនបើចង់ចាប់យកឱកាស និងដោះស្រាយបញ្ហាប្រឈមផុសចេញពី AEC ឆ្នាំ២០១៥ នោះកម្ពុជាត្រូវបង្កើត និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មថ្នាក់ជាតិមួយ ដែលជំរុញផលិតភាព និងពិពិធកម្មឧស្សាហកម្ម, ការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកឡូជីស្ទិក, ការអភិវឌ្ឍកម្លាំងពលកម្មជំនាញបំពេញតាមតម្រូវការទីផ្សារពលកម្ម, ការពង្រឹងស្ថាប័ន និងការបង្កើតបរិយាកាសអាជីវកម្មអំណោយផល ទាំងសម្រាប់ការធ្វើវិនិយោគក្នុងស្រុក និងអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជានឹងដាក់ចេញ ឲ្យអនុវត្តគោលនយោបាយនេះក្នុងពេលឆាប់ៗខាងមុខ ប៉ុន្តែការអនុវត្តគោលនយោបាយនេះ ត្រូវមានការដឹកនាំ និងការប្ដេជ្ញាចិត្តខ្លាំងក្លាពីសំណាក់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍, សហគមន៍អាជីវកម្ម, និងស្ថាប័នអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ព្រមទាំងការសម្របសម្រួល និងសហប្រតិបត្តិការល្អប្រសើរជាងមុនរវាងក្រសួង និងស្ថាប័ននានា។
- **"បង្ហាញរូបភាពថ្មីកាន់តែប្រសើរឡើង" នៃប្រទេសកម្ពុជាចំពោះ AEC និងហួសពីនោះទៀត៖** រាជរដ្ឋាភិបាលកម្ពុជា និងផ្នែកអាជីវកម្ម បានយល់ស្របគ្នាថា កម្ពុជាត្រូវបង្ហាញរូបភាពថ្មីរបស់ខ្លួន ដោយងាកចេញពីពាក្យអវិជ្ជមានកាលពីមុន ដូចជា "ប្រទេសទើបបញ្ចប់ទំនាស់, ប្រទេសលូតលាស់តិចជាងគេ និងពឹងផ្អែកលើជំនួយ" ជាដើម ទៅនិទានពីដំណើររឿងវិជ្ជមាន និងមានការថ្លឹងថ្លែងល្អជាងនេះ ទាំងក្នុងខ្លឹមសារ និងចំណាប់អារម្មណ៍ អំពីសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់ ដែលកម្ពុជាសម្រេចបានក្នុងពីរទសវត្សរ៍កន្លងទៅពោលគឺ ជាប្រទេសមានសន្តិភាព ស្ថិរភាព និងសេដ្ឋកិច្ចបើកទូលាយបំផុតមួយនៅលើពិភពលោក មានកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់យូរឆ្នាំ និងសម្រាប់គ្រប់គ្នា (ស្ថិតក្នុង "ក្រុមកំណើនគួរឲ្យស្ញប់ស្ញែង" តាមការវាយតម្លៃឆ្នាំ២០១៤ របស់ធនាគារពិភពលោក), មានការកាត់បន្ថយភាពក្រីក្រគួរឲ្យកត់សំគាល់, មានកំណែទម្រង់ធំទូលាយ ក្នុងវិស័យសំខាន់ៗដែលជះឥទ្ធិពលទៅលើបរិយាកាសអាជីវកម្ម, និងមានប្រជាជនវ័យក្មេងដែលមានសក្ដានុពលខ្លាំងក្លា ដើម្បីក្លាយជាកម្លាំងពលកម្មជំនាញសម្រាប់ ការធ្វើពិពិធកម្ម និងកំណើនផលិតភាពឧស្សាហកម្ម, ព្រមទាំងមានការប្ដេជ្ញាចិត្តរឹងមាំក្នុងការដើរតួនាទីកាន់តែសកម្ម និងមានសារៈប្រយោជន៍នៅក្នុងអាស៊ាន, តំបន់អាស៊ី និងតំបន់ដទៃទៀត។

## ឯកសារយោង


ASEAN, Association of South East Asian Nations. 2008. *ASEAN Economic Community Blueprint*. Jakarta: ASEAN.

ASEAN. 2012. *ASEAN Economic Community Scorecard: Charting Progress toward Regional Economic Integration; Phase I (2008-2009) and Phase II (2010-2011)*. Jakarta: ASEAN Secretariat.

Austria, S. Myrna. 2013. “Non-Tariff Barriers: A Challenge to Achieving the ASEAN Economic Community.” In *The ASEAN Economic Community: A Work in Progress*, edited by Sanchita Basu Das, Jayant Menon, Rodolfo Severino and Omkar Lal Shrestha, 31-94. Singapore: Asian Development Bank/Institute of Southeast Asian Studies.

Chan Sophal and Larry Strange. 2012. “Achieving the AEC 2015: Challenges for Cambodia and Its Businesses.” In *Achieving the ASEAN Economic Community 2015: Challenges for Member Countries and Businesses*, edited by Sanchita Basu Das, 37-52. Singapore: Institute of Southeast Asian Studies.

Das, Sanchita Basu, Jayant Menon, Rodolfo Severino and Omkar Lal Shrestha. 2013. *The ASEAN Economic Community: A Work in Progress*. Singapore: Asian Development Bank/Institute of Southeast Asian Studies.

ECN, Economist Corporate Network. 2013. *Riding the ASEAN Elephant: How Business is Responding to an Unusual Animal*. Economist Corporate Network.

EIU, Economist Intelligence Unit. 2014. *Asia Re-drawing the ASEAN map: How Companies are Crafting New Strategies in South-east Asia*. Economist Intelligence Unit.

Hing Vutha. 2013. *Leveraging Trade for Economic Growth in Cambodia*. Working paper Series No.81. Phnom Penh: CDRI.

Hing Vutha and Larry Strange. 2014. “Cambodia and Its Region—Challenges and Choices.” *Annual Development Review 2013-14*, 9-25. Phnom Penh: CDRI.


*តទៅទំព័រ ១១ ...*

# នយោបាយអេកូឡូស៊ី នៃទំនប់វារីអគ្គិសនីកំចាយ

## សេចក្តីផ្តើម

នយោបាយអេកូឡូស៊ី (Political ecology) មាននិយមន័យផ្សេងៗគ្នាជាច្រើន ទៅតាមអ្នកសិក្សាលើបរិបទខុសៗគ្នានៃប្រព័ន្ធអេកូឡូស៊ី (Robbins 2012)។ ក្នុងន័យងាយយល់ នយោបាយអេកូឡូស៊ី ជាការសិក្សាពីទំនាក់ទំនងរវាងកត្តានយោបាយ កត្តាសេដ្ឋកិច្ចនិងកត្តាសង្គម ជាមួយនឹងបញ្ហានិងការប្រែប្រួលបរិស្ថាន (https://en.wikipedia.org/?title=Political_ecology)។

កម្ពុជា ត្រូវផលិតជាបន្ទាន់នូវថាមពលអគ្គិសនី ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងបំពេញកង្វះខាតថាមពលនៅក្នុងប្រទេស។ អាត្រាគ្របដណ្តប់សរុបនៃបណ្តាញចែកចាយអគ្គិសនី មានត្រឹមតែ ៤២,៧២% ឬ ៣,១៦លានគ្រួសារប៉ុណ្ណោះដែលបានតភ្ជាប់នឹងបណ្តាញចែកចាយអគ្គិសនីរបស់ជាតិ (EAC 2014)។ អត្រាគ្របដណ្តប់នៃបណ្តាញចែកចាយអគ្គិសនីនៅជនបទ នៅទាបជាខ្លាំងជាងអត្រាមធ្យមសម្រាប់ទូទាំងប្រទេស។ សមត្ថភាពផលិតអគ្គិសនីក្នុងស្រុកក្នុងឆ្នាំ២០១៣ មានត្រឹមតែ ១៧៧០លានគីឡូវ៉ាត់/ម៉ោង (GWh) ក្នុងនេះ ប្រមាណ ៤៣% បានពីរោងចក្រប្រើម៉ាស៊ូត ធ្យូងថ្ម និងជីវម៉ាស់ ហើយ ៥៧% បានពីទំនប់វារីអគ្គិសនី (EAC 2014)។ ការនាំចូលអគ្គិសនីមកពីប្រទេសជិតខាងមានដល់ ២២៨២ GWh ក្នុងនោះ ៤៤% មកពីប្រទេសថៃ, ២៥% មកពីវៀតណាម និង ១% មកពីឡាវ (EAC 2014)។ តម្លៃអគ្គិសនីនៅកម្ពុជា ស្ថិតក្នុងចំណោមកម្រិតខ្ពស់បំផុតនៅតំបន់អាស៊ាន។ តម្លៃអគ្គិសនីក្នុងស្រុកឆ្នាំ២០១១ ស្ថិតក្នុងចន្លោះពី ៨,៥៤ ទៅ ១៥,៨៥សេនដុល្លារក្នុងមួយគីឡូវ៉ាត់/ម៉ោង (ASEAN Centre for Energy 2011)។

ដោយសារប្រទេសកម្ពុជា មានស្ថានភាពដីអំណោយផលច្រើន (ជ្រលងភ្នំ, អូរមានទឹកហូរលឿន, និងទន្លេមានទឹកហូរខ្លាំង) និងមានទុនវិនិយោគពីបរទេស (ភាគច្រើនរបស់ក្រុមហ៊ុនចិន) ទៅលើហេដ្ឋារចនាសម្ព័ន្ធថាមពល រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍវារីអគ្គិសនី ដោយរំពឹងថាកំណើនការផ្គត់ផ្គង់អគ្គិសនី នឹងជួយបញ្ចុះ និងរក្សាស្ថិរភាពថ្លៃអគ្គិសនីនាពេលអនាគត។ ក្រសួងរ៉ែ និងថាមពល (MME) និងគណៈកម្មការទន្លេមេគង្គ (MRC) បានប៉ាន់ប្រមាណថា ថាមពលវារីអគ្គិសនី ដែលអាចទាញយកបានតាមលទ្ធភាពបច្ចេកទេសនៅកម្ពុជា មានប្រមាណ ១០.០០០មេហ្គាវ៉ាត់ (MW) ក្នុងនេះ ១០% កំពុងតែសាងសង់ កាលពីឆ្នាំ២០១១ និងមានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា សម្រាប់ ២២០០មេហ្គាវ៉ាត់ថែមទៀត (Gätke and Un 2013)។

ទំនប់ធំៗជានិច្ចជាកាលមានចោទបញ្ហាច្រើន ដែលជាទូទៅទាក់ទងនឹងផលប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងចីរភាពនៃបរិស្ថាន (Siciliano et al. ជិតចេញផ្សាយ)។ ផលប៉ះពាល់ចម្បងៗខាងផ្នែកជីវសាស្ត្រ មានជាអាទិ៍ ការប្រែប្រួលប្រភេទត្រីនៅក្នុងស្ទឹងទន្លេ ការស្ទះផ្លូវត្រីដែលត្រូវផ្លាស់ទីទៅកាន់កន្លែងរកចំណី, និងកន្លែងពងកូន, ការស្ទះលំហូរដីល្បាប់និងសារធាតុចិញ្ចឹម, ការជន់លិចដីកសិកម្ម និងបាត់បង់សត្វនិងរុក្ខជាតិនៅលើដី។ ការប្រែប្រួលស្ថានភាពស្ទឹងទន្លេ, ការប្រើប្រាស់ដី, លំហូរទឹក, និងគុណភាពទឹក ដូចជា កំណើនជាតិប្រៃនៅតំបន់ខ្សែទឹកខាងក្រោមក្បែរឆ្នេរសមុទ្រ, គឺជាផលប៉ះពាល់ផ្នែករូបវន្ត។ ការតម្រូវឲ្យប្រជាជនទៅរស់នៅកន្លែងមួយទៀត, ការបាត់បង់ធនធានធម្មជាតិ, ការដាក់កម្រិត ឬការហាមឃាត់លើការប្រើប្រាស់ធនធាន, ការប្រែប្រួលជីវភាពរស់នៅ និងរបៀបធ្វើកសិកម្ម, និង ទឹកទន្លេដែលមិនសមស្របសម្រាប់ប្រើប្រាស់ក្នុងផ្ទះនិងកសិកម្ម, គឺជាផលប៉ះពាល់មួយចំនួនទៅលើសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ផលប៉ះពាល់ផ្នែកជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គមកិច្ចនៃទំនប់វារីអគ្គិសនីធំៗ មិនអាចជៀសផុតទេ។ ប៉ុន្តែទំហំនៃផលប៉ះពាល់អវិជ្ជមាន គឺអាស្រ័យទៅលើទំហំនៃទំនប់ និងអាងស្តុកទឹក។ ដោយសារគម្រោងអាចមានចំណាយលើសផែនការ និងការយឺតយ៉ាវនោះ ទំនប់ទាំងអស់មិនមែនសុទ្ធតែបានចំណេញខាងសេដ្ឋកិច្ចនោះទេ (Ansar et al. 2014 and Sovaool et al. 2014 cited in Siciliano et al. forthcoming)។

ការអភិវឌ្ឍវិស័យថាមពល ពិសេសវារីអគ្គិសនី គឺជាកិច្ចការថ្មីសម្រាប់កម្ពុជា ហើយគម្រោងសាងសង់ធំៗទាមទារទុនវិនិយោគ និងជំនួយពីបរទេស។ ក្នុងពេលដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ កំពុងផ្តោតចិត្តទៅលើផលប្រយោជន៍បានពីការផលិតថាមពលវារីអគ្គិសនីនោះ អ្នកកសាងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត នៅមានការយល់ដឹងតិចនៅឡើយពីហានិភ័យផ្សេងៗទាក់ទងនឹងការសាងសង់ទំនប់។ ដូច្នេះហើយ នៅមានការយកចិត្តទុកដាក់តិចតួចណាស់ទៅលើ ផលប៉ះពាល់នៃការអភិវឌ្ឍទំនប់វារីអគ្គិសនី និងវិធីសាស្ត្រកាត់បន្ថយហានិភ័យ។

អត្ថបទនេះផ្អែកលើ ការសិក្សាធំមួយ[1] ដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរពី របៀបរបបនៃអភិបាលកិច្ចនៅទំនប់វារីអគ្គិសនីកំចាយ និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថាន ដោយផ្តោតខ្លាំងទៅលើការប្រែប្រួលក្នុងជីវភាពរស់នៅរបស់ប្រជាជននៅជុំវិញទំនប់វារីអគ្គសនីនោះ។

## ករណីសិក្សាលើទំនប់វារីអគ្គិសនីកំចាយ

ទំនប់វារីអគ្គិសនីកំចាយ មានកម្លាំងសរុប ១៩៤មេហ្គាវ៉ាត់ និងសាងសង់ឡើងដោយ ក្រុមហ៊ុនចិនមួយឈ្មោះ Sinohydro។

អត្ថបទនេះ រៀបចំឡើងដោយ គឹម សួ ជាអ្នកស្រាវជ្រាវ ផ្នែកបរិស្ថាន នៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Kim Sour. 2015. “Political Ecology of Kamchay Hydropower Dam.” *Cambodia Development Review* 19(1): 6-11។

១ គម្រោងស្រាវជ្រាវ "China Goes Global" ផ្តល់មូលនិធិដោយ ក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ច និងសង្គម (ESRC), ប្រទេសអង់គ្លេស (UK), គ្រោងចប់រួចរាល់នៅចុងឆ្នាំ២០១៥ ។

រូបភាព១៖ ទំនប់វារីអគ្គិសនីកំចាយ នៅខេត្តកំពត



ទំនប់នេះធំជាងគេបង្អស់នៅកម្ពុជា នៅមុនពេលទំនប់ស្ទឹងឫស្សីជ្រុំក្រោម ដែលមានកម្លាំងដល់ ៣៣៨មេហ្គាវ៉ាត់ បានចាប់ដំណើរការកាលពីខែមករា ២០១៥។ បច្ចុប្បន្នគេមិនទាន់ដឹងច្បាស់ទេពីផលប៉ះពាល់ នៃទំនប់វារីអគ្គិសនីកំចាយ ប៉ុន្តែការបែងចែកបន្ទុកចំណាយ និងផលចំណេញផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថាន រវាងតួអង្គនៅតាមកម្រិតផ្សេងៗ ពិតជាមិនបានស្មើគ្នាល្អឡើយ។ ការកសាងទំនប់វារីអគ្គិសនីនេះ ជាតេស្តមួយបញ្ជាក់ពីសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា និងដោះស្រាយបញ្ហាមិនស្មើភាពគ្នារវាងអ្នកទទួលបានផលប្រយោជន៍ និងអ្នកត្រូវខាតបង់ ហើយក៏ជួយផ្តល់នូវបទពិសោធន៍សំខាន់ៗជាច្រើន សម្រាប់គម្រោងទំនប់វារីអគ្គិសនីនាពេលអនាគត។

ការសាងសង់ និងកិច្ចដំណើរការទំនប់វារីអគ្គិសនីកំចាយ បានជះឥទ្ធិពលជាខ្លាំងទៅលើបរិស្ថាន ហើយបានប៉ះពាល់ដល់ធនធានធម្មជាតិ និងអ្នកប្រើប្រាស់ធនធាននៅក្នុងមូលដ្ឋាន។ បញ្ហានេះ ត្រូវមានការស្វែងយល់ឲ្យបានប្រសើរថែមទៀតពីផលប៉ះពាល់នៃការកសាងទំនប់ ដែលអាចចូលរួមចំណែកដល់ការកំណត់គោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

ការស្រាវជ្រាវមានគោលដៅចម្បង ដើម្បីស្វែងយល់អំពី (១) ផលប៉ះពាល់នៃទំនប់ទៅលើសង្គម សេដ្ឋកិច្ចក្នុងមូលដ្ឋាន និងបរិស្ថាន, និង (២) របៀបរបបអភិបាលកិច្ច និងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងទំនប់វារីអគ្គិសនី។ ដើម្បីសម្រេចការងារនេះ មានការសិក្សាលើសំណួរស្រាវជ្រាវសំខាន់ៗ ២ គឺ៖

- តើទំនប់វារីអគ្គិសនីកំចាយ មានផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលអ្វីខ្លះទៅលើ សង្គម សេដ្ឋកិច្ច និងបរិស្ថាន នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ?
- តើមានរបៀបរបបអភិបាលកិច្ចអ្វីខ្លះ ទាក់ទងនឹងការអភិវឌ្ឍ និងកិច្ចដំណើរការទំនប់វារីអគ្គិសនីកំចាយ?

## វិធីសាស្ត្រ

### *ក្របខ័ណ្ឌទ្រឹស្តី*

នយោបាយអេកូឡូស៊ី ដើរតួនាទីជាក្របខ័ណ្ឌវិភាគ សម្រាប់កំណត់នូវផលប៉ះពាល់ផ្នែកនយោបាយ និងសេដ្ឋកិច្ចសង្គមកិច្ចនៃទំនប់វារីអគ្គិសនីកំចាយ ដែលបង្កនូវការប្រែប្រួលបរិស្ថាន។ អ្នកស្រាវជ្រាវផ្សេងទៀតបានប្រើក្របខ័ណ្ឌស្រដៀងគ្នាដើម្បីសិក្សាអំពីទំនាស់លើលទ្ធភាពបានប្រើប្រាស់ និងត្រួតត្រាលើធម្មជាតិ ដូចជា ទឹក និងថាមពល ជាដើម (Wolf 1972; Greenberg and Park 1994)។ ចំណុចសំខាន់ក្នុងក្របខ័ណ្ឌនេះ គឺ អន្តរកម្មដ៏ស្មុគស្មាញរវាងតួអង្គនៅតាមកម្រិតផ្សេងៗ (Tan-Mullins 2007)៖ ការវាយតម្លៃពីទំនាក់ទំនងដោយមានអំណាចមិនស្មើគ្នារវាងតួអង្គនានា ដែលជួយពន្យល់ពីការបែងចែកមិនស្មើគ្នានូវសិទ្ធិបានប្រើប្រាស់ និងត្រួតត្រាលើធនធានបរិស្ថាន។

លក្ខណៈជាប់ទាក់ទងដល់ច្រើនវិស័យ (interdisciplinary nature) នៃនយោបាយអេកូឡូស៊ី មានន័យថា មានការសង្កត់ធ្ងន់ខុសគ្នា នៅក្នុងនិយមន័យរបស់វា។ ដោយឡែកការសន្មត់៣យ៉ាង របស់ Bryant and Bailey (1997, 27-28) បានក្លាយជាមូលដ្ឋានគ្រឹះនៃការអនុវត្តនយោបាយអេកូឡូស៊ី នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

រូបភាព ២៖ ស្ថាប័នចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើទំនប់វារីអគ្គិសនីកំចាយ




**បញ្ជីពាក្យកាត់**

| | |
|---|---|
| 3SPN | បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (3S Rivers Protection Network) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AFD | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AgenceFrançaise de Développement) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (The Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CEPA | សមាគមអភិរក្សវប្បធម៌ និងបរិស្ថាន (Culture and Environment Preservation Association) |
| CI | អង្គការអភិរក្សអន្តរជាតិ (Conservation International) |
| DOE | នាយកដ្ឋានថាមពល (Department of Energy) |
| DOH | នាយកកដ្ឋានវារីអគ្គិសនី |
| EAC | អាជ្ញាធរអគ្គិសនីកម្ពុជា (Electricity Authority Cambodia) |
| EcoAC | សមាគមសេដ្ឋកិច្ចកម្ពុជា (Economic Association of Cambodia) |
| EDC | អគ្គិសនីកម្ពុជា (Elictricitte Du Cambodge) |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) |
| EU | សហគមន៍អឺរ៉ុប (European Union) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម ពិភពលោក (Food and Agriculture Organization) |
| IRN | បណ្តាញទន្លេអន្តរជាតិ (International Rivers Network) |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (Institute of Technology of Cambodia) |
| IUCN | សម្ព័ន្ធភាពអន្តរជាតិសម្រាប់អភិរក្សធម្មជាតិ (International Union for Conservation of Nature) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន (Japan International Cooperation Agency) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MB | អង្គការម្លប់បៃតង (MlupBaitong Organization) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance) |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (Ministry of Industry, Mines and Energy) |
| MOE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MOI | ក្រសួងមហាផ្ទៃ (Ministry of Interior) |
| MOP | ក្រសួងផែនការ (Ministry of Planning) |
| MOT | ក្រសួងទេសចរណ៍ (Ministry of Tourism) |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resources and Meteorology) |
| MRC | គណៈកម្មការទន្លេមេគង្គ (Mekong River Commission) |
| NA | រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា (The National Assembly of The Kingdom of Cambodia) |
| NGO Forum | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (Non-Governmental Organization Forum on Cambodia) |
| OXFAM | គណៈកម្មការរបស់អុកស្វ៊តសម្រាប់ជួយដោះភាពអត់ឃ្លាន (Oxford Committee for Famine Relief) |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម (Royal University of Agriculture) |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (Royal University of Phnom Penh) |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (United Nations Development Programme) |
| WA | សម្ព័ន្ធភាពសត្វព្រៃ (Wildlife Alliance) |
| WB | ធនាគារពិភពលោក (World Bank) |
| WCS | សង្គមអភិរក្សសត្វព្រៃ (Wildlife Conservation Society) |
| WWF | មូលនិធិសត្វព្រៃពិភពលោក (World Wildlife Fund) |

- ទី១ រាល់ផលចំណាយ និងអត្ថប្រយោជន៍ ដែលទាក់ទងនឹងការប្រែប្រួលបរិស្ថាន មានការបែងចែកមិនស្មើភាពគ្នាទេ។
- ទី២ ការបែងចែកមិនស្មើភាពគ្នានេះ បានបង្កើនឡើង ឬកាត់បន្ថយវិសមភាពខាងសង្គមកិច្ចសេដ្ឋកិច្ចដែលមានស្រាប់។
- ទី៣ ការបែងចែកមិនស្មើភាពគ្នានូវរាល់ផលចំណាយ និងអត្ថប្រយោជន៍ និងការបង្កើន ឬកាត់បន្ថយវិសមភាពដែលមានស្រាប់នោះ បាននាំឲ្យមានផលពាក់ព័ន្ធផ្នែកនយោបាយ ក្នុងន័យការប្រែប្រួលលើទំនាក់ទំនងអំណាច។

## ការចុះស្រាវជ្រាវដល់កន្លែង

ការសិក្សានេះ បានប្រើវិធីសាស្ត្របែបគុណភាព និងពិនិត្យលើច្រើនវិស័យ និងផ្អែកលើទិន្នន័យបឋម និងទិន្នន័យប្រភពទី២ ដែលប្រមូលបានពីការស្រាវជ្រាវឯកសារ និងការសិក្សាពីទំនប់វារីអគ្គិសនីកំចាយ និងទំនប់ផ្សេងៗទៀតនៅកម្ពុជា, សេចក្ដីណែនាំ និងគោលនយោបាយនៅអន្តរជាតិ លើការអភិវឌ្ឍទំនប់វារីអគ្គិសនី, និងគោលនយោបាយ និងច្បាប់ជាតិលើសន្តិសុខថាមពល ការសាងសង់ និងកិច្ចដំណើរការទំនប់វារីអគ្គសនី។

ទិន្នន័យបឋម ប្រមូលបានពីការធ្វើសម្ភាសន៍ពាក់កណ្ដាលរៀបរយ (SSIs) និងការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយនឹងតំណាងស្ថាប័ននានានៅរាជធានីនៅភ្នំពេញ និងប្រជាជនមូលដ្ឋាននៅតាមសហគមន៍រងផលប៉ះពាល់ ក្នុងតំបន់ទំនប់វារីអគ្គិសនី នៅខេត្តកំពត។ វិធីជ្រើសរើសដោយមានគោលដៅ និងតាមការស្គាល់គ្នា (purposive and snowball sampling) ត្រូវបានប្រើប្រាស់ ដើម្បីជ្រើសរើសភូមិចំនួន ៥ ធ្វើជាតំបន់សិក្សា និងដើម្បីជ្រើសរើសអ្នកចូលរួមក្នុង FGDs និង SSIs ផងដែរ។ SSIs ចំនួន ៤ និង FGDs ចំនួន ២ មានធ្វើឡើងក្នុងភូមិនីមួយៗ គឺ សរុបមកបាន ២០ SSIs និង ១០ FGDs ។ SSIs ចំនួន ២០ ទៀត ត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងមន្ត្រីរដ្ឋាភិបាល អ្នកតំណាង NGOs និងសង្គមស៊ីវិល និងអ្នកសិក្សាស្រាវជ្រាវ។

## ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ មានពីរបែប ដែលត្រូវប្រើកម្មវិធីកុំព្យូទ័រខុសគ្នា។ មុនពេលចាប់ផ្ដើមចុះសិក្សាដល់កន្លែង មានធ្វើការវិភាគមួយ ដើម្បីកំណត់អ្នកពាក់ព័ន្ធ ទំនាក់ទំនងជាផ្លូវការរវាងពួកគេ និងជាពិសេស សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចចិត្តរបស់ពួកគេ។ ជំហានដំបូង គឺការកំណត់អ្នកពាក់ព័ន្ធទាំងអស់ តាមរយៈការពិភាក្សាបំផុសគំនិត រួចធ្វើចំណាត់ថ្នាក់តាមទស្សនៈ ការចូលរួម និងផលប្រយោជន៍របស់ពួកគេ។ ជំហានបន្ទាប់ទៀតគឺ ការកសាងជាផែនទី ដើម្បីកំណត់ និងបង្ហាញជារូបភាពនូវទំនាក់ទំនងដ៏ស្មុគស្មាញ រវាងអ្នកពាក់ព័ន្ធទាំងនោះ (រូបភាព ២) ដោយត្រូវប្រើកម្មវិធីកុំព្យូទ័រ Visualizer។ ការចងក្រងជាផែនទី អនុញ្ញាតឲ្យអ្នកស្រាវជ្រាវកំណត់បានថា អ្នកពាក់ព័ន្ធណាមួយមានប្រយោជន៍សម្រាប់ការធ្វើសម្ភាសន៍។

ការថតសម្លេងក្នុង SSIs និង FGDs ត្រូវបានយកមកកត់ត្រាជាភាសាខ្មែរ និងបកប្រែជាភាសាអង់គ្លេស។ ក្រោយពីបានពិនិត្យឲ្យស៊ីគ្នាហើយ (consistency) ឯកសារទាំងនេះ គេបែងចែកជា ៣ក្រុមតូចៗ៖ ការធ្វើសម្ភាសន៍ជាមួយសមាជិកសហគមន៍ ការធ្វើសម្ភាសន៍ជាមួយតំណាងស្ថាប័ន និងការពិភាក្សាតាមក្រុមស្នូល។ ព័ត៌មានប្រមូលបាន គេដាក់លេខកូដ និងផ្ដុំវាជាកញ្ចុំតាមប្រធានបទផ្សេងៗដែលផុសចេញពីការវិភាគ។ លំហាត់នេះ អនុវត្តឡើងដោយប្រើកម្មវិធី Nvivo។

## លទ្ធផលរកឃើញ

លទ្ធផលបង្ហាញឲ្យឃើញ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថាន នៃការអភិវឌ្ឍវារីអគ្គិសនីនៅតំបន់ជុំវិញទំនប់វារីអគ្គិសនីកំចាយ ជាពិសេសចំពោះប្រជាជនមានជីវភាពពឹងផ្អែកលើធនធានធម្មជាតិ។ ជាក់ស្ដែង អាជីវករនៅរមណីយដ្ឋានទឹកឈូរ និងអ្នកប្រមូលឫស្សី បានរាយការណ៍ពីជីវភាពលំបាកខ្លាំងជាងនៅមុនពេលមានទំនប់វារីអគ្គិសនី។

## ផលប៉ះពាល់លើសហគមន៍មូលដ្ឋាន និងបរិស្ថាន

ទំនប់វារីអគ្គិសនី បានកាត់បន្ថយលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិរបស់ប្រជាជនមូលដ្ឋាន។ ព្រៃក្រាស់ក្នុងឧទ្យានជាតិភ្នំបូកគោ ដែលពីមុនជាតំបន់គ្រប់គ្រងដោយរដ្ឋ ឥឡូវនេះគឺជាកម្មសិទ្ធិឯកជនរបស់ក្រុមហ៊ុន Sinohydro។ មានព្រៃឫស្សីមួយដុំធំត្រូវលិចទឹកជាអចិន្ត្រៃយ៍ ដោយសារអាងស្ដុកទឹក។ ដូច្នេះ អ្នកប្រមូលឫស្សី ក៏លែងបានចូលដល់ព្រៃឫស្សីភ្លាមៗ ហើយត្រូវទៅឆ្ងាយពីនោះទៀត។ ស្ត្រីម្នាក់នៅភូមិអូរតូច ប្រាប់ថា "មុនពេលសាងសង់ទំនប់ ពួកយើងមានជីវភាពគ្រាន់បើ។ ឥឡូវនេះ តំបន់ឫស្សីត្រូវលិចទឹកអស់ ការប្រមូលឫស្សីលំបាកជាងមុន ព្រោះត្រូវប្រើក្បូន។ ជីវភាពពួកយើង លំបាកជាងមុនពេលមានសំណង់ទំនប់ទឹក។" ច្រកចូលទៅព្រៃឫស្សី ជួនកាលមានទឹកលិច និងមានការរាយការណ៍ជារឿយៗ ពីការហាមឃាត់ប្រជាជនមូលដ្ឋានមិនឲ្យចូលព្រៃឫស្សី។

ការពិភាក្សាតាមក្រុមស្នូលបង្ហាញថា ជីវភាពរបស់អ្នកប្រមូលឫស្សីបានធ្លាក់ចុះជាង ៥០% ហើយជួនកាលរហូតដល់ ១០០% នៅពេលមានការហាមឃាត់មិនឲ្យចូលព្រៃឫស្សី។ ប្រជាជនជាច្រើនគ្មានដីធ្លីទេ ឬមានដីតូច ដូច្នេះត្រូវទិញអង្ករហូប។ អ្នកខ្លះបានខ្ចីលុយពីស្ថាប័នមីក្រូឥណទាន ដើម្បីទិញស្បៀងអាហារ ហើយខ្លះទៀតបានខ្ចីប្រាក់ទៅទិញទូក ដើម្បីអាចទៅដល់កន្លែងមានឫស្សី។

ប្រាក់ចំណូលរបស់អ្នកលក់ផ្លែឈើ នៅរមណីដ្ឋានទឹកឈូរបានធ្លាក់ចុះ ដោយសារភ្ញៀវទេសចរមានចំនួនតិចជាងមុន ចាប់តាំងពីជម្រៅទឹក និងលំហូរទឹកធ្លាក់បានថយចុះ ជាពិសេសនៅក្នុងរដូវប្រាំង។ នៅមានសេចក្ដីរាយការណ៍បន្ថែមទៀតថាភ្ញៀវទេសចរខ្លះបានលង់ទឹកស្លាប់ នៅពេលមានការបើកបង្ហូរទឹកភ្លាមៗចេញពីអាង៖ ការបើកទឹកនេះមិនទៀងទាត់ និងគ្មានការជូនដំណឹងជាមុនទេ។ ស្ត្រីម្នាក់នៅភូមិស្ទឹងប្រាំពីរ បានបកស្រាយថា "យើងមិនអាចលក់ដូរបានច្រើនដូចមុនទេ ពីព្រោះមានទឹកហូរតិចពេកសម្រាប់ឲ្យភ្ញៀវទេសចរមកលេង។ សូម្បីនៅថ្ងៃឈប់សម្រាកបុណ្យជាតិ ក៏ក្រុមហ៊ុនចិនមិនបានបង្ហូរទឹកចេញដែរ។

ដូច្នេះ ភ្ញៀវទេសចរមកលេងទីនេះ មានចំនួនកាន់តែតិចទៅ តាំងពីមានការសាងសង់ទំនប់មក។"

ប្រជាជនមូលដ្ឋានរំពឹងថា នឹងទទួលបានអគ្គិសនីដោយឥតគិតថ្លៃ ឬមានតម្លៃទាប ប៉ុន្តែការពិតវាផ្ទុយគ្នាស្រឡះ។ ធ្ងន់ធ្ងរជាងនេះ អ្នកភូមិខ្លះដែលរស់នៅក្បែរទំនប់ មិនទាន់បានភ្ជាប់ទៅនឹងបណ្ដាញអគ្គិសនីទេ។ បុរសម្នាក់នៅភូមិមាត់ពាម បានឮថា ប្រជាជនដែលរងផលប៉ះពាល់ដោយសារទំនប់ នឹងបានប្រើប្រាស់អគ្គិសនីដោយឥតគិតថ្លៃ។ ស្ត្រីអ្នកភូមិម្នាក់ទៀតនិយាយថា "ទេ! យើងគ្មានអគ្គិសនីប្រើទេ។ ពួកគេមិនតភ្ជាប់អគ្គិសនីឲ្យយើងទេ។"

ផលប៉ះពាល់ដល់បរិស្ថាន អាចឃើញច្បាស់បំផុតក្នុងពេលសាងសង់ទំនប់។ ដីនិងព្រៃជាង ២២៣០ហិកតា ក្នុងឧទ្យានជាតិភ្នំបូកគោ បានលិចលង់អស់ (SAWAC 2011)។ លំហូរទឹកនៅតំបន់ខាងក្រោមទំនប់ មិនមានគ្រប់គ្រាន់ និងមិនទៀងទាត់ទេ ហើយអ្នកភូមិជាច្រើន ជាពិសេស អ្នកលក់ផ្លែឈើបានត្អូញត្អែរថា រមណីដ្ឋានទឹកឈូរទាក់ទាញភ្ញៀវទេសចរបានតិចជាងមុន។ ស្ត្រីម្នាក់នៅភូមិស្នំប្រាំពីរ បានប្រាប់ពីការដែលគាត់ "បានស្នើឲ្យបើកទ្វារទឹកជារៀងរាល់ថ្ងៃ ដើម្បីឲ្យទឹកហូរបានទៀងទាត់"។ គាត់បន្ថែមថា "ឥឡូវនេះ យើងអាចលក់បានត្រឹមតែ ២០ ទៅ ៤០% នៃចំនួនដែលយើងធ្លាប់លក់បានមុនពេលសាងសង់ទំនប់ប៉ុណ្ណោះ។" ចំពោះផលប៉ះពាល់លើធនធានជលផល មានរបាយការណ៍ចម្រុះគ្នាថា មានការកើនឡើងនៅតំបន់ខ្សែទឹកខាងលើ ប៉ុន្តែមានការធ្លាក់ចុះនៅតំបន់ខ្សែទឹកខាងក្រោម។ បុរសម្នាក់នៅភូមិបាត់ក្បាលដំរី បានកត់សម្គាល់ថា "មុនពេលសាងសង់ទំនប់ គ្រួសារនីមួយៗអាចរកត្រីបានពី ២០ ទៅ ៣០គីឡូក្រាម។ ឥឡូវនេះ យើងមិនអាចទៅរកត្រីទេ ព្រោះទំនប់បានបិទ ហើយត្រីមិនអាចរកឃើញច្រក ដែលគេដាក់ក្នុងទំនប់ ទុកឲ្យវាហែលឆ្លងមកតំបន់ខាងក្រោមនោះទេ។"

ទំនប់វារីអគ្គិសនីកំចាយ ក៏មានផលវិជ្ជមានខ្លះៗដែរ ហើយជាសំខាន់ទំនប់នេះ បានជួយការពារតំបន់ខ្លះពីការលិចទឹកប្រចាំឆ្នាំ។ ជីវភាពបានល្អប្រសើរឡើង សម្រាប់អ្នករស់នៅតាមភូមិដែលតែងមានទឹកជន់លិចពីមុន។ បុរសម្នាក់ នៅភូមិបាត់ក្បាលដំរីនិយាយថា "ជីវភាពរបស់ខ្ញុំ បានប្រសើរជាងកាលពីមុនពេលសាងសង់ទំនប់ ព្រោះឥឡូវគ្មានទឹកជន់លិចទេ។" ទោះយ៉ាងនេះក្ដី អ្នកភូមិខ្លះបានសម្ដែងការបារម្ភពីគ្រោះទឹកជំនន់ ដែលអាចកើតមានដោយសារការធ្លាយទំនប់ ឬការខូចខាតបែបណាមួយនៃទំនប់។ គ្មានការតម្រូវឲ្យផ្លាស់ទីតាំងលំនៅដ្ឋានទេ។ ប្រជាជនមូលដ្ឋាន ហាក់ពេញចិត្តនឹងសំណងទទួលបានលើការបាត់បង់ដើមឈើហូបផ្លែ និងកសិដ្ឋាន។ អ្នកខ្លះបានត្អូញត្អែរដែរ តែក្នុងកម្រិតមួយនៅមានការស្ទាក់ស្ទើរ។

ការលិចលង់ដីព្រៃ និងការប្រែប្រួលនៃជីវចម្រុះនៅជុំវិញអាងស្តុកទឹក, កម្រិតទឹកទាប និងលំហូរទឹកមិនទៀងទាត់ខ្លាំងនៅរដូវប្រាំង, និង ការបិទផ្លូវត្រីហែលឆ្លងកាត់ទៅតំបន់ខាងក្រោម បានផ្ដល់ផលវិបាកយ៉ាងធ្ងន់ធ្ងរ។ អ្នកប្រមូលឫស្សី អ្នកលក់ផ្លែឈើ និងអ្នករកត្រី បានបាត់បង់ប្រភពចិញ្ចឹមជីវិតដោយសារទំនប់ ប៉ុន្តែពុំទាន់មានការគិតគូរឲ្យក្រុមមនុស្សទាំងនេះទទួលបានសំណងប៉ះប៉ូវនោះទេ។

### *របៀបរបបអភិបាលកិច្ច*

ការផ្លាស់ប្ដូរយោបល់ និងអន្តរកម្មនៅគ្រប់កម្រិត និងរវាងកម្រិតផ្សេងៗនៃអភិបាលកិច្ច បានកើតមានឡើងនៅមុនពេល និងក្រោយពេលសាងសង់ទំនប់។ ការសាងសង់ទំនប់វារីអគ្គិសនីកំចាយ បានទទួលសេចក្ដីសម្រេចពីថ្នាក់កំពូលនៃរដ្ឋាភិបាល ពោលគឺ ទីស្ដីការគណៈរដ្ឋមន្ត្រី, ក្រសួងរ៉ែនិងថាមពល និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត ដែលជាទីភ្នាក់ងារគាំទ្រគម្រោង។

អ្នកចូលរួមក្នុងការសិក្សា បានរាយការណ៍ថា សហគមន៍មូលដ្ឋាន ជាពិសេស សហគមន៍ដែលទំនប់ត្រូវប៉ះពាល់ខ្លាំងជាងគេ បានចូលរួមតិចតួចណាស់ ក្នុងដំណើរការពិគ្រោះយោបល់មុនពេលសាងសង់។ មានការពិគ្រោះយោបល់ជាសាធារណៈមួយបានធ្វើឡើងជាចំណែកមួយនៃ ការវាយតម្លៃពីផលប៉ះពាល់លើបរិស្ថាន (EIA)។ ទោះបីអាជ្ញាធរមូលដ្ឋាន ដូចជា ប្រធានភូមិ និងក្រុមប្រឹក្សាឃុំ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុង EIA ក្ដី ប៉ុន្តែពុំមានការសាកសួរយោបល់ ពីអ្នកប្រមូលឫស្សីភាគច្រើននោះទេ។ ប្រជាជនទទួលបានព័ត៌មានតិចតួចណាស់ ស្ដីពីទំនប់នេះ នៅមុនពេលចាប់ផ្ដើមសាងសង់។ បុរសៗនៅភូមិទ្វីខាន់ជើងបានបញ្ជាក់ថា "មានការត្អូញត្អែរច្រើន អំពីការហាមឃាត់មិនឲ្យចូលទៅព្រៃឫស្សីដែលទំនប់បានប៉ះពាល់។" អ្នកភូមិផ្សេងទៀតបានប្រាប់ថា "ម្ដងនោះ មានប្រជាជនជាង ៣០០នាក់ បានតវ៉ាអំពីការមិនអាចចូលទៅក្នុងតំបន់ព្រៃឫស្សី។" អ្នកខ្លះមានការមិនពេញចិត្តនឹងកម្រិតទឹកទាបនៅរមណីយដ្ឋានទឹកឈូរ និងចង់ឲ្យអ្នកគ្រប់គ្រងទំនប់ បើកបង្ហូរទឹកឲ្យច្រើនជាងនេះពីអាងស្តុកទឹក ហើយអ្នកខ្លះទៀត បានត្អូញត្អែរពីការមិនបានប្រើប្រាស់អគ្គិសនី។

សេចក្ដីដូចខាងលើហាក់ដូចបង្ហាញច្បាស់ថា មានទំនាស់ជាច្រើនបានផុសឡើង តាំងពីពេលទំនប់ចាប់ដំណើរការមក។ ប្រជាជនមូលដ្ឋានជាច្រើនបានដាក់ពាក្យបណ្ដឹង ទៅការិយាល័យរដ្ឋអំណាចមូលដ្ឋានមួយចំនួន និងដាក់ទៅក្រុមហ៊ុន Sinohydro ដែលជាអ្នកអភិវឌ្ឍន៍ទំនប់នេះ។ ប៉ុន្តែគេនៅមិនទាន់ដឹងច្បាស់ទេថា អ្នកណាទទួលខុសត្រូវលើការដោះស្រាយទំនាស់ និងបណ្ដឹងស្របច្បាប់ទាំងនេះ ឬក៏បញ្ហានេះត្រូវដោះស្រាយយ៉ាងណា។ ដោយសារការពិគ្រោះយោបល់ នៅមុនពេលសាងសង់មានដំណើការខ្លី និងមានអ្នកតំណាងតិចនាក់នោះ ការប្រាស្រ័យទាក់ទងរវាងក្រុមហ៊ុន Sinohydro អាជ្ញាធរគ្រប់គ្រង និងប្រជាជនរងផលប៉ះពាល់ ក៏ប្រហែលមានតិចដែរ។

### សេចក្ដីសន្និដ្ឋាន

លទ្ធផលនៃករណីសិក្សានេះ ព្រមទាំងការសិក្សាឯកសារយ៉ាងទូលំទូលាយលើច្រើនវិស័យ អំពីផលប៉ះពាល់នៃទំនប់វារីអគ្គិសនីធំៗ បានបង្ហាញពីផលវិជ្ជមាន និងអវិជ្ជមានផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាននៃទំនប់វារីអគ្គិសនីកំចាយ។ ម្យ៉ាងទៀត ផលប៉ះពាល់ ហាក់ដូចជាមាន ការបែងចែកមិនស្មើភាពគ្នាទេក្នុងនេះ ប្រជាជនមូលដ្ឋានដែលពឹងផ្អែកច្រើនទៅលើធនធានធម្មជាតិ និងសេវាកម្មអេកូឡូស៊ី គាត់មានជីវភាពលំបាកខ្លាំងជាងមុន។ ដូច្នេះលក្ខខណ្ឌចាំបាច់ដើម្បីទទួលបានអត្ថប្រយោជន៍ជាសំណងប៉ះប៉ូវ ត្រូវរៀបចំយ៉ាងណាឲ្យមានរួមបញ្ចូលនូវក្រុម

ប្រជាជនដែលបានបាត់បង់មធ្យោបាយទ្រទ្រង់ជីវភាព ដោយសារតែទំនប់នេះ។

ជាទូទៅ ការធ្វើផែនការ និងការគ្រប់គ្រងបរិស្ថាន ដែលមានចែងនៅក្នុងរបាយការណ៍ EIA នោះ មិនឃើញមានអនុវត្តទេ ហើយប្រព័ន្ធតាមដាន និងការវាយតម្លៃក៏ដូច្នោះដែរ។ ប្រជាជនមូលដ្ឋានសឹងតែមិនអាចធ្វើយ៉ាងណា ដើម្បីឲ្យគេទទួលយកបណ្ដឹងតវ៉ារបស់ខ្លួន ព្រោះជាក់ស្ដែងពុំមានការកំណត់យន្តការសម្របសម្រួលណាមួយ សម្រាប់ដោះស្រាយបញ្ហាដែលផុសឡើងក្នុងពេល ឬចាប់តាំងពីពេលការសាងសង់ទំនប់នេះមក។

បញ្ហាថា ប្រជាជនទំនងត្រូវប៉ះពាល់ដោយសារគម្រោងវារីអគ្គិសនី គួរតែទទួលបានការផ្ដល់ដំណឹង និងពិគ្រោះយោបល់ច្រើនប៉ុណ្ណោះ កន្លងមកមានការជជែកតវ៉ាគ្នាជារឿយៗ។ បញ្ហានេះគ្មានចម្លើយងាយស្រួលទេ ព្រោះវាពិបាកនឹងវាយតម្លៃពីផលប៉ះពាល់ជារួម នៃទំនប់វារីអគ្គិសនីជាក់លាក់ណាមួយ៖ ការថ្លឹងថ្លែងរវាងអត្ថប្រយោជន៍ និងផលអាក្រក់ តែងជួបភាពចម្រូងចម្រាស់ចៀសមិនរួច។ ទោះយ៉ាងនេះក្ដី គោលការណ៍ជាមូលដ្ឋាននៃអភិបាលកិច្ចល្អ គួរតែអនុវត្តឲ្យបានរួមមាន៖ ការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយតម្លាភាព, ប្រជាជនមូលដ្ឋានទទួលបានការផ្ដល់ព័ត៌មានយ៉ាងត្រឹមត្រូវ, ការព្រួយបារម្ភរបស់ប្រជាជនមានគេដឹងឮ និងជួយដោះស្រាយ។

ការសិក្សានេះបង្ហាញពី ការប្រើប្រាស់បានយ៉ាងធំទូលាយនូវការស្រាវជ្រាវខាងនយោបាយអេកូឡូស៊ី ដើម្បីវិភាគពីទំនាក់ទំនងអំណាចដ៏ស្មុគស្មាញ ដែលជាឫសគល់នៃវិសមភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ - ក្នុងករណីនេះគឺមាន ទឹក ត្រី ព្រៃឫស្សី និងថាមពលអគ្គិសនី។ ទិន្នន័យនិងព័ត៌មានបានពីការស្រាវជ្រាវទាំងនេះ នឹងជួយឲ្យមានការធ្វើសម្រេចចិត្តឲ្យបានកាន់តែប្រសើរ និងមានផលចំណេញ ពីការការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍទំនប់វារីអគ្គិសនី នៅពេលអនាគតដ៏វែងឆ្ងាយ។

## ឯកសារយោង


ASEAN Centre for Energy. 2011. *Electrical Tariffs in ASEAN Member Countries*. Jakarta Selatan: ASEAN Center for Energy.

Bryant, P. 1985. *The Political Economy of Soil Erosion in Developing Countries*. London: Longman.

Bryant, R., and S. Bailey. 1997. *Third World Political Ecology*. London: Routledge.

EAC, Electricity Authority of Cambodia. 2014. *Report on Power Sector of the Kingdom of Cambodia*. Phnom Penh: EAC.

Gätke, P., and B. Un. 2013. *The Kamchay Hydropower Dam: An Assessment of the Dam's Impacts on Local Communities and the Environment*. Phnom Penh: NGO Forum on Cambodia.

Greenberg, James B., and Thomas K. Park 1994. "Political Ecology." *Journal of Political Ecology* 1:1-12.

"Political Ecology." *Wikipedia,* last modified 8 Jun 2015. Accessed 19 Jun 2015, www.en.wikipedia.org/?title=Political_ecology.

Robbins, Paul. 2012. *Political Ecology: A Critical Introduction.* 2nd ed. Malden, MA; London: Wiley-Blackwell.

SAWAC, Sanitation, Agriculture, Water and Agronomy in Cambodia. 2011. *Environmental and Social Impact Assessment (ESIA): Kamchay Hydroelectric Project in Kampot Province*. Phnom Penh: SAWAC.

Siciliano, Giuseppina, Frauke Urban, Kim Sour and Lonn Pich Dara. Forthcoming. "Hydropower, Social Priorities and the Rural-Urban Development Divide: The Case of Large Dams in Cambodia." *Energy Policy.*

Tan-Mullins, May. 2007. "The State and Its Agencies in Coastal Resources Management: The Political Ecology of Fisheries Management in Pattani, Southern Thailand." *Singapore Journal of Tropical Geography* 28(3): 348-361.

Wolf, Eric. 1972. "Ownership and Political Ecology." *Anthropological Quarterly* 45(3): 201-205.


---

*តពីទំព័រ ៥ ...*

## អេកូឡូស៊ីផ្នែកនយោបាយ ...


Itakura, Ken. 2013. Impact of Liberalization and Improved Connectivity and Facilitation in ASEAN for the ASEAN Economic Community Jakarta: Economic Research Institute for ASEAN and East Asia.

KPMG. 2014. The ASEAN Economic Community 2015: On the Road to Real Business Impact. KPMG Asia Pacific Tax Centre.

Madhur, Srinivasa. 2014. *Cambodia's Skill Gap: An Anatomy of Issues and Policy Options*. Working Paper Series No.98. Phnom Penh: Cambodia Development Resource Institute.

Todd, William E. 2015. "ASEAN Integration: An Opportunity for Business in Cambodia." *The Cambodia Herald*, 11 Jan 2015.

World Bank. 2014. *Clear Skies: Cambodia Economic Update*. Phnom Penh: World Bank.

Woetzel, Jonathan, Oliver Tonby, Fraser Thompson, Penny Burtt and Gillian Lee. 2014. *Southeast Asia at the Crossroads: Three Paths to Prosperity*. McKinsey Global Institute.

Wong, Marn-Heong, and Andre Wirjo. 2013. *Findings from 2013 ASEAN-BAC Survey on ASEAN Competitiveness*. Jakarta: ASEAN Business Advisory Council.

# លំហូរកម្លាំងពលកម្មស្ត្រីនៅក្នុងមហាអនុតំបន់មេគង្គ

## សេចក្ដីផ្ដើម

អត្ថបទនេះ ពិនិត្យឡើងវិញពីបញ្ហាចម្បងៗទាក់ទងនឹងលំហូរកម្លាំងពលកម្មស្ត្រី នៅក្នុងមហាអនុតំបន់មេគង្គ (GMS) ដោយផ្ដោតសំខាន់លើលំនាំនៃការធ្វើចំណាកស្រុក មូលហេតុនៃចំណាកស្រុក បញ្ហាប្រឈម និងផលប៉ះពាល់។ ទិន្នន័យបែងចែកតាមភេទដែលអាចរកបាន មានតិចតួចណាស់ ដោយសារនៅតាមមូលដ្ឋានមានសមត្ថភាពតិច ក្នុងការប្រមូលព័ត៌មានផ្នែកសេដ្ឋកិច្ចសង្គមកិច្ច លើចំណាកស្រុកទ្រង់ទ្រាយធំ ហើយចំណាកស្រុកភាគច្រើនក៏មិនបានចុះបញ្ជីទេ។ ដូច្នេះការពិភាក្សាមួយចំនួននៅខាងក្រោម មានលក្ខណៈទូទៅ សម្រាប់ទាំងចំណាកស្រុកបុរស និងចំណាកស្រុកស្ត្រី ហើយខ្លះទៀតផ្ដោតលើភេទជាក់លាក់។ បញ្ហាចម្បងៗកំពុងផុសឡើង រួមមានកំណើនលឿននៃលំហូរជនចំណាកស្រុកនៅក្នុង និងនៅក្រៅអនុតំបន់, លំហូរមិនទៀងទាត់, ការកេងប្រវ័ញ្ចពលកម្ម និងការរំលោភសិទ្ធិ ដោយមានសេវាជួយការពារផ្នែកច្បាប់តិចតួចបំផុត, ប៉ុន្តែនៅតែឃើញមានលទ្ធផលរីកលូតលាស់វិជ្ជមាន សម្រាប់គ្រួសារ និងប្រទេសជាតិ។

## លំនាំចំណាកស្រុក

មានលំនាំធំៗពីរនៃចំណាកស្រុកកម្លាំងពលកម្ម ដែលអាចសម្គាល់ឃើញនៅក្នុងតំបន់៖ ខាងក្នុង GMS និង ហួសពី GMS (ខាងក្នុង និង ខាងក្រៅអាស៊ាន)។

### *ការធ្វើចំណាកស្រុកខាងក្នុង GMS*

ចំណាកស្រុករបស់បុរស និងស្ត្រី ក្នុង GMS មានសន្ទុះខ្លាំង និងកើនចំនួនលឿនជាងមុន (ADB 2013; Caouette et al. 2007; Jalilian 2012)។ ចំនួនពលករចំណាកស្រុកក្នុងអនុតំបន់មានពី ៣ ទៅ ៥លាននាក់ ហើយស្តុកពលករចំណាកស្រុករំពឹងថានឹងកើន ២៨% នៅត្រឹមឆ្នាំ២០២០ (Lewis et al. 2010)។ ចំណាកស្រុកខាងក្នុង GMS ទាក់ទងចម្បងនឹងលំហូរពលករគ្មានជំនាញពី CLM (កម្ពុជា ឡាវ និង មីយ៉ាន់ម៉ា) ទៅប្រទេសថៃ។ ចំណាកស្រុកនេះ មានលក្ខណៈមិនទៀងទាត់ទេ។ ទិន្នន័យទទួលបានពីក្រសួងមហាផ្ទៃថៃ (មានចុះក្នុង IOM 2011) បង្ហាញថា ពលករចំណាកស្រុកមានជំនាញទាបរបស់ CLM មាន ២,៤៦លាននាក់ ក្នុងឆ្នាំ២០០៩ ក្នុងនេះ ១,៤លាននាក់មិនបានចុះបញ្ជីត្រឹមត្រូវទេ។ ក្នុងចំណោមពលករចំណាកស្រុកបានចុះបញ្ជីរបស់ CLM មាន ៨២% មកពីប្រទេសមីយ៉ាន់ម៉ា។ ក្រៅពីលំហូរពលករគ្មានជំនាញពី CLM ទៅប្រទេសថៃ ក៏មានលំហូរពលករវៀតណាមមានជំនាញខ្ពស់ចូលមក កម្ពុជា ឡាវ និង ថៃ ព្រមទាំងពលករចិនមានជំនាញខ្ពស់ មកពីខេត្ត Yunnan និង Guangxi ចូលទៅប្រទេសឡាវ និង មីយ៉ាន់ម៉ា (World Bank 2006; Caouette et. Al 2007)។

សមាមាត្រពលករស្ត្រី CLM ដែលបានចុះបញ្ជីនៅក្នុងប្រទេសថៃ កើនឡើងពី ២៩% ក្នុងឆ្នាំ ១៩៩៨ ដល់ ៤៦% ក្នុងឆ្នាំ២០០៩ (ILO n.d)។ ពលករបុរសភាគច្រើនស្វែងរកការងារក្នុងវិស័យសំណង់ កសិកម្ម ឬនៅលើទូកនេសាទ ចំណែកឯពលករស្ត្រី ជាទូទៅរកបានការងារធ្វើជាអ្នកបម្រើតាមផ្ទះ ឬការងារនៅតាមរោងចក្រ ជាពិសេសរោងចក្រកែច្នៃស្បៀងអាហារ (IOM 2011)។

### *ចំណាកស្រុកហួសពី GMS*

ក្រៅពីកំណើនចំណាកស្រុកខាងក្នុង GMS ក៏មានកំណើនយ៉ាងលឿន នៃលំហូរពលករទៅកាន់ប្រទេសនៅក្រៅតំបន់ដែរ ភាគច្រើន តាមរយៈកម្មវិធីនាំចេញកម្លាំងពលកម្ម។ ចំណាកស្រុកហួសពី GMS ជាទូទៅជាប់ទាក់ទងនឹងប្រទេស GMS ជាពិសេសប្រទេស ថៃ វៀតណាម និង កម្ពុជា ដែលបញ្ជូនពលករក្រោមកិច្ចព្រមព្រៀងនាំចេញពលកម្ម ទៅកាន់ប្រទេសមានៗជាងខ្លួនក្នុងតំបន់អាស៊ាន (ភាគច្រើនទៅ ម៉ាឡេស៊ី និង សិង្ហបុរី) ឬប្រទេសនៅក្រៅអាស៊ាន។ ប្រទេសថៃ មានកម្មវិធីនាំចេញពលកម្ម ដោយបញ្ជូនពលករថៃមានជំនាញមធ្យមនិងទាបទៅប្រទេស តៃវ៉ាន់ ចិន ជប៉ុន អ៊ីស្រាអ៊ែល ម៉ាឡេស៊ី កូរ៉េខាងត្បូង និងប្រទេសមជ្ឈឹមបូព៌ាមួយចំនួន។ ប្រទេសវៀតណាម បានអនុវត្តកម្មវិធីនាំចេញពលកម្មតាំងពីឆ្នាំ១៩៨០ និងជាសំខាន់ទៅកាន់ប្រទេស ជប៉ុន តៃវ៉ាន់ កូរ៉េខាងត្បូង និង ម៉ាឡេស៊ី។ ប្រទេសកម្ពុជាបានបញ្ជូនពលករទៅប្រទេស ម៉ាឡេស៊ី កូរ៉េខាងត្បូង សិង្ហបុរី និង ជប៉ុន។

## មូលហេតុនៃចំណាកស្រុក

ចំណាកស្រុកក្នុងតំបន់ GMS បណ្ដាលជាចម្បងមកពីភាពខុសគ្នាខ្លាំង ផ្នែកប្រជាសាស្ត្រ និងសេដ្ឋកិច្ច រចនាសម្ព័ន្ធទីផ្សារពលកម្មបំពេញឲ្យគ្នាក្នុងចំណោមប្រទេស GMS និងសមាហរណកម្ម និងការតភ្ជាប់កាន់តែប្រសើរ (ADB 2013; Caouette et al. 2007; Jalilian 2012)។

- *ការអភិវឌ្ឍផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច មិនស្មើគ្នា ជំរុញឲ្យមានចំណាកស្រុក។* ការសិក្សាជាច្រើន បង្ហាញពីភាពខុសគ្នាគួរឲ្យកត់សំគាល់នៃប្រាក់ចំណូល រចនាសម្ព័ន្ធសេដ្ឋកិច្ច និងទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍមនុស្ស (ដូចជា រចនាសម្ព័ន្ធប្រជាសាស្ត្រ និងកម្រិតអប់រំ) នៅក្នុងតំបន់ GMS។ ប្រទេសថៃបានអភិវឌ្ឍជឿនលឿនជាងគេ ដោយមាននគរូបនីយកម្មឆាប់រហ័ស និងរចនាសម្ព័ន្ធសេដ្ឋកិច្ចធំទូលាយ ផ្អែកលើ

អត្ថបទនេះ រៀបរៀងឡើងដោយ ហ៊ីង វុត្ថា អ្នកស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៃវិទ្យាស្ថាន CDRI ។ សូមយោងអត្ថបទនេះថា៖ Hing Vutha. 2015. "Women's Labour Mobility in the Greater Mekong Subregion." *Cambodia Development Review* 19(1): 12-16.

កម្មន្តសាលកម្មប្រើពលកម្មច្រើន សេវាកម្ម និងកសិកម្ម ដែលផ្តោតលើការនាំចេញ និងមានការរីកលូតលាស់លឿន។ កំណើនសេដ្ឋកិច្ចថៃ បានបង្កើតការងារជាច្រើន ប៉ុន្តែប្រទេសថៃមានប្រជាជនកាន់តែវ័យចំណាស់ ដូចអាចឃើញច្បាស់តាមអត្រាកំណើនអវិជ្ជមាន នៃចំនួនប្រជាជនក្នុងក្រុមអាយុអាចធ្វើការបាន។ កង្វះខាតពលករយ៉ាងច្រើន ដោយសារបញ្ហានេះ ធ្វើឲ្យថៃត្រូវពឹងផ្អែកលើពលករចំណាកស្រុកមកពីប្រទេសជិតខាង។ CLM មានប្រជាជនវ័យក្មេងយ៉ាងច្រើន មានអត្រាកំណើនប្រជាជនខ្ពស់ និងមានយុវជន និងមនុស្សក្នុងក្រុមអាយុអាចធ្វើការបានកាន់តែច្រើនឡើង។ ប៉ុន្តែកំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំងនេះ មានមូលដ្ឋានតូចចង្អៀត ពឹងផ្អែកលើកសិកម្ម និង មានវិស័យសេវាកម្ម និងកម្មន្តសាលកម្មនៅតូច (ដូចជា វិស័យកាត់ដេរ សំណង់ និងទេសចរណ៍)។ ដោយមានលក្ខណៈបែបនេះ សេដ្ឋកិច្ចរបស់ CLM មិនអាចស្រូបយកកម្លាំងពលកម្មរបស់ខ្លួន ដែលកើនឡើងឥតឈប់ឈរបានទេ ហើយក៏មានអតិរេកកម្លាំងពលកម្ម។ រចនាសម្ព័ន្ធទីផ្សារពលកម្ម និងសេដ្ឋកិច្ចបំពេញឲ្យគ្នាបែបនេះ ជាកត្តាជំរុញលំហូរពលករឆ្លងកាត់ព្រំដែនដែលមានប្រទេសថៃជាទីផ្សារពលកម្មគោលដៅចម្បង និង CLM ជាប្រភពផ្គត់ផ្គង់កម្លាំងពលកម្ម។

- *សមាហរណកម្ម និងការតភ្ជាប់កាន់តែប្រសើរ ជួយជំរុញចំណាកស្រុក។* ប្រទេស GMS បានចូលរួមក្នុងក្របខ័ណ្ឌសហប្រតិបត្តិការមានច្រើនកម្រិត។ កម្មវិធីសហប្រតិបត្តិការ GMS ដែលធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បង្កើតឡើងក្នុងឆ្នាំ១៩៩២ បានតភ្ជាប់ប្រទេសកំពុងអភិវឌ្ឍន៍ ទៅនឹងប្រទេសមានសន្ទុះសេដ្ឋកិច្ចខ្លាំងក្លាជាង តាមរយៈការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធធំទូលាយ។ ក្របខ័ណ្ឌសហប្រតិបត្តិការអាស៊ាន ផ្តល់ឱកាសកាន់តែច្រើនសម្រាប់ពាណិជ្ជកម្ម និងវិនិយោគ តាមរយៈគំនិតផ្តួចផ្តើមសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ។ អាស៊ាន ក៏ជួយតភ្ជាប់ប្រទេស GMS ទៅនឹងតំបន់អាស៊ីធំទូលាយ តាមរយៈកិច្ចព្រមព្រៀងអាស៊ានបូកនានា (ASEAN Plus Agreements) ដូចជា អាស៊ានបូក១ និង អាស៊ានបូក៣ ជាដើម។ លក្ខណៈមានច្រើនកម្រិតនៃប្រព័ន្ធថ្នាក់អនុតំបន់ និងតំបន់ គួបផ្សំនឹងការតភ្ជាប់កាន់តែប្រសើរ វាជួយបង្កើនពាណិជ្ជកម្មផ្ទៃក្នុងតំបន់ អន្តរកម្មខាងសេដ្ឋកិច្ច និងលំហូរប្រជាជនឆ្លងកាត់ព្រំដែន (Caouetter et al. 2007; ADB 2013)។
- *ទីតាំងភូមិសាស្ត្រនៅជិតៗគ្នា ជួយជំរុញលំហូរពលករ។* ប្រទេសថៃ មានព្រំប្រទល់វែង និងមិនសូវជិតគត់មត់ទេជាមួយប្រទេស CLM។ ជាក់ស្តែង ព្រំដែនដីគោកថៃនឹងកម្ពុជាមានប្រវែង ៨០៣ គ.ម ដែលមានច្រកចូលក្រៅផ្លូវការជាច្រើន។ ប្រទេសឡាវ មានព្រំប្រទល់ ១៨៣៥ គ.ម ជាមួយប្រទេសថៃ។ លំហូរឆ្លងកាត់ព្រំដែន ក៏ជំរុញឡើងដោយសារការផ្លាស់ប្តូរទីតាំងឧស្សាហកម្ម ទៅនៅតាមទីប្រជុំជនជិតព្រំដែនថៃ ដើម្បីទាញយកចំណេញពីកម្លាំងពលកម្មដ៏សម្បូរ (ADB 2013)។

**បញ្ហាចោទ**

ដូចនៅតាមតំបន់ជាច្រើនក្នុងពិភពលោកដែរ ពលករចំណាកស្រុកបុរស និងស្ត្រី ក្នុង GMS ត្រូវជួបបញ្ហាជាច្រើននៅតាមដំណាក់កាលផ្សេងៗ។ បញ្ហាខ្លះកើតឡើងក្នុងដំណើរការជ្រើសរើស ប៉ុន្តែបញ្ហាភាគច្រើនកើតឡើងនៅកន្លែងធ្វើការ។ បញ្ហា និងកម្រិតធ្ងន់ធ្ងររបស់វា ប្រែប្រួលទៅតាមដំណើរធ្វើចំណាកស្រុក ប្រភេទការងារ និងប្រទេសគោលដៅ។

- *ច្បាប់គ្រប់គ្រងអន់ខ្សោយ លើទីភ្នាក់ងារជ្រើសរើស។* របៀបរបបអនុវត្តមិនត្រឹមត្រូវ និងការធ្វេសប្រហែសរបស់ទីភ្នាក់ងារជ្រើសរើស រួមទាំងអ្នកមានអាជ្ញាប័ណ្ណផង ឃើញមានច្រើនណាស់។ ការរំលោភបំពានចម្បងៗមុនពេលចេញដំណើរ មានដូចជា ការយកថ្លៃជ្រើសរើស និងយកថ្លៃធ្វើដំណើរច្រើនហួសហេតុ ការដកយកលិខិតឆ្លងដែនទុក និងការផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ មិនពិត ឬនាំឲ្យភ័ន្តច្រឡំអំពីលក្ខខណ្ឌការងារ (Hing and Ly 2014)។ ជាក់ស្តែងនៅប្រទេសកម្ពុជា មានភស្តុតាងបង្ហាញពីបេក្ខជនពលករធ្វើចំណាកស្រុក ត្រូវគេបង្ខាំងទុកនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលមុនពេលចាកចេញ ដែលមានមនុស្សច្រើនលើសចំណុះ និងគ្មានអនាម័យ។ ពលករក៏បានរាយការណ៍ផងដែរពីការរំលោភបំពានលើរូបកាយ ការបង្ខំឲ្យធ្វើការច្រើនម៉ោង ពេលសម្រាកមានតិចតួច ការគ្មានរបបឈប់សម្រាកនៅចុងសប្តាហ៍ ឬរបបឈប់សម្រាកប្រចាំឆ្នាំ ការមានអារម្មណ៍កំព្រាឯកោ និងការនឹកផ្ទះជាខ្លាំង (Hing and Ly 2014)។
- *ការគ្រប់គ្រងចំណាកស្រុកនៅទន់ខ្សោយ។* ចំណាកស្រុកស្របច្បាប់ ជាដំណើរការស្មុគស្មាញ យូរពេល និងអស់សោហ៊ុយច្រើន ដែលធ្វើឲ្យពលករភាគច្រើន ជ្រើសយកការធ្វើចំណាកស្រុកខុសច្បាប់។ បញ្ហាដែលរដ្ឋាភិបាលនានារបស់ CLM ត្រូវប្រឈម វាកាន់តែធ្ងន់ធ្ងរឡើងដោយសារ កង្វះយន្តការពង្រឹងអនុវត្តន៍ច្បាប់ ដើម្បីធានាឲ្យមានការគ្រប់គ្រងចំណាកស្រុកប្រកបដោយប្រសិទ្ធភាព និងកង្វះសេវាផ្នែកច្បាប់ និងសេវាគាំទ្រ សម្រាប់ជនចំណាកស្រុក ជាពិសេសជនរងគ្រោះដោយសារការជួញដូរកម្លាំងពលកម្ម និងការរំលោភបំពាននៅកន្លែងធ្វើការ។
- *ភាពងាយរងគ្រោះក្នុងពេលធ្វើដំណើរ។* ពលករចំណាកស្រុកខុសច្បាប់ ដែលជារឿយៗត្រូវធ្វើដំណើរនៅខាងក្រៅក្របខ័ណ្ឌច្បាប់របស់ប្រទេសបញ្ជូន និងប្រទេសទទួលពលករនោះ មានហានិភ័យខ្ពស់ណាស់ នឹងជួបការរំលោភបំពាន និងការកេងប្រវ័ញ្ចពីសំណាក់និយោជក ហើយជាទូទៅពុំមានមធ្យោបាយស្វែងរកកិច្ចការពារតាមផ្លូវច្បាប់ទេ។ ច្បាប់នៅមីយ៉ាន់ម៉ា ហាមឃាត់មិនឲ្យស្ត្រីក្រោមអាយុ ២៥ឆ្នាំ ធ្វើដំណើរទៅក្រៅប្រទេស ដោយគ្មានអ្នកមើលការខុសត្រូវស្របច្បាប់។ ច្បាប់នេះ ធ្វើឲ្យស្ត្រីក្មេងៗរុញរានឹងធ្វើចំណាកស្រុកស្របច្បាប់ និងកាន់តែហ៊ានទទួលយក មធ្យោបាយរបស់ឈ្មួញផ្តល់ការងារដែលសន្យាថា នឹងរៀបចំនូវការធ្វើដំណើរដោយមានគេជូនត្រឹមត្រូវ និងមានការងារមានប្រាក់ខែ (SERC n.d)។

- *បញ្ហានៅកន្លែងធ្វើការ។* ការលើកកម្ពស់ និងការការពារសិទ្ធិរបស់ពលករចំណាកស្រុក នៅមានចំណុចខ្វះខាតច្រើន ជាពិសេស នៅប្រទេសគោលដៅ។ ការកេងប្រវ័ញ្ចមានច្រើនណាស់ ជាពិសេសការឆបោកលើប្រាក់ខែ ប្រភេទការងារ និងស្ថានភាពតាមផ្លូវច្បាប់របស់ពលករ ការកាត់ទុកប្រាក់ខែ ការដកយកលិខិតឆ្លងដែន ឬឯកសារអត្តសញ្ញាណ ការឃុំឃាំងពលករ លក្ខខណ្ឌការងារក្រោមកម្រិតស្តង់ដារ និងការគម្រាមកំហែងរាយការណ៍ប្រាប់អាជ្ញាធរ។ វិសមភាព និងការរើសអើងផ្លូវភេទ មានន័យថា ស្ត្រីងាយរងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ច ជាងបុរស។ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល បង្ហាញពីការធ្វើបាបធ្ងន់ធ្ងរលើពលករកម្ពុជា ដែលទៅបម្រើការតាមផ្ទះនៅប្រទេសម៉ាឡេស៊ី។ ជាក់ស្តែង ក្នុងឆ្នាំ២០១២ មាន ៩០ករណីនៃការបង្ខំឲ្យពន្យាពេលកិច្ចសន្យាការងារ ការរំលោភបំពាន និងធ្វើទារុណកម្មលើរាងកាយ ការបាត់ខ្លួនរបស់ស្ត្រីពលករ ឬស្ត្រីត្រូវការរង់ចាំប្រាក់ខែមិនទាន់បើកឲ្យ នៅក្នុងប្រទេសម៉ាឡេស៊ី (CLEC, LSCW, and HRW n.d)។ ក្នុងឆ្នាំ ២០១០ និង ២០១២ អង្គការលីកាដូ បានជួយ និង/ឬ នាំពលករកម្ពុជាជាអ្នកបម្រើតាមផ្ទះ ២៥០នាក់ នៅម៉ាឡេស៊ី ឲ្យត្រឡប់មកកម្ពុជាវិញ។ សម្រាប់ពលករចំណាកស្រុកនៅប្រទេសថៃវិញ បញ្ហាចម្បងរួមមាន ការពុំមានមធ្យោបាយស្វែងរកកិច្ចការពារតាមផ្លូវច្បាប់ (ដោយសារការភ័យខ្លាច ឬកង្វះសេរីភាព) អំពើហិង្សា និងលក្ខខណ្ឌការងារលំបាកនិងមានគ្រោះថ្នាក់។ ការចងក្រងករណីសិក្សារបស់លោក Naro (2009) ស្តីពីការធ្វើបាបពីសំណាក់និយោជក មកលើពលករចំណាកស្រុកកម្ពុជា បង្ហាញពីពលករមួយចំនួនត្រូវធ្វើការយូរម៉ោង តែបានប្រាក់ខែតិច ហើយខ្លះទៀតត្រូវរងការធ្វើបាបលើរាងកាយនៅពេលមិនព្រមធ្វើតាមបង្គាប់។
- *យន្តការប្តឹងតវ៉ានៅទន់ខ្សោយ ឬគ្មានប្រសិទ្ធភាព។* ដំណោះស្រាយគួរឲ្យពេញចិត្ត និងទាន់ពេល មានតិចតួចណាស់ នៅពេលមានបញ្ហាផុសឡើង។ ការកេងប្រវ័ញ្ចរបស់និយោជកទៅលើពលករ នៅតែគ្មានការទប់ទល់ពីសំណាក់រដ្ឋាភិបាល ហើយប្រព័ន្ធច្បាប់ មិនបានការពារពលករទេ ជាពិសេស ទាក់ទងនឹងបញ្ហាប្រាក់ខែ លក្ខខណ្ឌការងារ និងការរំលោភបំពានលើនិយោជិត។
- *លទ្ធភាពមានកំហិតក្នុងការទទួលបានសេវាសុខភាព និងសន្តិសុខសង្គម។* ពលករចំណាកស្រុកភាគច្រើន ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវជួបការលំបាកជាច្រើនក្នុងការទទួលសេវាសន្តិសុខសង្គម ដោយសារសិទ្ធិទទួលបានផលប្រយោជន៍ទាំងនេះ វាផ្សារភ្ជាប់ទៅនឹងសកម្មភាពសេដ្ឋកិច្ច ឬស្ថានភាពការងារស្របច្បាប់។ កត្តាផ្សេងៗទៀតដែលកាត់បន្ថយលទ្ធភាពរបស់ជនចំណាកស្រុក ក្នុងការទទួលបានសេវាសន្តិសុខសង្គម រួមមាន ដំណើរការរដ្ឋបាល ភាសា និងការរើសអើង។ ប្រទេសខ្លះបានបដិសេធ ឬដាក់កំហិតលើសិទ្ធិទទួលបាន អត្ថប្រយោជន៍ផ្នែកសុខុមាលភាពជាក់លាក់ខ្លះរបស់ពលករចំណាកស្រុក។
- *បញ្ហាចោទនៅពេលត្រឡប់មកវិញ។* ពលករត្រឡប់មកស្រុកវិញ ត្រូវជួបបញ្ហាជាច្រើន នៅក្នុងមាតុប្រទេសរបស់ខ្លួន។ បញ្ហាទូទៅបំផុត គឺ ឧបសគ្គក្នុងការធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍ដើមរបស់ខ្លួនវិញ។ ពលករភាគច្រើនមិនបានត្រៀមចិត្ត សម្រាប់ការវិលត្រឡប់មកប្រទេសកំណើតវិញទេ ហើយការទទួលស្វាគមន៍របស់គ្រួសារ និងសហគមន៍របស់គាត់ វាប្រែប្រួលទៅតាមប្រាក់សន្សំដែលគាត់យកមកជាមួយ (Caouette et al. 2007)។ បញ្ហាមួយទៀត គឺកង្វះកម្មវិធីធ្វើសមាហរណកម្មឡើងវិញ ដូចជា ការទទួលស្គាល់ជំនាញ សេវារកការងារឲ្យធ្វើ និងសេវាហិរញ្ញវត្ថុ។ ប្រទេសដូចជា មីយ៉ាន់ម៉ា ឡាវ វៀតណាម និង ចិន មានច្បាប់សម្រាប់ផាកពិន័យ ឬដាក់ទោសពលរដ្ឋដែលបានចាកចេញពីប្រទេសដោយមិនបានជូនដំណឹងដល់អាជ្ញាធរ (Caouette et al. 2007)។ ការប្រកែប្រកាន់ និងផ្ទត់គំនិតអវិជ្ជមានមួយចំនួនក៏អាចបន្ថែមទម្ងន់ដល់ការលំបាក ដែលពលករចំណាកស្រុកត្រូវប្រឈមនៅពេលត្រឡប់មកវិញដែរ (Caouette et al. 2007)។ ពលករចំណាកស្រុក និងគ្រួសាររបស់គាត់ កាន់តែតឹងតែងក្នុងចិត្តខ្លាំងឡើង បើសិនជននោះធ្លាប់រងការរំលោភបំពាន ឬមកដល់ផ្ទះវិញដោយមានបញ្ហាសុខភាពធ្ងន់ធ្ងរ។ ស្ថានភាពកាន់តែអាក្រក់ឡើងទៀត សម្រាប់ពលករចំណាកស្រុកជាស្ត្រី ព្រោះសហគមន៍ខ្លះ រើសអើងចំពោះពួកគេ ដោយសន្មតថា ពួកគេធ្លាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ក្នុងការងារបម្រើផ្លូវភេទ (Caouette et al. 2007)។

## ផលប៉ះពាល់នៃការធ្វើចំណាកស្រុក

ជាទូទៅគេតែងគិតថា ចំណាកស្រុកមានផលវិជ្ជមានច្រើនជាងអវិជ្ជមានមកលើការអភិវឌ្ឍ។ ផលប្រយោជន៍ទាំងនោះមានដូចជា ការកាត់បន្ថយអតុល្យភាពរវាងតម្រូវការនឹងការផ្គត់ផ្គង់កម្លាំងពលកម្ម, កំណើនចំណូលបានមកពីប្រាក់ផ្ញើមកផ្ទះ, សុខភាព ការអប់រំ និងអាហារូបត្ថម្ភបានល្អប្រសើរឡើង, កំណើនចំណាយប្រើប្រាស់, និង លទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានហិរញ្ញវត្ថុ (Ratha et al. 2011; Caouette et al. 2007; Jalilian 2012)។

សម្រាប់ប្រទេសខ្វះខាតកម្លាំងពលកម្ម ដូចជា នៅថៃជាដើមវត្តមាន និងលទ្ធភាពទទួលបានកម្លាំងពលកម្មគ្មានជំនាញ និងមានជំនាញទាប ពី CLM អាចធានានូវការផ្គត់ផ្គង់ពលករជាហូរហែ និងអាចទុកចិត្តបាន ដែលជាកត្តាសំខាន់បំផុតសម្រាប់ជួយរក្សាសមត្ថភាពប្រកួតប្រជែង (World Bank 2006; IOM 2011)។ កម្មន្តសាលកម្មអតិពលកម្ម ការនេសាទ និងកសិកម្ម ដែលជាវិស័យដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចថៃ នៅតែមានលក្ខណៈប្រកួតប្រជែង ព្រោះគេអាចរកបានច្រើនណាស់នូវកម្លាំងពលកម្មចំណាកស្រុកមានតម្លៃទាប (World Bank 2006; IOM 2011)។ សម្រាប់ CLM ដែលសម្បូរកម្លាំងពលកម្មនេះ លំហូរពលករឆ្លងកាត់ព្រំដែនកាន់តែងាយស្រួល និងសេរីឡើង អាចជួយកាត់បន្ថយអត្រាគ្មានការងារធ្វើ ជាពិសេស នៅតាម

សហគមន៍ជនបទដែលតែងខ្វះខាតឱកាសសេដ្ឋកិច្ច និងមានអ្នកគ្មានការងារធ្វើច្រើននាក់។

លំហូរប្រាក់ផ្ញើមកផ្ទះ ចូលក្នុងប្រទេស GMS នៅឆ្នាំ២០១៣ មាន ៥,៦៩៣ពាន់លានដុល្លារ នៅថៃ (១,៥% នៃ ផសស), ១១ពាន់លានដុល្លារ នៅវៀតណាម (៦,៤% នៃ ផសស), ៥៩លានដុល្លារ នៅឡាវ (0,៥% នៃ ផសស,) និង ១៧៦លានដុល្លារ នៅកម្ពុជា (១,២% នៃ ផសស)។ បទពិសោធន៍តាមប្រទេសនានា រួមទាំងនៅប្រទេស GMS ផង បង្ហាញថា ប្រាក់ផ្ញើមកផ្ទះអាចជួយរក្សាស្ថិរភាពជញ្ជីងទូទាត់ និងកាត់បន្ថយភាពងាយប្រែប្រួលនៃសេដ្ឋកិច្ច (Ahsan et al. 2014)។

ប្រាក់ដែលពលករចំណាកស្រុកផ្ញើមកផ្ទះ គេយកទៅប្រើក្នុងគោលដៅច្រើនយ៉ាង។ នៅកម្ពុជា ប្រហែល ៨៧% នៃប្រាក់ផ្ញើមកផ្ទះសរុប គឺសម្រាប់ដោះស្រាយចំណាយប្រើប្រាស់ប្រចាំថ្ងៃ (ភាគច្រើន អាហារ) ការសងបំណុល ការព្យាបាលជំងឺ និងទ្រព្យជាប់លាប់របស់គ្រួសារ ហើយ ១៣% ទៀត សម្រាប់ចំណាយលើធាតុចូលកសិកម្ម ការបង្កើតមុខជំនួញ ការពង្រីកមុខជំនួញមានស្រាប់ និងទ្រព្យផលិតកម្មជាប់លាប់ផ្សេងទៀត (CDRI 2009)។ ការសិក្សានាពេលថ្មីៗនៅវៀតណាម បង្ហាញថា បន្ទាប់ពីការសងកម្ចីដែលទទួលបាន មុនពេលធ្វើចំណាកស្រុក ប្រាក់ទាំងនោះត្រូវបានវិនិយោគជាសំខាន់ ទៅលើទ្រព្យរូបវន្ត និងធនធានមនុស្ស៖ ការសាងសង់ផ្ទះ (៥៣,៣%) ការសិក្សារបស់កូនៗ (២៤,២%) និង ជំនួញ (១៧%) (Lee and Mont 2014)។ ពលករវៀតណាមដែលត្រឡប់មកស្រុកវិញភាគច្រើនរាយការណ៍ថា ពួកគេអាចសន្សំប្រាក់បានច្រើនពីការងារនៅក្រៅប្រទេស ហើយប្រើប្រាក់ទាំងនោះ ដើម្បីធ្វើវិនិយោគលើជំនួញតូចតាចនៅតាមផ្ទះ។

ចំណាកស្រុកមានផលវិជ្ជមាន ទៅលើជីវភាពរបស់ប្រជាជន។ ក្នុង GMS គ្រួសារដែលមានសមាជិកជាពលករចំណាកស្រុក ជាទូទៅតែងមានប្រាក់ចំណូល និងចំណាយប្រើប្រាស់ ខ្ពស់ជាងគ្រួសារដែលគ្មានសមាជិកជាពលករចំណាកស្រុក (Jalilian 2012)។ នៅឡាវ គ្រួសារមានសមាជិកធ្វើការនៅក្រៅប្រទេស តែងមានទ្រព្យសម្ភារ ដូចជា ទូរទស្សន៍ ទូរស័ព្ទដៃ វិទ្យុ ត្រាក់ទ័រហាង និងប្រាក់កាស ច្រើនជាងគ្រួសារ ដែលគ្មានសមាជិកធ្វើការនៅក្រៅប្រទេស។ នៅកម្ពុជា ចំណាកស្រុក និងប្រាក់ផ្ញើមកផ្ទះ អាចកាត់បន្ថយអត្រាភាពក្រីក្របាន ៣% (Roth et al. 2013)។ នៅឡាវ ប្រាក់ផ្ញើមកផ្ទះ ជាពិសេសពីប្រទេសថៃ បានជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ (Southichack 2013)។

ចំណាកស្រុក មិនមែនផ្តល់តែផលវិជ្ជមានទាំងអស់នោះទេ៖ ការបាត់បង់កម្លាំងពលកម្មសម្រាប់ផលិតកម្មកសិកម្ម កង្វះការគ្រប់គ្រង និងថែទាំកូនៗ នៅឯស្រុក និងចំណងបំណុលរឹតរួត អាចប៉ះពាល់អាក្រក់ទៅលើគ្រួសារ និងសហគមន៍របស់ពលករចំណាកស្រុក។ ការខាតបង់ គេមិនសូវនិយាយដល់មួយនៃចំណាកស្រុក ចំពោះគ្រួសារ ឬសហគមន៍របស់សាមីជន គឺការថយចុះកម្លាំងពលកម្ម សម្រាប់គ្រួសារប្រកបមុខរបរខ្លួនឯង (កសិកម្ម និង មិនមែនកសិកម្ម) និងសម្រាប់សហគមន៍ទាំងមូល (Roth et al. 2014)។ ជារឿយៗ នៅពេលពលករចំណាកស្រុក ជាពិសេសពលករជាស្ត្រី ទៅធ្វើការនៅក្រៅប្រទេស ពួកគេទុកកូនឲ្យឪពុកម្តាយ ឬសាច់ញាតិជួយមើលថែទាំ។ កូនៗទុកនៅឯស្រុកទាំងនេះ ទទួលបានការគ្រប់គ្រង និងថែទាំតិចជាងមុន ហើយពេលខ្លះត្រូវក្លាយជាកុមារធ្វើពលកម្មទៀតផង។ ភស្តុតាងក្នុងការសិក្សានាពេលថ្មីៗរបស់ Hing et al. (2014) បង្ហាញថា កូនៗក្នុងគ្រួសារអ្នកធ្វើចំណាកស្រុក មានប្រូបាប៊ីលីតេនៃការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ២៧% ខ្ពស់ជាងកូនៗក្នុងគ្រួសារអ្នកមិនធ្វើចំណាកស្រុក។ ទោះបីគេរកឃើញថា ចំណាកស្រុកពុំមានផលប៉ះពាល់ធ្ងន់ធ្ងរ ទៅលើអត្រាទទួលបានវ៉ាក់សាំងរបស់កុមារក្តី ក៏វាពិតជាជះឥទ្ធិពលទៅលើសុខភាពកុមារ ដូចអាចមើលឃើញតាមរយៈ កំណើនករណីមានរបួស ការឈឺថ្កាត់ និងកង្វះអាហារូបត្ថម្ភ។ នៅវៀតណាម ជាទូទៅពលករចំណាកស្រុកត្រូវខ្ចីលុយពីសាច់ញាតិ មិត្តភក្តិ ឬធនាគារ សម្រាប់បង់ឲ្យក្រុមហ៊ុនបញ្ជូនពលករ និងឈ្មួញកណ្តាល ដើម្បីបានចេញទៅធ្វើការ។ បើសិនពួកគេមិនបានការងារធ្វើនៅក្រៅប្រទេស ឬត្រូវត្រឡប់មកវិញមុនពេលកំណត់នោះ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃប្រាក់កម្ចីនេះ អាចធ្ងន់ធ្ងរណាស់ (Lee and Mont 2014)។

## សន្និដ្ឋាន

ការបូកសរុបសង្ខេបលើការសិក្សាមានស្រាប់សំខាន់ៗ ស្តីពីចំណាកស្រុកក្នុង GMS ផ្តល់នូវការយល់ដឹងស៊ីជម្រៅមួយចំនួន។ ទី១ ស្ត្រីបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ នៅក្នុងសន្ទុះនិងនិន្នាការចំណាកស្រុក។ ពិនិត្យតាមលក្ខខណ្ឌសេដ្ឋកិច្ច និងប្រជាសាស្ត្រមានស្រាប់ និន្នាការនេះរំពឹងថា នឹងបន្តទៅមុខទៀត។ បញ្ហាចោទ គឺជារឿយៗ ពុំមានគោលនយោបាយចំណាកស្រុក ឬកម្មវិធីអន្តរាគមន៍ជាក់លាក់ សម្រាប់ជួយដល់ពលករស្ត្រីចំណាកស្រុកនោះទេ និងមានការសិក្សាតិចតួចណាស់ដែលផ្តោតលើបញ្ហាជាក់លាក់ប៉ះពាល់លើពួកគេ។ ទី២ ការគ្រប់គ្រង និងកិច្ចការពារពលករចំណាកស្រុក ទាំងនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួលពលករ មិនទាន់មានប្រសិទ្ធភាពទេ។ ពលករចំណាកស្រុក ត្រូវជួបបញ្ហានៅគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុក៖ មុនពេលចេញដំណើរ នៅកន្លែងធ្វើការ និងនៅពេលត្រឡប់មកវិញ។ ចំណាកស្រុកខុសច្បាប់ដែលមានច្រើនលើសលុបនេះ អាចបង្កើនហានិភ័យនិងភាពងាយរងគ្រោះនៃពលករចំណាកស្រុក ជាពិសេសពលករស្ត្រី។ ទី៣ ទោះបីចំណាកស្រុកមានផលប៉ះពាល់អវិជ្ជមាន ដូចជា ការថយចុះកម្លាំងពលកម្មនៅក្នុងគ្រួសារ និងសហគមន៍របស់ពលករចំណាកស្រុក, ការឃ្លាតពីគ្រួសារនិងកូនៗ និងការរំលោភបំពានពីសំណាក់អ្នកជ្រើសរើសឬថៅកែក្តី ក៏វានៅតែមានផលប្រយោជន៍ច្រើនដែរ។ ចំណាកស្រុកជះឥទ្ធិពលវិជ្ជមានលើការអភិវឌ្ឍ។ ទី៤ លំហូរចំណាកស្រុក ជាពិសេស ចំណាកស្រុករបស់ពលករមានជំនាញទាបនៅក្នុង GMS បានកើនឡើងជាខ្លាំង ប៉ុន្តែកំណើននេះកើតមានឡើង ដោយមានស្ថាប័ន និងបទបញ្ញត្តិក្នុងតំបន់តិចតួចគ្រប់គ្រង។ ដូច្នេះហើយ ក៏មានឧបសគ្គ និងបញ្ហាជាច្រើនផុសឡើងជាមួយគ្នានោះដែរ។

## ឯកសារយោង


ADB, Asian Development Bank. 2013. *Facilitating Safe Labor Migration in the Greater Mekong Subregion: Issues, Challenges and Forward-Looking Interventions*. Manila: ADB.

Ahsan, Ahmad, Manolo Abella, Andrew Beath, Yukon Huang, Manjula Luthria and Trang Van Nguyen. 2014. *International Migration and Development in East Asia and the Pacific*. Washington, DC: World Bank.

Caouette, Therese, Rosalia Sciortino, Philip Guest and Alan Feinstein. 2007. *Labour Migration in the Greater Mekong Subregion.* Bangkok: The Rockefeller Foundation.

CDRI, Cambodia Development Resource Institute. 2009. *Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study*. Working Paper Series No. 47. Phnom Penh: CDRI.

CLEC, LICADHO, LSCW,HRW, Community Legal Education Center, Cambodian League for the Promotion and Defense of Human Rights, Legal Support for Children and Women, and Human Rights Watch. n.d. "Cambodia: Joint Submission on Human Trafficking for Labour Exploitation." Accessed 16 January 2015. www.licadho-cambodia.org/reports/files/188Document-UPR2013-LICADHO_CLEC_LSCW_HRW.pdf.

Hing Vutha, Pide Lun and Dalis Phann. 2013. "Irregular Migration from Cambodia: Characteristics, Challenges and Regulatory Approach." *Phillipine Journal of Development* XXXVIII (1,2): 1-25.

Hing Vutha, Pide Lun and Dalis Phann. 2014. "The Impacts of Adult Migration on Children's Well-being: The Case of Cambodia." Final Report. Phnom Penh: Cambodia Development Resource Institute. Accessed 16 January 2015. www.cdri.org.kh/webdata/download/otherpapers/Migration%20and%20child%20well-being_CDRI.pdf.

Hing Vutha and Vouch Cheng Ly. 2014. "Policy Priorities to Better Manage Migration in Cambodia". Unpublished.

ILO, International Labour Organisation. n.d. *Tripartile Action to Protect Migrants within and from the GMS from Labour Exploitation* (TRIANGLE). Bangkok: ILO.

IOM, International Organization for Migration. 2011. *Thailand Migration Report*. Bangkok: IOM.

Jalilian, Hossein, ed. 2012. *Costs and Benefits of Cross-Country Labour Migration in the GMS*. GMS Development Series 2. Singapore: Institute of Southeast Asian Studies.

Lee, Nguyen Huyen, and Daniel Mont. 2014. "Vietnam's Regulatory, Institutional and Governance Structure for International Labor Migration." In *Managing International Migration for Development in East Asia*, edited by Richard H. Adams Jr. and Ahmad Ahsan, 199-219. Washington, DC: World Bank.

Lewis, Daniel Ray, Nuarpear Lekfuangfu, Irena Vojackova-Sollorano, Federico Soda and Claudia Natali. 2010. *Forecasting Migration Flows: The Relationships among Economic Development, Demographic Change and Migration in the Greater Mekong Subregio*n. Geneva: IOM and ADB.

Naro Neth. 2009. *Human Trafficking in Cambodia: Reintegration of the Cambodian Illegal Migrants from Vietnam and Thailand*. Working Paper No. 181. Singapore: S. Rajaratnam School of International Studies.

Ratha, Dilip, Sanket Mohapatra and Elina Scheja. 2011. *Impact of Migration on Economic and Social Development: A Review of Evidence and Emerging Issues.* World Bank Policy Research Working Paper Series. Washington, DC: World Bank.

Roth Vathana, Vutha Hing, Dalis Phann and Sreymom Sum. 2014. "Estimating the Economic Effects of Emigration and Remittances on the Left-Behind in Cambodia." Final Report. Dakar: Partnership for Economic Policy.

Southichack, Mana. 2013. *Lao Labor Migration and Remittance: Trends and Economic and Livelihood Implications*. Vientiane: Swiss Agency for Development and Cooperation.

World Bank. 2006. *Labour Migration in the Greater Mekong Sub-region – Synthesis Report: Phase 1.* Washington, DC: World Bank.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពិពណ៌នាពីសូចនាករសេដ្ឋកិច្ចមួយចំនួននៃប្រទេសមានសេដ្ឋកិច្ចធំៗក្នុងពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានគន់គូរថា កំណើនសកលមានអត្រា ៣,៣% នៅឆ្នាំ២០១៤។ ទោះជាយ៉ាងនេះក្ដី ក៏មានសញ្ញា និងការបារម្ភនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង អំពីលទ្ធផលសម្រេចបានមិនស្មើគ្នា ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច ដែលបន្តធ្វើឲ្យអាប់អួរដល់អនាគតនៃកំណើនសកល។

នៅត្រីមាសទី៤ កំណើន ផសស ពិត នៅម៉ាឡេស៊ី ឡើងដល់ ៥,៨% ធៀបនឹង ៥,១% កាលពីឆ្នាំមុន។ កំណើន ផសស ពិត នៅសិង្ហបុរី ចុះខ្សោយមកត្រឹម ២,១% ធៀបនឹង ៥,៥% កាលពីឆ្នាំមុន។ កំណើន ផសស ពិត នៅឥណ្ឌូនេស៊ី ធ្លាក់ចុះបន្តិចមកត្រឹម ៥,៤%។ នៅត្រីមាសទី៤ កំណើន ផសស ពិត នៅថៃ ឡើងដល់ ២,២% ធៀបនឹង ០,៤% កាលពីឆ្នាំមុន។ ការធូរស្រាលមកវិញនៃភាពតានតឹងផ្នែកនយោបាយ បានរួមចំណែកធ្វើឲ្យបរិយាកាសពាណិជ្ជកម្ម មានលំនឹង និងទំនុកចិត្ត។ ស្ថិរភាពនយោបាយនៅថៃ ក៏មានផលប្រយោជន៍ដល់ប្រទេសជិតខាងដែរ ដូចជា ការធ្វើចំណាកស្រុករបស់ពលករមានជំនាញទាប ពី កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ជាដើម។

កំណើនសេដ្ឋកិច្ចនៅប្រទេសចិន និងប្រទេសនៅអាស៊ីខាងកើតដទៃទៀត ដូចជា ហុងកុង កូរ៉េខាងត្បូង និងតៃវ៉ាន់ នៅតែខ្លាំងក្លា ទោះបីវាយឺតជាងមុនក្ដី។ ក្នុងត្រីមាសទី៤ កំណើន ផសស ពិត នៅប្រទេសចិន និងហុងកុង ធ្លាក់ចុះបន្តិច មកត្រឹម ៧,៣% និង ២,២% រៀងគ្នា។ កំណើននៅកូរ៉េខាងត្បូង ថយចុះមកត្រឹម ២,៨% ប៉ុន្តែកំណើននៅ តៃវ៉ាន់ ឡើងដល់ ៣,៣%។

នៅត្រីមាសទី៤ កំណើនជាមធ្យមនៅក្នុងបណ្ដាប្រទេសឧស្សាហកម្ម បានថយចុះ ដោយសារតែភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះ ផុសចេញពីបំណុលដ៏ខ្ពស់ និងតម្រូវការក្នុងស្រុកចុះខ្សោយក្នុងតំបន់ចាយប្រាក់អឺរ៉ូ។ បញ្ហាបំណុលរបស់ប្រទេសក្រិក បន្តបន្ថែមភាពស្មុគស្មាញកាន់តែច្រើន ដល់តំបន់នេះ។ នៅត្រីមាសទី៤ កំណើននៅសហរដ្ឋអាមេរិក ធ្លាក់ចុះបន្តិចមកត្រឹម ២,៤% ធៀបនឹង ២,៥% កាលពីឆ្នាំមុន ប៉ុន្តែទីផ្សារការងារនៅសហរដ្ឋអាមេរិក នៅតែមានដំណើរការល្អក្នុងឆ្នាំ ២០១៤ ដោយបានបង្កើត ៣,១ លានការងារមិនមែនកសិកម្មថែមទៀត (ជាមធ្យម ២៦០.០០០/ខែ)។ ការធ្វើអន្តរាគមន៍ផ្នែករូបិយវត្ថុដើម្បីជួយទ្រទ្រង់ អាចជាកត្តាពន្យល់ពីស្ថានភាពដូចបានសង្កេតឃើញ ទោះមានការវាយស្មានពីការកាត់បន្ថយសាច់ប្រាក់ដោយធនាគារកណ្ដាលសហរដ្ឋអាមេរិក ដើម្បីគ្រប់គ្រងលើអតិផរណាជំរុញដោយការផ្គត់ផ្គង់រូបិយវត្ថុក្ដី។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលខ្លី ហាក់បីដូចជាមិនមានការកាត់បន្ថយភ្លាមៗ ដោយធនាគារកណ្ដាលសហរដ្ឋអាមេរិកនោះទេ។ នៅត្រីមាសទី៤ កំណើននៅជប៉ុន ធ្លាក់ចុះមកត្រឹម ០,៥% ធៀបនឹង ២,៦% កាលពីឆ្នាំមុន។ IMF បានគន់គូរថា ប្រទេសជប៉ុន នឹងមានកំណើនមិនខ្លាំងទេនៅឆ្នាំសារពើពន្ធ ២០១៤-១៥ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

អត្រាអតិផរណាក្នុងប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង និងប្រទេសអភិវឌ្ឍន៍ ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ហើយនៅក្នុងប្រទេសអ្នកមានខ្លះ វាទាបជាងការរំពឹងទុក។ ប្រទេសមួយចំនួនកំពុងប្រឹងប្រែងប្រយុទ្ធនឹងអតិផរណា។

អតិផរណានៅកម្ពុជាថយចុះមកត្រឹម ២,២% ធៀបនឹង ៤,៣% កាលពីឆ្នាំមុន ហើយនៅឥណ្ឌូនេស៊ី វាធ្លាក់មកត្រឹម ៦,៥% ធៀបនឹង ៨,៤% កាលពីឆ្នាំមុន។ សិង្ហបុរី មានបរិត្តផរណាដល់ ០,២%។ ប្រទេសជប៉ុនរួចផុតពីបរិត្តផរណាកាលពីត្រីមាសទី៤ ឆ្នាំ២០១៤។ គេសង្ឃឹមថា គោលនយោបាយបង្កើនរូបិយវត្ថុ និងបង្កើនហិរញ្ញវត្ថុដ៏ខ្លាំងក្លា ណែនាំដោយនាយករដ្ឋមន្ត្រី Abe គឺអាចបំបាត់បរិត្តផរណាបាន។ អត្រាអតិផរណាក៏មានកម្រិតទាបដែរនៅប្រទេសចិន និងប្រទេសខ្លាអាស៊ីដទៃទៀត។ បើសិនមានការចាំបាច់ អត្រាអតិផរណានៅប្រទេសចិននេះអាចទុកលទ្ធភាពច្រើន សម្រាប់ការអនុវត្តគោលនយោបាយបង្កើនរូបិយវត្ថុជាផ្នែកមួយនៃយុទ្ធសាស្ត្រជំរុញកំណើន។ អតិផរណានៅតំបន់ចាយប្រាក់អឺរ៉ូ និងនៅសហរដ្ឋអាមេរិក បន្តមានកម្រិតទាប ដែលបង្ហាញថា គោលនយោបាយសម្រួលបរិមាណសាច់ប្រាក់ II មិនទាន់មានឥទ្ធិពលខ្លាំងទៅលើកម្រិតថ្លៃសរុបទេ ហើយការកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុ ក៏មិនទាន់គួរចាប់ផ្ដើមអនុវត្តដែរ។

នៅត្រីមាសទី៤ ប្រាក់រៀល ធ្លាក់ថ្លៃ ១,៣% ទល់នឹង ប្រាក់ដុល្លារ ធៀបនឹងឆ្នាំមុន មកត្រឹម ៤០៧០,១រៀល/ដុល្លារ។ ប្រាក់បាតថៃ ធ្លាក់ថ្លៃ ៣,៥% ទល់នឹងប្រាក់ដុល្លារ ធៀបនឹងឆ្នាំមុន ហើយប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ១,០%។ ប្រាក់យ៉ន់ចិន នៅតែគ្មានប្រែប្រួល បើធៀបនឹងឆ្នាំមុន ប៉ុន្តែ ប្រាក់យ៉េនជប៉ុន ធ្លាក់ថ្លៃ ១៤% ទល់នឹងប្រាក់ដុល្លារ មកត្រឹម ១១៤,៦យ៉េន/ដុល្លារ ដែលគួរតែបានបង្កើនថែមទៀតនូវ ភាពប្រកួតប្រជែងនៃទំនិញនាំចេញរបស់ប្រទេសជប៉ុន។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៤ ទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោកបានធ្លាក់ថ្លៃ ធៀបនឹងឆ្នាំមុន។ ពោត ធ្លាក់ថ្លៃ ១៣% មកត្រឹម ១៧៣,៣ ដុល្លារ/តោន, ប្រេងឆា ធ្លាក់ថ្លៃ ២០,៥% មកត្រឹម ៧១៣,៣ដុល្លារ/តោន, កៅស៊ូ ធ្លាក់ថ្លៃ ៣៥,៤% មកត្រឹម ១៥៣៨,១ដុល្លារ/តោន។ អង្ករ ធ្លាក់ថ្លៃ ៥,៦% និងសណ្ដែកសៀង ធ្លាក់ថ្លៃ ២០,៥%។ ប្រេងឆៅ ធ្លាក់ថ្លៃ ៣១% មកត្រឹម ៧៣,៤ដុល្លារ/ធុង ហើយរួមចំណែកធ្វើឲ្យថ្លៃសាំង និងម៉ាសូតធ្លាក់ចុះ ២៦,៥% និង ២៧,៨% រៀងគ្នា។ ការធ្លាក់ថ្លៃទំនិញទាំងនេះ ពិតជាបានផ្ដល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ក្នុងប្រទេសដែលធ្វើការនាំចូល តែបានធ្វើឲ្យខាតបង់ដល់បណ្ដាប្រទេសនាំចេញផលិតផលដើម។

---

អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 0.1 | 6.0 | 6.1 | 6.2 | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 4.2 | 6.2 | 6.5 | 6.3 | 6.0 | 5.8 | 5.6 | 5.7 | 5.2 | 5.1 | 5.0 | 5.4 |
| ម៉ាឡេស៊ី | -2.4 | 9.0 | 4.9 | 5.4 | 4.1 | 4.3 | 5.0 | 5.1 | 6.2 | 6.4 | 5.6 | 5.8 |
| សិង្ហបុរី | -4.5 | 14.7 | 4.7 | 1.3 | 0.2 | 3.7 | 5.8 | 5.5 | 5.1 | 2.4 | 2.4 | 2.1 |
| ថៃ | 3.3 | 7.9 | 0.0 | 6.7 | 5.4 | 2.6 | 2.6 | 0.4 | 3.1 | 0.3 | 0.6 | 2.2 |
| វៀតណាម | 4.7 | 6.7 | 6.1 | 5.0 | - | - | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.5 | 7.8 | 7.7 | 7.1 | 7.5 | 7.3 | 7.3 |
| ហុងកុង | -3.2 | 6.9 | 4.9 | 2.9 | 2.8 | 3.3 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 |
| កូរ៉េខាងត្បូង | -1.0 | 6.1 | 3.6 | 2.1 | 1.5 | 2.3 | 3.3 | 4.0 | 4.1 | 3.5 | 3.2 | 2.8 |
| តៃវ៉ាន់ | -3.6 | 11.1 | 4.2 | 1.2 | 1.7 | 2.3 | 1.7 | 2.9 | 3.1 | 3.7 | 3.8 | 3.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -3.8 | 1.6 | 1.6 | -0.5 | 1.1 | -0.7 | -0.4 | 0.5 | 0.9 | 0.7 | 0.3 | 0.9 |
| ជប៉ុន | -5.4 | 4.1 | -0.8 | 1.7 | 0.4 | 0.9 | 2.7 | 2.6 | 3.1 | -0.1 | -1.2 | 0.5 |
| សហរដ្ឋអាមេរិក | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 1.4 | 1.6 | 2.5 | 2.3 | 2.6 | 2.3 | 2.4 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៤ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | -0.5 | 4.1 | 5.5 | 3.0 | 1.5 | 2.2 | 3.8 | 4.3 | 4.5 | 4.9 | 4.0 | 2.2 |
| ឥណ្ឌូណេស៊ី | 4.7 | 5.1 | 5.4 | 4.3 | 5.3 | 5.7 | 8.6 | 8.4 | 7.7 | 7.1 | 4.3 | 6.5 |
| ម៉ាឡេស៊ី | 0.4 | 1.7 | 3.2 | 1.7 | 1.4 | 1.8 | 2.2 | 3.0 | 3.5 | 3.3 | 3.0 | 2.8 |
| សិង្ហបុរី | 0.5 | 2.9 | 5.2 | 4.6 | 3.6 | 1.6 | 1.8 | 2.0 | 1.0 | 2.3 | 0.9 | -0.1 |
| ថៃ | -0.9 | 3.1 | 3.8 | 3.0 | 3.1 | 2.3 | 1.7 | 1.7 | 2.0 | 2.5 | 2.0 | 1.1 |
| វៀតណាម | 7.3 | 9.0 | 18.6 | 9.3 | 6.9 | 6.6 | 7.0 | 5.9 | 4.8 | 4.7 | 4.5 | 5.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | -0.8 | 3.2 | 5.4 | 2.7 | 2.4 | 2.4 | 2.8 | 2.9 | 2.1 | 2.2 | 2.0 | 1.5 |
| ហុងកុង | -0.3 | 2.4 | 5.3 | 4.1 | 2.2 | 4.0 | 5.3 | 4.3 | 4.1 | 3.6 | 4.9 | 5.0 |
| កូរ៉េខាងត្បូង | 2.8 | 3.0 | 4.4 | 2.1 | 1.4 | 1.1 | 1.2 | 0.9 | 1.1 | 1.6 | 1.4 | 1.0 |
| តៃវ៉ាន់ | -1.1 | 1.0 | 1.4 | 1.9 | 1.8 | 0.8 | 0.0 | 0.5 | 1.1 | 1.6 | 1.5 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.4 | 1.6 | 2.7 | 2.5 | 1.8 | 1.5 | 1.3 | 0.6 | 0.6 | 0.6 | 0.4 | 0.2 |
| ជប៉ុន | -1.3 | -0.7 | 0.1 | -0.03 | -0.3 | -0.3 | 0.9 | 1.4 | 1.5 | 3.6 | 3.4 | 2.6 |
| សហរដ្ឋអាមេរិក | -0.4 | 1.7 | 3.2 | 2.1 | 1.7 | 1.4 | 1.6 | 1.2 | 1.4 | 2.1 | 1.8 | 1.3 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4140.5 | 4187.1 | 4063.6 | 4037.8 | 3995.0 | 4032.9 | 4062.0 | 4018.9 | 3993.8 | 4026.9 | 4059.5 | 4070.1 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 10,413.8 | 9089.9 | 4374.0 | 9363.0 | 9681.9 | 9783.6 | 10,666.0 | 11,545.1 | 11,765.8 | 11,615.3 | 11,775.7 | 12,244.1 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.0 | 3.2 | 3.2 | 3.3 | 3.2 | 3.2 | 3.4 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.3 | 1.3 | 1.3 |
| ថៃ (បាត) | 34.3 | 31.7 | 30.5 | 31.1 | 29.8 | 29.9 | 31.4 | 31.7 | 32.6 | 32.4 | 32.1 | 32.7 |
| វៀតណាម (ដុង) | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 20,870.8 | 20,952.5 | 21,027.4 | 21,110.5 | 21,093.8 | 20,923.2 | 21,221.9 | 21,314.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.8 | 6.8 | 6.5 | 6.3 | 6.2 | 6.2 | 6.1 | 6.1 | 6.1 | 6.2 | 6.2 | 6.1 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1277.8 | 1156.3 | 1108.6 | 1126.6 | 1085.9 | 1123.4 | 1108.8 | 1062.0 | 1069.7 | 1028.9 | 1027.5 | 1088.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.0 | 31.3 | 29.4 | 29.6 | 29.5 | 29.9 | 29.9 | 29.6 | 30.3 | 30.1 | 30.0 | 30.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.8 | 0.7 | 0.7 | 0.7 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 93.6 | 87.8 | 79.9 | 79.8 | 92.3 | 98.8 | 98.9 | 100.5 | 102.8 | 102.1 | 104.0 | 114.6 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៩-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - USA (USD/តោន) | 167.3 | 167.3 | 291.4 | 296.5 | 305.2 | 291.4 | 246.2 | 199.3 | 209.6 | 214.7 | 174.8 | 173.3 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 686.8 | 834.7 | 1125.4 | 999.3 | 852.7 | 850.3 | 827.3 | 897.3 | 911.3 | 887.3 | 770.7 | 713.3 |
| កៅស៊ូ SMR 5 (USD/តោន) | 1884.8 | 3152.2 | 4630.6 | 3200.7 | 3029.5 | 2497.2 | 2394.6 | 2380.0 | 2034.7 | 1777.6 | 1672.1 | 1538.1 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 524.5 | 456.2 | 558.5 | 594.8 | 607.0 | 570.0 | 502.3 | 455.7 | 450.7 | 411.7 | 447.0 | 430.3 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 414.0 | 375.4 | 507.9 | 566.1 | 558.4 | 569.8 | 545.1 | 514.9 | 533.0 | 565.7 | 463.0 | 409.3 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 60.5 | 71.6 | 106.2 | 109.5 | 109.5 | 100.9 | 106.9 | 106.4 | 104.7 | 105.9 | 100.8 | 73.4 |
| សាំង - US Gulf Coast (សេន/លីត្រ) | 42.9 | 49.8 | 71.9 | 74.6 | 74.8 | 71.2 | 73.3 | 65.7 | 70.1 | 74.1 | 70.0 | 48.3 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 75.7 | 83.8 | 77.8 | 80.7 | 80.3 | 81.5 | 75.6 | 79.6 | 77.5 | 77.1 | 73.7 | 57.5 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី៤ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ធ្លាក់ចុះ ៧៦% ធៀបត្រីមាសមុន ឬ ៩១,៥% ធៀបឆ្នាំមុន មកត្រឹម ១៤៩,៩លានដុល្លារ។ វិនិយោគក្នុងអនុវិស័យកាត់ដេររួមចំណែក ២០,២% នៃគម្រោងវិនិយោគក្នុងវិស័យឧស្សាហកម្ម។ វិនិយោគក្នុងវិស័យកសិកម្មពុំឃើញមានទេ ដូច្នេះនៅមានការងារត្រូវធ្វើច្រើនទៀត ដើម្បីទាក់ទាញវិនិយោគិន ព្រោះកសិកម្មជាវិស័យសំខាន់មួយ សម្រាប់ជំរុញកំណើនជារួម និងបង្កើតការងារ ជាពិសេសសម្រាប់គ្រួសារនៅតំបន់ជនបទ។ វិស័យកសិកម្មខ្លាំង និងមានផលិតភាពខ្ពស់ ក៏ជាកត្តាជំរុញសំខាន់មួយ សម្រាប់ការកាត់បន្ថយភាពក្រីក្រនៅទីជនបទដែរ។ ក្នុងត្រីមាសនេះ មិនមានការធ្វើនិយោគខាងផ្នែកសណ្ឋាគារ និងទេសចរណ៍ទេ។

នៅឆ្នាំ២០១៤ ភ្ញៀវទេសចរមកដល់កម្ពុជាសរុប កើន ៦,៩% ធៀបឆ្នាំមុន ដល់ ៤,៥លាននាក់។ នៅត្រីមាសទី៤ ឆ្នាំ២០១៤ ភ្ញៀវទេសចរមកដល់កម្ពុជា កើន ១៣,០% ធៀបមួយឆ្នាំមុន ហើយក្នុងនោះភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១០,១% និងភ្ញៀវមកដល់តាមផ្លូវគោក ឬផ្លូវទឹក កើន ១៥,៩%។ វិស័យទេសចរណ៍កំពុង និងរំពឹងថានឹងរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ហើយការដាក់បញ្ចូលវិស័យនេះទៅក្នុងការអភិវឌ្ឍសហគមន៍ ជាកត្តាសំខាន់មួយសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍតំបន់ទេសចរណ៍ប្រកបដោយចីរភាព។

សូចនាករសំខាន់ៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក បង្ហាញថា នៅឆ្នាំ២០១៣ សេវាកម្មរួមចំណែក ៤០,១% ក្នុង ផសស របស់កម្ពុជា ហើយបន្ទាប់មកគឺកសិកម្ម (៣៥,៦%) និង ឧស្សាហកម្ម (២៤,៣%)។ អត្រារួមចំណែករបស់វិស័យសេវាកម្មនៅកម្ពុជា វាខ្ពស់ជាងនៅប្រទេសសមាជិកអាស៊ានឯទៀត ដូចជា ប្រ៊ុយណេ (២៨,២%), ឥណ្ឌូនេស៊ី (២៨,៦%), ឡាវ (៣៩,៣%) និង មីយ៉ាន់ម៉ា (៣៧,៥%)។

នៅត្រីមាសទី៤ ការនាំចេញសរុបនៅខ្លាំងក្លាដដែលដោយកើន ១៧,៧% ធៀបមួយឆ្នាំមុន ដល់ ២,១ពាន់លានដុល្លារ។ សម្លៀកបំពាក់នៅតែជាក្បាលម៉ាស៊ីននៃការនាំចេញ ដោយរួមចំណែក ៧០% នៃតម្លៃនាំចេញសរុប។ ហេតុនេះ ពិពិធកម្មផលិតផលនាំចេញ នៅតែជាអាទិភាពមួយសម្រាប់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ។ ការចាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥ នាពេលឆាប់ៗខាងមុខ ជាជំហានមួយទៀតក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងកម្មសិទ្ធិរឹងមាំ គឺជាកត្តាដ៏សំខាន់បំផុតមួយ។ ក្របខ័ណ្ឌគោលនយោបាយនានាសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទើបតាក់តែងឡើង ដោយមានជំនួយទ្រទ្រង់ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន គឺជាចំណាត់ការមួយផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាផលិតភាពទាប និងមូលដ្ឋានតូចចង្អៀតនៃសេដ្ឋកិច្ចកម្ពុជា។ សម្លៀកបំពាក់ កម្ពុជានាំចេញជាចម្បងទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលមានចំណែក ៧៤,២% នៃតម្លៃនាំចេញសរុប។ ពិពិធកម្មទីផ្សារនាំចេញ គឺជាការងារមួយទៀត។ វិស័យកសិកម្ម រួមចំណែក ៣៥,៦% ក្នុង ផសស ឆ្នាំ២០១៣ ប៉ុន្តែមានចំណែកត្រឹមតែ ៧,៨% ប៉ុណ្ណោះ នៃការនាំចេញសរុបនៅត្រីមាសទី៤ ឆ្នាំ២០១៤។ ផលិតផលនាំចេញចម្បងៗរួមមាន កៅស៊ូ ឈើ ត្រី និងអង្ករ។ តម្លៃនាំចេញកៅស៊ូធ្លាក់ចុះ ៧,០% ធៀបឆ្នាំមុន ដោយសារជាសំខាន់ការធ្លាក់ថ្លៃកៅស៊ូអន្តរជាតិ។ តម្លៃនាំចេញអង្ករ ធ្លាក់ចុះ ០,៨% មកត្រឹម ៨២ លានដុល្លារ។

នៅត្រីមាសទី៤ ការនាំចូលសរុប កើន ៣១,៨% ធៀបឆ្នាំមុន ដល់ ២,៨ពាន់លានដុល្លារ ក្នុងនេះការនាំចូលម៉ាស៊ូត រួមចំណែក ៥,៣% សាំង ៣,៣% និង សម្ភារសំណង់ ១,១%។ ឱនភាពពាណិជ្ជកម្ម កើនដល់ ៦៧០,៨លានដុល្លារ ធៀបនឹង ៣១៤,៧លានដុល្លារ កាលពីឆ្នាំមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ចំណូលរដ្ឋាភិបាលសរុប កើន ២៤,៩% ធៀបឆ្នាំមុន ដល់ ២៩៤៨,៦ពាន់លានរៀល (៧២៤លានដុល្លារ) ក្នុងនេះ ចំណូលចរន្ត រួមចំណែក ៩៥% ។ នៅឆ្នាំ២០១៤ ចំណូលសរុប កើន ២៧,៧% ធៀបនឹងឆ្នាំ២០១៣។ ចំណូលពន្ធ រួមចំណែក ៨៤% ក្នុងចំណូលចរន្តសរុប ឬកើនបាន ២០,៩% បើធៀបនឹងឆ្នាំមុន ដល់ ២៣៥៨,៨ពាន់លានរៀល (៥៧៩លានដុល្លារ)។ នៅត្រីមាសទី៤ នេះដែរ ចំណាយសរុប កើន ៧,៨% ដែលបណ្តាលជាចម្បងពីកំណើន ២៤,៨% នៃចំណាយចរន្ត ធៀបនឹងឆ្នាំមុន។ ចំណាយលើបៀវត្សរ៍រួមចំណែក ៣៦,៣% នៃចំណាយចរន្តសរុប ហើយឧបត្ថម្ភធន និងជំនួយសង្គមផ្សេងទៀត រួមចំណែក ២៤,៩%។ ចំណាយមូលធនធ្លាក់ចុះ ១៣,៦% ។ ឱនភាពថវិកា ធ្លាក់ចុះដល់ ៥២២,៨ពាន់លានរៀល ធៀបនឹង ១៧៨៥,២ពាន់លានរៀល កាលពីឆ្នាំមុន។ ការកែលំអការប្រមូលចំណូល និងការកាត់បន្ថយចំណាយខ្ជះខ្ជាយ នៅតែស្ថិតក្នុងរបៀបវារៈកំណែទម្រង់របស់រដ្ឋាភិបាល។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ អតិផរណាបានធ្លាក់ចុះមកត្រឹម ២,១% ធៀបនឹង ៤,៧% កាលពីឆ្នាំមុន។ អតិផរណាសម្រាប់អាហារ និងភេសជ្ជៈគ្មានជាតិស្រា មានកម្រិត ៣,៤%។ ទោះជាអត្រាអតិផរណានេះស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្តី ក៏រដ្ឋាភិបាលត្រូវគិតគូរជានាំឲ្យបានថា បៀវត្សរ៍ចារឹកដើរទាន់គ្នានឹងកំណើន

---

អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ថ្លៃនេះ។ នៅត្រីមាសទី៤ នេះដែរ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ធៀបនឹងឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ។ ប្រាក់រៀល ឡើងថ្លៃ ៤,៧% និង ១,៥% រៀងគ្នា ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម។ ម៉ាស៊ូត ធ្លាក់ថ្លៃ ១១,០% មកត្រឹម ៤៣៨២,៨រៀល/លីត្រ ហើយសាំង ធ្លាក់ថ្លៃ ១០,០% មកត្រឹម ៤៦១៣រៀល/លីត្រ។ មាស ធ្លាក់ថ្លៃ ១៧,៩% ធៀបឆ្នាំមុន មកត្រឹម ១៤១,១ដុល្លារ/ជី។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៤ សាច់ប្រាក់ងាយស្រួលសរុប កើន ២៩,៩% ធៀបឆ្នាំមុន។ រូបិយវត្ថុ និងរូបិយវត្ថុផ្សេងៗ កើន ២៩,៣% និង ៣០,០% រៀងគ្នា។ កំណើននេះផ្តល់ផលល្អសម្រាប់អាជីវកម្ម ដូចអាចមើលឃើញតាមកំណើន ២៦,៨% នៃឥណទានផ្តល់ឲ្យវិស័យឯកជន។ ទោះយ៉ាងណាក្តី ការពិនិត្យតាមដានឲ្យបានជិតដល់ពីសំណាក់ធនាគារកណ្តាល ជាកត្តាសំខាន់ ដើម្បីចៀសវាងកំណើនមិនបានត្រៀមមុន នៃអតិផរណាក្នុងរយៈពេលវែងបង្កឡើងដោយការផ្គត់ផ្គង់រូបិយវត្ថុ។ ការបែងចែកឥណទានទៅឲ្យវិស័យឯកជន ក៏ជាកត្តាចាំបាច់ដើម្បីធានាថា ឥណទានមិនប្រមូលផ្តុំទៅលើតែអាជីវកម្មធំៗ។

## ស្ថានភាពក្រីក្រ

នៅខែកុម្ភៈ ២០១៥ ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់ពលករងាយរងគ្រោះ ក្រៅពីអ្នកស៊ីឈ្នួលធ្វើស្រែ បានកើន បើធៀបនឹងតួលេខអង្កេតក្នុងខែកុម្ភៈ ២០១៤។ ប្រាក់ចំណូលរបស់អ្នកលក់បន្លែ កម្មករសំណង់មានជំនាញ និងអ្នកបម្រើតាមភោជនីយដ្ឋាន បានធ្លាក់ចុះបើធៀបនឹងខែវិច្ឆិកា ២០១៤។

ប្រាក់ចំណូលរបស់អ្នកលក់បន្លែ ធ្លាក់ចុះ ១៤% ធៀបនឹងអង្កេតពីលើកមុន មកត្រឹម ១៥.១៨៥រៀល/ថ្ងៃ។ អ្នកផ្តល់សម្ភាសន៍ ៨៣% ប្រាប់ថា ការធ្លាក់ចុះនេះបណ្តាលជាចម្បងមកពីកំណើនចំនួនអ្នកលក់ និងការធ្វើវិនិយោគបានតិចដើម្បីបង្កើនមុខបន្លែសម្រាប់លក់។ អ្នកឆ្លើយសម្ភាសន៍ ៨២% មកពីខេត្តជិតៗ ដូចជា កណ្តាល តាកែវ និង កំពង់ចាម ក្នុងនេះ ៥៨% មកភ្នំពេញតែម្នាក់ឯង។ ក្នុងចំណោមអ្នកមកពីខេត្ត មានតែ ៥៤% ប៉ុណ្ណោះ ដែលជួលផ្ទះស្នាក់នៅ ហើយក្រៅពីនេះធ្វើដំណើរឡើងចុះវិលល្ងាចតែម្តង។ ចំណាយលើអាហារ មានចំណែក ៦០% នៃចំណាយសរុបប្រចាំថ្ងៃ និង ៤២% នៃចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែ។

នៅខែកុម្ភៈ ប្រាក់ចំណូលរបស់អ្នកបម្រើតុភោជនីយដ្ឋាន ធ្លាក់ចុះ ៩,៦% ធៀបនឹងអង្កេតលើកមុន មកត្រឹម ៨៥៦៦រៀល/ថ្ងៃ។ ពួកគេទទួលបានកន្លែងស្នាក់នៅពីម្ចាស់ភោជនីយដ្ឋាន ដូច្នេះចាយវាយអស់តែ ២០% នៃប្រាក់ចំណូល ហើយប្រាក់នៅសល់គេផ្ញើទៅផ្ទះ ប៉ុន្តែអាចផ្គត់ផ្គង់គ្រួសារបានតែមួយផ្នែកប៉ុណ្ណោះ។

ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ៦,១% មកត្រឹម ១៧.២៥១រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាសុទ្ធតែមកពីខេត្ត (៤១% មកពីព្រៃវែង) ក្នុងនេះមាន ៧៨% ប្រាប់ថា ចំណូលរបស់ខ្លួនអាចផ្គត់ផ្គង់គ្រួសារបានមួយផ្នែក ហើយ ៦៨% ត្រូវចិញ្ចឹមសត្វដើម្បីបានចំណូលបន្ថែម។ កម្មករទាំងឡាយអាចស្នាក់នៅតាមការដ្ឋានបាន ដូច្នេះមុខចំណាយចាយវាយប្រចាំថ្ងៃចម្បង គឺអាហារ (៩២% នៃចំណាយសរុប)។

ប្រាក់ចំណូលរបស់កម្មករសំណង់គ្មានជំនាញ កើន ៨,៨% ដល់ ១៦.៨៧៧រៀល/ថ្ងៃ។ កម្មករ ៦៥% ប្រាប់ថា កំណើននេះបណ្តាលជាចម្បងមកពីកង្វះកម្មករ។ អ្នកឆ្លើយសម្ភាសន៍ទាំងឡាយសុទ្ធតែមកពីខេត្ត ជាពិសេស ខេត្តព្រៃវែង និងស្វាយរៀង។ ពួកគេចំណាយអស់ ៣០% នៃចំណូលប្រចាំថ្ងៃ ហើយភាគច្រើនទៅលើអាហារ។

ប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូ កើន ១២% ធៀបនឹងអង្កេតលើកមុន ដល់ ១៣.១០៣រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៧៨% ប្រាប់ថា ដោយសារមានអ្នកធាក់ស៊ីក្លូជាច្រើននាក់ចេញទៅធ្វើការងារផ្សេងទើបមានកំណើននេះ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាជាប្រភពចំណូលចម្បងក្នុងគ្រួសារខ្លួន ប៉ុន្តែប្រាក់ចំណូលរបស់គាត់មិនអាចផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់ទេ ដូច្នេះមាន ៦៨% ត្រូវរកការងារផ្សេងទៀត និងធ្វើការចិញ្ចឹមសត្វដើម្បីរកចំណូលចិញ្ចឹមគ្រួសារ ហើយ ៤០% ត្រូវខ្ចីបុលគេ។

សម្ភាសន៍ជាមួយអ្នកស៊ីឈ្នួលធ្វើស្រែ មានធ្វើតែនៅខេត្តកំពង់ស្ពឺ និងកណ្តាល ប៉ុណ្ណោះ។ ចំណូលប្រចាំថ្ងៃពិតរបស់ពួកគេ បានកើន ២៣% ដល់ ៨៤០១រៀល/ថ្ងៃ។ ២៨% នៃអ្នកឆ្លើយសម្ភាសន៍គ្មានដីធ្លីទេ ហើយអ្នកឯទៀត មានដីកសិកម្មជាមធ្យម ០,៤ហិកតា។ ៥៨% នៃអ្នកឆ្លើយសម្ភាសន៍ប្រាប់ថា ការស៊ីឈ្នួលធ្វើស្រែចំការ មិនមែនជាប្រភពចំណូលចម្បងរបស់គាត់ទេ។ គាត់អាចរកចំណូលពីប្រភពផ្សេងទៀត ដូចជា ធនធានទ្រព្យរួម ការលក់ពលកម្មក្នុងវិស័យដទៃទៀត ជាពិសេសវិស័យសំណង់ និងការងារជំនាញផ្សេងៗ ដូចជា ខាងកាត់សក់ កាត់ដេរ និង ជួញដូរតូចតាច។

ចំណូលរបស់កម្មកររោងចក្រកាត់ដេរ កើន ២២% ដល់ ១៤.៨១៦រៀល/ថ្ងៃ ដោយសារមានការងារថែមម៉ោងច្រើនជាងមុន។ ពួកគេ ៥៥% បានរៀនចប់ថ្នាក់បឋមសិក្សា ៣៩% បានចូលរៀនថ្នាក់មធ្យមសិក្សា ហើយក្រៅពីនេះមិនបានចូលរៀនទេ។ ៧០% នៃអ្នកឆ្លើយសម្ភាសន៍ បានចូលរៀននៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលឯកជន មុនពេលចូលធ្វើការ។ ពួកគេកាត់ដេរនូវចំណែកផ្សេងៗនៃសម្លៀកបំពាក់ ដេរប៉ាក់ ត្បាញ ឬបោកអ៊ុតនៅក្នុងរោងចក្រកាត់ដេរ។ អ្នកឆ្លើយសម្ភាសន៍ ៤២% ប្រាប់ថា ចង់បន្តធ្វើការក្នុងវិស័យកាត់ដេរ ព្រោះមិនមានជំនាញអ្វីផ្សេង ឬមិនមានប្រាក់សន្សំ ហើយក្រៅពីនេះមិនដឹងថាចង់ធ្វើការងារអ្វីទេទៅថ្ងៃអនាគត។ ពួកគេមានចំណាយសរុបប្រចាំខែជាមធ្យម ២២៤.០៦៥រៀលក្នុងមួយខែ ក្នុងនេះ ៦៧% ជាចំណាយលើម្ហូបអាហារ និង ១៥% លើថ្លៃស្នាក់នៅ។

# តាមដានសេដ្ឋកិច្ច - សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៩-១៤*

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 615.0 | 530.7 | 725 | 531.6 | 2.3 | 57.8 | 133.1 | 738.3 | 28.9 | 27.6 | 0.0 | 0.0 |
| ឧស្សាហកម្ម | 818.5 | 403.7 | 2860.1 | 829.3 | 195.4 | 1928.3 | 119.5 | 1014.1 | 179.0 | 239.3 | 434.3 | 149.9 |
| *កាត់ដេរ* | 90.1 | 122.8 | 393.9 | 497 | 109.5 | 76.4 | 65.15 | 73.1 | 109.3 | 172.4 | 81.6 | 30.3 |
| សេវាកម្ម | 4432.0 | 1337.3 | 3425.4 | 916.6 | 21.2 | 106.0 | 5.3 | 8.3 | 219.1 | 114.4 | 191.5 | 0.0 |
| *សណ្ឋាគារ និងទេសចរណ៍* | 3980.1 | 1105.1 | 2850.9 | 691.5 | 0.0 | 106.0 | 0.0 | 0.0 | 163.3 | 15.4 | 268.1 | 0.0 |
| សរុប | 5865.5 | 2271.7 | 7010.42 | 2278.0 | 218.9 | 2091.1 | 257.9 | 1760.7 | 426.9 | 302.2 | 625.8 | 149.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -81.1 | 855.5 | -87.7 | 582.8 | -75.8 | -29.2 | 64.1 | -76.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -44.5 | -61.3 | 209 | -67.5 | -47.5 | 666.0 | -39.9 | 52.2 | 95.1 | -81.8 | 142.7 | -91.5 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 175.2 | 145.2 | 10.3 | 51.6 | 110.2 | 27.1 | 8.8 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 372.1 | 114.1 | 33.0 | 62.7 | 131.9 | 106.5 | 75.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 463.6 | 154.4 | 238.3 | 336.0 | 130.8 | 190.0 | 141.7 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 443.7 | 281.6 | 450.3 | 372.9 | 323.6 | 225.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 590.9 | -36.5 | 59.9 | -17.2 | -13.2 | -30.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៩-១៤

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1111.7 | 1304.3 | 1480.4 | 1722.1 | 611.2 | 398.1 | 428.0 | 580.4 | 699.0 | 438.2 | 497.5 | 638.8 |
| តាមផ្លូវគោក និងទឹក | 999.7 | 1094.6 | 1401.4 | 1862.2 | 560.9 | 522.5 | 536.6 | 572.5 | 569.0 | 495.2 | 501.2 | 663.9 |
| សរុប | 2111.5 | 2398.9 | 2881.8 | 3584.3 | 1172.1 | 920.5 | 964.6 | 1153.0 | 1268.0 | 933.4 | 998.7 | 1302.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 16.4 | -21.5 | 4.8 | 19.5 | 10.0 | -26.4 | 7.0 | 30.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 0.5 | 13.6 | 20.1 | 24.4 | 17.8 | 20.9 | 17.5 | 14.5 | 8.0 | 1.4 | 3.5 | 13.0 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៩-១៤ *

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2901.6 | 3630.2 | 4929.5 | 6106.4 | 1576.9 | 1620.1 | 1969.9 | 1815.4 | 1976.5 | 1859.8 | 2132.5 | 2137.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2565.3 | 3223.4 | 4259.6 | 5015.4 | 1225.2 | 1259.0 | 1568.5 | 1333.4 | 1464.0 | 1379.2 | 1624.7 | 1492.6 |
| - *សហរដ្ឋអាមេរិក* | 1512.6 | 1853.9 | 2055.3 | 2143.3 | 526.8 | 474.6 | 597.9 | 476.0 | 531.1 | 452.5 | 511.2 | 468.8 |
| - *សហភាពអឺរ៉ុប* | 644.7 | 809.5 | 1322.2 | 1716.9 | 397.5 | 477.5 | 572.8 | 521.9 | 532.7 | 558.5 | 673.8 | 638.7 |
| - *អាស៊ាន* | 6.9 | 9.9 | 17.6 | 39.4 | 13.0 | 12.7 | 17.4 | 17.2 | 21.9 | 19.3 | 20.5 | 21.7 |
| - *ជប៉ុន* | 44.5 | 86.5 | 147.0 | 188.6 | 57.6 | 51.4 | 98.1 | 71.6 | 101.4 | 74.9 | 117.6 | 89.2 |
| - *ប្រទេសផ្សេងៗ* | 356.5 | 463.6 | 717.5 | 927.2 | 230.3 | 242.8 | 282.4 | 247.4 | 277.0 | 273.9 | 301.6 | 274.2 |
| កសិកម្ម | 73.1 | 164.9 | 362.1 | 376.7 | 123.8 | 128.9 | 362.4 | 173.0 | 167.0 | 157.3 | 133.7 | 166.4 |
| - *កៅស៊ូ* | 51.6 | 89.1 | 197.6 | 176.6 | 36.6 | 38.7 | 282.4 | 51.1 | 31.7 | 40.0 | 34.8 | 47.5 |
| - *ឈើ* | 3.5 | 34.1 | 48.8 | 36.8 | 14.5 | 8.9 | 16.9 | 33.3 | 55.9 | 48.4 | 19.6 | 8.2 |
| - *ត្រី* | 3.9 | 2.8 | 3.1 | 2.0 | 0.3 | 0.5 | 0.2 | 0.2 | 0.3 | 0.2 | 0.1 | 0.2 |
| - *អង្ករ* | 10.9 | 34.7 | 106.6 | 146.4 | 65.8 | 56.5 | 57.3 | 82.7 | 57.9 | 52.8 | 55.8 | 82.0 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 3.0 | 4.1 | 6.0 | 14.9 | 6.6 | 24.4 | 5.7 | 5.7 | 21.2 | 16.0 | 23.5 | 28.5 |
| ផ្សេងៗ | 263.2 | 242.0 | 307.9 | 714.4 | 274.9 | 232.2 | 272.6 | 308.5 | 345.5 | 323.3 | 373.0 | 478.2 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4331.5 | 5190.6 | 6375.9 | 8593.3 | 2192.1 | 2211.4 | 2059.7 | 2130.1 | 2238.2 | 2454.4 | 2794.8 | 2807.9 |
| សាំង | 91.13 | 108.6 | 294.4 | 308.0 | 1225.2 | 77.2 | 71.3 | 80.5 | 77.4 | 83.2 | 80.2 | 93.9 |
| ម៉ាស៊ូត | 180.67 | 203.8 | 447 | 559.5 | 526.8 | 137.4 | 150.9 | 132.2 | 148.5 | 142.5 | 163.4 | 147.9 |
| សម្ភារសំណង់ | 49.74 | 57.6 | 48.1 | 66.1 | 397.5 | 17.8 | 18.0 | 17.2 | 27.8 | 29.2 | 29.0 | 31.6 |
| ផ្សេងៗ | 4010 | 4820.6 | 5586.4 | 7659.1 | 13.0 | 1979 | 1819.4 | 1899.6 | 1984.5 | 2199.5 | 2522.2 | 2534 |
| ជញ្ជីងពាណិជ្ជកម្ម | -1429.9 | -1560.5 | -1446.4 | -1341.6 | -615.2 | -591.2 | -89.8 | -314.7 | -261.7 | -589.5 | -662.3 | -670.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | 7.4 | 2.8 | 24.6 | -15.0 | 9.8 | -5.8 | 17.8 | -8.1 |
| ការនាំចេញសរុប | - | - | - | - | 8.4 | 2.7 | 21.6 | -7.8 | 8.9 | -5.9 | 14.7 | 0.2 |
| ការនាំចូលសរុប | - | - | - | - | 13.1 | 0.9 | -6.9 | 3.4 | 5.1 | 9.4 | 14.1 | 0.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | -14.1 | 25.7 | 32.1 | 17.7 | 14.4 | -14.6 | 18.0 | 16.9 | 19.5 | 9.6 | 3.6 | 11.9 |
| ការនាំចេញសរុប | -6.3 | 25.1 | 35.8 | 23.9 | 23.2 | -8.8 | 23.4 | 24.8 | 25.3 | 14.8 | 8.3 | 17.7 |
| ការនាំចូលសរុប | 1.4 | 19.8 | 22.8 | 16.8 | 36.2 | 17.3 | 2.2 | 9.9 | 2.1 | 10.8 | 35.7 | 31.8 |

* Import data include tax-exempt imports.

Sources: Department of Trade Preference Systems, Ministry of Commerce and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៩-១៤ (ពាន់លានរៀល)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 4885.2 | 5989.0 | 6251.4 | 7691.9 | 1820.2 | 2204.8 | 1868.9 | 2361.2 | 2220.5 | 2793.7 | 2580.6 | 2948.6 |
| ចំណូលចរន្ត | 4855.9 | 5859.1 | 6179.3 | 7443.8 | 1817.4 | 2241.3 | 1858.1 | 2316.3 | 2219.2 | 2765.2 | 2571.4 | 2803.6 |
| ចំណូលពន្ធ | 4268.0 | 4693.0 | 5277.5 | 6334.8 | 1577.7 | 2024.0 | 1646.0 | 1950.4 | 1988.7 | 2383.1 | 2264.6 | 2358.8 |
| ពន្ធក្នុងស្រុក | 3088.6 | 3533.6 | 4071.6 | 5002.8 | 1254.5 | 1652.9 | 1300.6 | 1520.1 | 1593.6 | 1943.2 | 1798.0 | 1891.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1064.7 | 1159.4 | 1205.9 | 1331.7 | 323.1 | 371.1 | 345.4 | 430.3 | 449.0 | 439.9 | 466.5 | 467.2 |
| ចំណូលមិនមែនពន្ធ | 702.1 | 1166.1 | 901.8 | 1118.2 | 239.8 | 217.4 | 212.2 | 365.9 | 176.6 | 382.1 | 306.9 | 444.8 |
| ចំណូលលើទ្រព្យសម្បត្តិ | 64.6 | 291.1 | 63.8 | 143.0 | 8.4 | 18.1 | 24.3 | 33.2 | 11.1 | 40.8 | 21.2 | 15.4 |
| លក់ទំនិញ និងសេវា | 408.0 | 460.1 | 588.7 | 667.4 | 153.3 | 173.3 | 178.8 | 245.0 | 160.3 | 197.5 | 212.9 | 300.5 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 228.2 | 408.9 | 249.3 | 298.8 | 78.1 | 25.9 | 9.0 | 87.7 | 5.2 | 143.7 | 72.7 | 128.9 |
| ចំណូលជាមូលធន | 29.3 | 129.9 | 72.1 | 247.9 | 6.2 | 11.5 | 10.7 | 45.0 | 1.3 | 28.5 | 9.2 | 145.0 |
| ចំណាយសរុប | 7383.5 | 8784.6 | 9032.4 | 9660.9 | 2114.8 | 3181.6 | 3093.0 | 4146.4 | 2618.8 | 2867.2 | 3349.0 | 4471.4 |
| ចំណាយជាមូលធន | 2694.9 | 2853.2 | 3546.9 | 3628.3 | 1108.4 | 1273.7 | 1350.6 | 1834.8 | 1187.1 | 1395.9 | 1421.7 | 1586.0 |
| ចំណាយចរន្ត | 4440.0 | 4773.1 | 5341.2 | 6188.4 | 1006.4 | 1907.8 | 1742.4 | 2311.6 | 1431.7 | 1471.4 | 1927.3 | 2885.4 |
| បៀវត្សរ៍ | 2012.0 | 2048.8 | 2170.6 | 2486.6 | 505.0 | 757.0 | 827.3 | 908.0 | 860.0 | 931.0 | 918.4 | 1046.1 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 871.4 | 1099.4 | 1518.8 | 1586.8 | 252.0 | 652.5 | 285.0 | 373.4 | 213.1 | 259.6 | 434.8 | 719.5 |
| ចំណាយចរន្តផ្សេងទៀត | 1556.6 | 1624.8 | 1651.8 | 2115.1 | 249.4 | 498.3 | 630.1 | 1030.2 | 358.6 | 280.8 | 574.1 | 1119.9 |
| សមតុល្យជាទូទៅ | -2498.3 | -2795.7 | -1271.4 | -1969.0 | -294.6 | -976.7 | -1224.1 | -1785.2 | -398.4 | -73.5 | -768.5 | -522.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1746.1 | 1845.2 | -2781.0 | 2457.8 | 906.0 | 1150.6 | 1032.2 | 1237.4 | 977.9 | 1123.9 | 1,012.5 | 857.9 |
| ហិរញ្ញប្បទានក្នុងស្រុក | 474.9 | 938.6 | 2379.2 | -332.9 | -470.6 | 270.3 | 113.0 | 65.8 | -915.0 | -172.9 | -279.3 | -61.4 |

Source: Ministry of Economy and Finance website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៩-១៤

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | -0.7 | 4.1 | 5.4 | 2.3 | 1.5 | 2.3 | 3.7 | 4.7 | 4.6 | 4.8 | 4.0 | 2.1 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | -0.3 | 4.4 | 6.5 | 2.5 | 1.6 | 3.3 | 4.8 | 5.8 | 5.7 | 5.3 | 5.1 | 3.4 |
| - ដឹកជញ្ជូន | -10.7 | 7.0 | 6.9 | 3.3 | -0.7 | -1.0 | -0.1 | -0.4 | -1.1 | 0.5 | -0.2 | -3.3 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4140.5 | 4187.1 | 4063.6 | 4039.2 | 3995.0 | 4033.1 | 4062 | 4059.0 | 3993.8 | 4026.9 | 4059.5 | 4064.7 |
| រៀលក្នុង ១ បាតថៃ | 121.1 | 133.1 | 133.2 | 130.0 | 134.7 | 135.74 | 131.4 | 130.7 | 123.0 | 124.8 | 127.1 | 124.6 |
| រៀលក្នុង ១០០ ដុងវៀតណាម | 23.4 | 21.7 | 19.7 | 19.4 | 19.3 | 19.34 | 19.3 | 19.4 | 19.1 | 19.2 | 19.2 | 19.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 113.1 | 147.5 | 184.5 | 200.9 | 197.3 | 173.4 | 161.1 | 171.8 | 156.6 | 155.9 | 155.5 | 141.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3170.9 | 3859.3 | 4761.2 | 4941.2 | 5134.4 | 4992 | 5022.5 | 4927 | 4971.2 | 5006.7 | 5047.6 | 4382.8 |
| ថ្លៃសាំង (រៀល/លីត្រ) | 3593.1 | 4368.1 | 5044.5 | 5312.7 | 5410.5 | 5274.5 | 5245.2 | 5126.7 | 5171.5 | 5200.0 | 5348.6 | 4613.0 |

Sources: National Institute of Statistics, National Bank of Cambodia and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៩-១៤ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 19,976.7 | 21,772.9 | 18,720.7 | 21,260.1 | 23,344.4 | 26,235.8 | 26,817.8 | 26,699.7 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1573.0 | 2778.9 | 5760.8 | 10,437.4 | 10,504.1 | 9886.1 | 10,634.8 | 11,508.3 | 11,817.4 | 12,024.4 | 13,950.5 | 15,859.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2252.0 | -2126.6 | -2123.1 | -2486.4 | -2991.6 | -3012.6 | -2804.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 |
| ឥណទានដល់ផ្នែកឯកជន | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 24,820.2 | 25,146.0 | 26,445.3 | 27,608.8 | 28,584.5 | 30,621.3 | 33,226.4 | 36,244.6 |
| រូបិយវត្ថុទូទៅ M2 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 30,480.8 | 31,659.1 | 29,355.5 | 32,768.4 | 35,161.8 | 38,259.9 | 40,768.3 | 42,559.5 |
| រូបិយវត្ថុ M1 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4500.6 | 4585.9 | 4720.8 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 |
| រូបិយវត្ថុផ្សេងៗ | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 25,980.2 | 27,073.2 | 24,634.8 | 27,890.2 | 29,785.7 | 33,028.5 | 35,185.2 | 36,251.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 36.9 | 20.0 | 17.8 | 20.9 | 22.6 | 18.8 | 9.3 | 14.6 | 15.4 | 20.8 | 38.9 | 29.9 |
| រូបិយវត្ថុ M1 | 30.1 | 3.2 | 16.9 | 2.3 | 12.9 | 18.4 | 23.6 | 20.6 | 19.5 | 14.1 | 18.3 | 29.3 |
| រូបិយវត្ថុផ្សេងៗ | 38.6 | 24.0 | 17.9 | 44.6 | 24.4 | 18.8 | 6.9 | 13.6 | 14.6 | 22.0 | 42.8 | 30.0 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | 2014 | | 2015 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 9036 | 9532 | 10,303 | 10,438 | 10,832 | 10,764 | 9867 | 11,634 | 13,103 | -7.2 | 7.8 | 21.0 |
| អ្នកលីសែង | 9939 | 10,785 | 12,143 | 13,247 | 12,141 | 12,568 | 13,399 | 16,188 | 16,997 | -5.4 | 22.2 | 40.4 |
| អ្នកលក់បន្លែតូចតាច | 8250 | 8337 | 10,771 | 11,366 | 12,294 | 13,581 | 15,372 | 17,735 | 15,185 | 33.8 | 43.1 | 23.5 |
| អ្នករើសអេតចាយ | 6683 | 8388 | 8680 | 9819 | 9593 | 9214 | 8337 | 9548 | 10,752 | -13.3 | -1.4 | 12.1 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5596 | 5986 | 6111 | 6697 | 7449 | 6696 | 7565 | 9435 | 8566 | 11.4 | 40.0 | 15.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5679 | 5695 | 6151 | 6599 | 8932 | 5836 | 8795 | 6781 | 8401 | 13.2 | 6.6 | -5.9 |
| កម្មកររោងចក្រកាត់ដេរ | 7828 | 8409 | 8932 | 10,161 | 9548 | 11,412 | 11,388 | 12,092 | 14,816 | 11.4 | 16.3 | 52.2 |
| អ្នករត់ម៉ូតូឌុប | 10,603 | 11,568 | 12,930 | 13,450 | 13,227 | 13,401 | 12,656 | 14,259 | 14,720 | -7.3 | 8.6 | 11.3 |
| កម្មករសំណង់គ្មានជំនាញ | 8773 | 10,307 | 11,078 | 13,184 | 15,162 | 15,316 | 15,401 | 15,436 | 16,877 | 18.3 | 15.4 | 11.3 |
| កម្មករសំណង់មានជំនាញ | 11,929 | 13,159 | 13,743 | 15,442 | 15,163 | 15,765 | 20,420 | 18,302 | 17,251 | 29.1 | 10.4 | 13.8 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000.

Source: CDRI

**ជិតចេញផ្សាយ**

# ការអប់រំ នៅកម្ពុជាឆ្នាំ២០១៥ ការខារ និងការផ្ដល់សិទ្ធិអំណាច

**អ្នកកែសម្រួល**

**ឃៀង-សុធី ស្រ៊ីនីវាសា-ម៉ាឌូ នែម-រិទ្ធី**




ការកែលំអប្រព័ន្ធអប់រំ ជាបញ្ហាដ៏សំខាន់បំផុតមួយ ដែលកម្ពុជាកំពុងប្រឈមមុខ។ ការសិក្សានេះ ជាលទ្ធផល នៃការពិគ្រោះយោបល់ និងកិច្ចសហការជាមួយស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិថ្នាក់ជាតិ គ្រឹះស្ថានអប់រំ ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន ដែលបានផ្ដល់នូវកន្លែងរក្សាទុកជំនាញ ចំណេះដឹង និងបទពិសោធន៍ជាច្រើន។ ឯកសារនេះផ្ដោតលើប្រធានបទសំខាន់ៗជាច្រើន៖ ការដោះស្រាយបញ្ហាកង្វះជំនាញ, ការឈានទៅសម្រេចគោលដៅខ្ពស់តាមរយៈការអប់រំកម្រិតឧត្ដមសិក្សា ការរៀបចំ និងពង្រីកការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ការពង្រឹងការអប់រំកម្រិតមធ្យមសិក្សា ការដោះស្រាយតម្រូវការរៀនសូត្រជាមូលដ្ឋាន តាមរយៈការអប់រំកម្រិតបឋមសិក្សា និងការរៀនសូត្រមួយជីវិតតាមរយៈសាលាមត្តេយ្យ និងការរីកលូតលាស់របស់កុមារតាំងពីក្មេងខ្ចី។

នៅពេលគិតគូរពីការអប់រំអ្នកជំនាន់ក្រោយ កម្ពុជាត្រូវផ្ដោតលើទាំងផ្នែកគុណភាព និងភាពពាក់ព័ន្ធល្អ ហើយត្រូវរក្សាជំហរបើកចំហដល់គំនិតបែបថ្មី។ ការធ្វើវិនិយោគទៅលើកំណែទម្រង់អប់រំជាលក្ខណៈប្រព័ន្ធ និងប្រកបដោយគុណភាព នឹងផ្ដល់នូវធាតុផ្សំមានស្ថិរភាពល្អ សម្រាប់ការសម្រេចគោលដៅរយៈពេលវែងរបស់យើង។ កម្ពុជាជាប្រជាជាតិមួយកំពុងវិវត្តទៅមុខ។ ការកសាង និងអនុវត្តគោលនយោបាយផ្អែកលើការស្រាវជ្រាវត្រឹមត្រូវ នឹងជួយយើងក្នុងការកំណត់ គន្លងដ៏រុងរឿងសម្រាប់អនាគតប្រទេសកម្ពុជា។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh។
ឯកសារបោះពុម្ពផ្សាយអាចរកជាវបាននៅវិទ្យាស្ថាន CDRI និងនៅហាងលក់សៀវភៅ ម៉ូនូម៉ែន។

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ**...

នៅឆ្នាំនេះមានចំណងជើងថា *ការអប់រំនៅកម្ពុជាឆ្នាំ២០១៥៖ ការងារ និងការផ្តល់សិទ្ធិអំណាច* បានយកមកផ្សព្វផ្សាយក្នុងឱកាសនៃសន្និសីទនេះ។ របាយការណ៍ស្នូលប្រចាំឆ្នាំ បទបង្ហាញ និងឯកសារនានាទាក់ទងនឹងសន្និសីទ និង អត្ថបទសង្ខេបចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៥ ដែលបង្ហាញគំនិតសំខាន់ៗបានពីសន្និសីទ អាចស្វែងរកបានតាមរយៈគេហទំព័រ CDRI៖ www.cdri.org.kh ។

នៅថ្ងៃទី៦ មីនា ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាល CDRI ដែលមានឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា ជាប្រធាននោះ ក្រុមប្រឹក្សាភិបាលបានស្វាគមន៍ទទួលសមាជិកថ្មីពីររូប គឺ អគ្គរដ្ឋទូត Takahashi Fumiaki ប្រធានសមាគមជប៉ុន-កម្ពុជា និងអតីតអគ្គរដ្ឋទូតជប៉ុនប្រចាំនៅកម្ពុជា និង បណ្ឌិត Il Houng Lee ប្រធានវិទ្យាស្ថានគោលនយោបាយសេដ្ឋកិច្ចនៃប្រទេសកូរ៉េ។ ក្រុមប្រឹក្សាភិបាលបានអបអរសាទរចំពោះលោកនាយកប្រតិបត្តិ ដែលបានចូលកាន់តំណែង និងបំពេញការងារប្រកបដោយជោគជ័យ និងចំពោះបុគ្គលិកទាំងអស់ដែលបានប្រឹងប្រែង និងចំណាយពេលកែសម្រួលទៅតាមរបៀបដឹកនាំថ្មី។ លោកប្រធានផ្នែកស្រាវជ្រាវ បានអរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការលើកទឹកចិត្តក្នុងអំឡុងពេលលោកបំពេញការងារនៅ CDRI ។ សមាជិកក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងតំណាងបុគ្គលិក បានអរគុណដល់លោកប្រធានផ្នែកស្រាវជ្រាវ ចំពោះការរួមចំណែកដ៏សំខាន់របស់លោកនៅក្នុងវិទ្យាស្ថាន CDRI ។

នៅថ្ងៃទី៣១ មីនា ២០១៥ នាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពី វិធានការកំណែទម្រង់សម្រាប់ប្រព័ន្ធអប់រំនៅកម្ពុជា ដែលរៀបចំឡើងដោយរដ្ឋសភាកម្ពុជា។ សិក្ខាសាលានេះ មានអ្នកចូលរួមជាង ២០០នាក់ មានជាអាទិ សមាជិករដ្ឋសភា, ថ្នាក់ដឹកនាំឧត្តមសិក្សាមកពីក្រសួងជំនាញ វិស័យឯកជន និងវិស័យសាធារណៈ, និង តំណាងអង្គការមិនមែនរដ្ឋាភិបាល។ សិក្ខាសាលានេះមានវាគ្មិនគន្លឹះចំនួនបួនរូប គឺ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, តំណាងអង្គការ UNESCO ប្រចាំនៅកម្ពុជា, នាយកប្រតិបត្តិវិទ្យាស្ថាន CDRI, និង នាយកប្រតិបត្តិអង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល។ បន្ទាប់ពីបទបង្ហាញនីមួយៗ មានកិច្ចសន្ទនាយ៉ាងរស់រវើក និងប្រកបដោយផ្លែផ្ការវាងតំណាងស្ថាប័នដៃគូនានាក្នុងវិស័យអប់រំ។

## ផ្នែកស្រាវជ្រាវ

### កសិកម្ម

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សាចំនួន៨ ក្នុងនេះមាន ២គម្រោង ត្រូវអនុវត្តរួមគ្នាជាមួយក្រុមស្រាវជ្រាវផ្នែកសុខាភិបាល និងផ្នែកបរិស្ថាន។ គម្រោង *ការរចនារៀបចំក្របខ័ណ្ឌវាយតម្លៃ និងការត្រួតពិនិត្យលើអង្កេតគោល និងអង្កេតចុងបញ្ចប់ សម្រាប់ការជួយទ្រទ្រង់ដល់ជីវភាព និងទ្រព្យផលិតកម្ម (PALS)* ដែលទទួលមូលនិធិពី កម្មវិធីស្បៀងអាហារពិភពលោក បានចប់សព្វគ្រប់នៅដើមខែកុម្ភៈ។ គម្រោងចំនួន៣ ទទួលបានជំនួយហិរញ្ញវត្ថុពី ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (Sida)។ ទី១ របាយការណ៍សម្រាប់គម្រោងស្តីពី *ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យាទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ* កំពុងចងក្រងឡើងសម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ ទី២ លទ្ធផលគម្រោង *ការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មកសិកម្ម* សព្វថ្ងៃកំពុងកែសម្រួលយ៉ាងល្អិតល្អន់ និងបង្ហាញអំណះអំណាងដោយប្រើម៉ូដែលវិភាគ ដើម្បីបង្កើនគុណភាពលទ្ធផលជាក់ស្តែង។ សម្រាប់គម្រោងទី៣ ស្តីពី *ផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង* ខាងក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។

ករណីសិក្សាផ្តោតលើ "ការវិភាគពីខ្សែចង្វាក់តម្លៃបន្ថែម និងផលិតកម្មសត្វចិញ្ចឹម" ដែលស្ថិតក្នុងដំណាក់កាលទី២ នៃគម្រោង *គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធដាំដុះផ្អែកលើដំណាំស្រូវនៅតំបន់មេគង្គកណ្តាល* និងទទួលបានមូលនិធិពី មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវផ្អែកកសិកម្មអន្តរជាតិ (ACIAR) កំពុងមានដំណើរការល្អ។ ក្រុមស្រាវជ្រាវកំពុងរៀបចំត្រៀមចាប់អនុវត្តគម្រោងរយៈពេលបួនឆ្នាំ (២០១៥-២០១៨) មួយស្តីពី *ការសាកល្បងគំរូបែបថ្មី នៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុងគម្រោង PADEE កម្ពុជា (គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា)* ដែលទទួលបានមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវពី គោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI)។ គម្រោងថ្មីមួយទៀតដែលទើបចុះកិច្ចសន្យា គឺ *ការវិភាគពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃគោលនយោបាយនាំចេញអង្កររបស់វៀតណាម សម្រាប់កម្ពុជា*។ គម្រោងនេះមានការគាំទ្រពី កម្មវិធីគំនិតផ្តួចផ្តើមគោលនយោបាយសាធារណៈតំបន់មេគង្គក្រោម (LMPPI) ដែលទទួលបានមូលនិធិពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។

### សេដ្ឋកិច្ច

ដោយមានជំនួយទ្រទ្រង់ពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ក្រុមស្រាវជ្រាវផ្នែកសេដ្ឋកិច្ច បានរៀបចំកិច្ចប្រជុំតុមូលមួយស្តីពី "ការលើកកម្ពស់ស្ថានភាពការងារក្នុងវិស័យកាត់ដេរនៅតំបន់មេគង្គ" នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៥ មីនា កន្លងទៅ។ កិច្ចប្រជុំនេះ មានគោលដៅជំរុញការជជែកវែកញែកពី ផលប៉ះពាល់នៃស្តង់ដារពលកម្ម (ប្រាក់ឈ្នួលអប្បបរមា, សុវត្ថិភាព, សុខភាព, ស្ថានភាពការងារ) ដែលស្របតាមលក្ខខណ្ឌនៃខ្សែចង្វាក់ផ្គត់ផ្គង់ពិភពលោក សម្រាប់អាជីវកម្ម និងពលករ។ CDRI បានទទួលជំនួយហិរញ្ញវត្ថុពី IDRC សម្រាប់ការសម្របសម្រួល និងការអនុវត្តកម្មវិធីរយៈពេលបីឆ្នាំ នៃបណ្តាញមហាអនុតំបន់មេគង្គ (GMSNet) ស្តីពី *ការលើកកម្ពស់អនាគតការងារសម្រាប់យុវជន៖ ទីផ្សារពលកម្ម ការអភិវឌ្ឍជំនាញ និងវិស័យឯកជន នៅក្នុង*

*មហាអនុតំបន់មេគង្គ*។ កម្មវិធីនេះ នឹងចាប់ប្រកាសឲ្យធ្វើការស្រាវជ្រាវជាលក្ខណៈប្រកួតប្រជែងលើកដំបូងបំផុតមួយ សម្រាប់រហូតដល់ ១២អនុគម្រោង ដោយបែងចែកការស្រាវជ្រាវជាពីរផ្នែក គឺ គោលនយោបាយ និង សកម្មភាព។ អនុគម្រោងផ្នែកគោលនយោបាយ នឹងពិនិត្យពីនិន្នាការ និងកំណែទម្រង់ផ្នែកគោលនយោបាយ ដែលជះឥទ្ធិពលទៅលើអនាគតការងារសមរម្យសម្រាប់យុវជននៅក្នុងវិស័យអាជីវកម្មឯកជន។ អនុគម្រោងផ្នែកសកម្មភាព រួមមាន ការស្រាវជ្រាវ ឬវាយតម្លៃពីការប្រតិបត្តិតាមស្តង់ដារពលកម្មល្អ, កម្មវិធីធ្វើអាជីវកម្មតាមបែបថ្មី, និង របៀបធ្វើអាជីវកម្មជាក់ស្តែងតាមបែបថ្មី ។

សមាសភាគពីរចុងក្រោយ (គោលនយោបាយទីផ្សារពលកម្ម និងទីផ្សារឥណទាន) នៃគម្រោងរយៈពេល៥ឆ្នាំក្រោមជំនួយទ្រទ្រង់ពី Sida ស្តីពី *កំណើនសម្រាប់គ្រប់គ្នា* កំពុងជឿនលឿនទៅមុខ។ របាយការណ៍ព្រាងស្តីពី *ចម្លើយតបរបស់សហគមន៍ចំពោះអំពើហិង្សាលើស្ត្រី* បានបញ្ជូនទៅឲ្យដៃគូរបស់វិទ្យាស្ថាន CDRI រួចហើយ ដើម្បីឲ្យជួយផ្តល់មតិ។ សម្រាប់គម្រោង *ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក នឹងការអភិវឌ្ឍ៖ ករណីសិក្សា និងអនុសាសន៍គោលនយោបាយ* ដែលទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) កំពុងស្ថិតក្នុងដំណាក់កាលចងក្រងរបាយការណ៍។ ការស្រាវជ្រាវរួមគ្នាមួយជាមួយសាកលវិទ្យាល័យ Manchester ស្តីពី *ដំណោះស្រាយនយោបាយ និងការអប់រំកម្រិតបឋមសិក្សានៅកម្ពុជា* កំពុងជឿនលឿនទៅមុខ ហើយការធ្វើសម្ភាសន៍អ្នកពាក់ព័ន្ធ និងការសិក្សាលើឯកសារមានស្រាប់ ក៏កំពុងអនុវត្តដែរ។

ការបោះពុម្ពផ្សាយជាទៀងទាត់ ដែលរួមមាន *របាយការណ៍ថ្មីៗប្រចាំខែស្តីពីសេដ្ឋកិច្ចកម្ពុជា*, "ការតាមដានសេដ្ឋកិច្ច" និង "អង្កេតពលករងាយរងគ្រោះ" នៅក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ចេញផ្សាយប្រចាំត្រីមាស, និង *អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត*, បន្តបង្ហាញរូបភាពសេដ្ឋកិច្ចមួយ ដែលមានតាំងពីកម្រិតប្រាក់ឈ្នួលតាមតំបន់ និងថ្លៃទំនិញនៅលើទីផ្សារក្នុងស្រុក រហូតដល់ថ្លៃទំនិញនៅលើទីផ្សារពិភពលោក។

## បរិស្ថាន

ការវាយតម្លៃផ្នែកធារាសាស្ត្រ អភិបាលកិច្ចទឹក ការកសាងសមត្ថភាព និង ការផ្សព្វផ្សាយចំណេះដឹង ដូចបានគ្រោងឡើងនៅក្នុងគម្រោង *ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា* ដែលទទួលមូលនិធិពី IDRC កំពុងអនុវត្តទៅមុខ។ ក្រុមស្រាវជ្រាវ កំពុងវិភាគលើទិន្នន័យបឋមដើម្បីវាយតម្លៃពីផលប៉ះពាល់នៃសកម្មភាពមនុស្ស ទៅលើបរិមាណទឹកនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ។ គម្រោងមួយដើម្បីបង្កើត *ផែនការគ្រប់គ្រងគ្រោះមហន្តរាយ ផ្អែកលើសហគមន៍នៅជនបទកម្ពុជា* ដែលទទួលបានមូលនិធិពី វិទ្យាស្ថានជប៉ុនផ្នែកការស្រោចស្រព និងរំដោះទឹក (JIID) បានចប់សព្វគ្រប់នៅខែមីនា។ ក្រុមស្រាវជ្រាវគម្រោង *ការសិក្សាបន្តពី ការសិក្សាទូទាំងប្រទេសឆ្នាំ២០១១ លើទម្លាប់ ឥរិយាបថ និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា* កំពុងរៀបចំរបាយការណ៍ពេញលេញមួយ ដើម្បីផ្ញើជូន សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) នៃក្រសួងបរិស្ថាន ឲ្យជួយផ្តល់មតិនៅដើមខែមេសា។

ឯកសារពិភាក្សាស្តីពី *ការអនុវត្តបច្ចេកវិទ្យាកសិកម្ម និងចន្លោះខ្វះខាត ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI)* ដែលទទួលមូលនិធិពី Sida បានចេញផ្សាយហើយ។ ការវិភាគទិន្នន័យសម្រាប់គម្រោង *ប្រទេសចិនឈានឡើងកម្រិតសកល* ដែលទទួលបានមូលនិធិពីក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម បានចប់សព្វគ្រប់។ លទ្ធផលស្រាវជ្រាវមានចុះផ្សាយនៅក្នុង*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ហើយនឹងមានចុះផ្សាយនៅក្នុង *គោលនយោបាយថាមពល* ដែលជាសារព័ត៌មានអន្តរជាតិមួយ មានអ្នកស្រាវជ្រាវក្នុងវិស័យដូចគ្នាជួយពិនិត្យផ្តល់មតិ នៅក្នុងឆ្នាំ២០១៥។

សំណើគម្រោងមួយបានដាក់ជូនទៅ LMPPI ដើម្បីធ្វើការស្រាវជ្រាវស្តីពី ចីរភាពនៃការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅទន្លេមេគង្គ និងដៃទន្លេមេគង្គនៅកម្ពុជា។ សំណើគម្រោងដទៃទៀតដែលបានបញ្ជូនទៅឲ្យដៃគូផ្សេងៗ កំពុងរង់ចាំការពិនិត្យសម្រេច ហើយសំណើថ្មីពីរកំពុងរៀបចំឡើង។ សំណើទី១ ទាក់ទងនឹងការសិក្សាសាកល្បងស្តីពី "អភិបាលកិច្ចទឹកក្រោមការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ហើយសំណើមួយទៀតជាការវាយតម្លៃលើគម្រោងចប់រួចរាល់មួយ ស្តីពី "ការជំរុញជីវភាពដែលធន់ល្អទៅនឹងអាកាសធាតុ សម្រាប់កសិករខ្នាតតូចនៅតំបន់ដីស្ងួតងាយរងគ្រោះជាងគេក្នុងខេត្តសៀមរាប និងកំពង់ចាម"។

## អភិបាលកិច្ច

ក្រុមស្រាវជ្រាវបានចាប់អនុវត្តការសិក្សាថ្មីពីរ។ ទី១ គម្រោងការផ្តល់សេវាសាធារណៈនៅកម្ពុជា ពិនិត្យពីយុទ្ធសាស្ត្រ វិធីសាស្ត្រ និងបច្ចេកទេសរដ្ឋបាល ដែលមានចែងនៅក្នុងបទបញ្ញត្តិផ្សេងៗ ដោយផ្តោតទៅលើការផ្តល់គ្រឿងលើកទឹកចិត្ត និងលក្ខណៈវិជ្ជាជីវៈ ដើម្បីជួយលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ប្លង់សិក្សាលំអិត កំពុងរៀបចំឡើង ដោយផ្អែកលើការសិក្សាលើឯកសារពាក់ព័ន្ធមានស្រាប់ និងការពិគ្រោះយោបល់ជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៃទីភ្នាក់ងារទាំងនោះ។ ការសិក្សាទី២ ស្តីពី លទ្ធភាពសម្រាប់ធ្វើកិច្ចសន្ទនាអំពីអភិបាលកិច្ចទឹកទន្លេមេគង្គ ដែលជាសមាសភាគមួយនៃ កម្មវិធីស្រាវជ្រាវស្តីពី ទឹក ដី និងប្រព័ន្ធអេកូឡូស៊ី ទទួលបានមូលនិធិពី ក្រុមពិគ្រោះយោបល់សម្រាប់ការស្រាវជ្រាវផ្នែកកសិកម្មអន្តរជាតិ (CGIAR)។ ការសិក្សានេះកំពុងដំណើរការទៅមុខ ដោយមានគ្រោងធ្វើសិក្ខាសាលាបំផុសគោលគំនិតមួយ នៅខែមេសា។

ការសិក្សាចំនួន៤ បានចប់សព្វគ្រប់។ លទ្ធផលស្រាវជ្រាវនៃការសិក្សាពីរក្នុងនោះ បានយកមកចងក្រងនិងបោះពុម្ពផ្សាយរួចហើយ ដោយមានមួយក្លាយជាជំពូកមួយមានចំណងជើងថា "ការដោះស្រាយតម្រូវការរៀនសូត្រជាមូលដ្ឋាន តាមរយៈការអប់រំកម្រិតបឋមសិក្សា" នៅក្នុងរបាយការណ៍ *ការអប់រំនៅកម្ពុជា*

*ឆ្នាំ២០១៥៖ ការងារ និងការផ្តល់សិទ្ធិអំណាច* ហើយមួយទៀតក្លាយជាឯកសារពិភាក្សាស្តីពី *ការអនុវត្តជាក់ស្តែងនូវវិធីសាស្ត្រផ្អែកលើសិទ្ធិអំណាច៖ កត្តាកំណត់ និងការប្រមើលឃើញសម្រាប់កម្ពុជា*។ ឯកសារព្រាងស្តីពី *គណនេយ្យភាពសង្គមនៅកម្ពុជា ការសម្រេចចិត្ត និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងធនធានទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា* កំពុងកែសម្រួលបន្ថែម ដោយផ្អែកលើមតិយោបល់របស់អ្នកមានជំនាញដូចគ្នាដែលបានជួយពិនិត្យ។

ការបណ្តុះបណ្តាលផ្ទៃក្នុង CDRI ស្តីពី ការវិភាគផ្នែកសេដ្ឋកិច្ចនយោបាយ ធ្វើឡើងដោយសាស្ត្រាចារ្យ Caroline Hughes ទីប្រឹក្សាផ្នែកស្រាវជ្រាវនៃក្រុមស្រាវជ្រាវផ្នែកអភិបាលកិច្ច និងជាសាស្ត្រាចារ្យផ្នែកការសិក្សាពីសន្តិភាព នៅសាកលវិទ្យាល័យ Bradford នោះ មានអ្នកស្រាវជ្រាវមកពីផ្នែកស្រាវជ្រាវទាំងប្រាំរបស់ CDRI មកចូលរួម។ អ្នកស្រាវជ្រាវមួយរូបមកពីផ្នែកអភិបាលកិច្ច បានធ្វើបទបង្ហាញទាក់ទងនឹងឯកសារមួយស្តីពី "ការអប់រំកម្រិតបឋមសិក្សានៅកម្ពុជា" នៅក្នុងសន្និសីទនៃវេទិកាសិក្សាស្រាវជ្រាវនៅសតវត្សរ៍ទី២១ ក្រោមប្រធានបទ "ការបង្រៀន ការរៀនសូត្រ និងការស្រាវជ្រាវនៅសតវត្សរ៍ទី២១" នៅឯសាកលវិទ្យាល័យ Harvard កាលពីថ្ងៃទី ៨-១២ ខែមីនា កន្លងទៅ។

## សុខាភិបាល

គម្រោងស្រាវជ្រាវធំ៣ កំពុងជឿនលឿនទៅមុខ។ គម្រោង *ការស្រាវជ្រាវ ដើម្បីកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD)* ទទួលបានមូលនិធិពី DFID ហើយចែកជា៣អនុគម្រោង គឺ៖ ហិរញ្ញប្បទានសុខភាព, ធនធានមនុស្សផ្នែកសុខាភិបាល និង ការរៀបចំកិច្ចសន្យាផ្នែកសុខាភិបាល។ របាយការណ៍ព្រាងនៃអនុគម្រោងទាំងបី បានចងក្រងចប់សព្វគ្រប់។ ការស្រាវជ្រាវស្តីពី *ការផ្តល់សេវាសម្ភពក្នុងប្រព័ន្ធសុខាភិបាលនៅកម្ពុជា* ដែលជាគម្រោងរួមគ្នាជាមួយ មជ្ឈមណ្ឌលនូហ្វៀលសម្រាប់ការអភិវឌ្ឍ និងសុខភាពអន្តរជាតិ (Nuffield Centre for International Health and Development) និងសកលវិទ្យាល័យ Leeds នោះ បានទទួលជំនួយទ្រទ្រង់ពីមូលនិធិ ReBUILD Responsive Fund។ ការសំអាតទិន្នន័យ ការចម្លងបទសម្ភាសន៍ជាលាយលក្ខណ៍អក្សរ និងការដាក់លេខកូដ និងវិភាគទិន្នន័យ កំពុងដំណើរការទៅមុខ។ ការសិក្សាពីរទៀតនៅក្រោមគម្រោង *ការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារតាមការលើកកម្ពស់ការអប់រំ និងជីវភាពរស់នៅ (EXCEL)* ពោលគឺ ការសិក្សាផ្តោតលើ កុមារបម្រើការងារតាមផ្ទះ និង ភាពគ្មានដីធ្លីនិងពលកម្មកុមារ បានចេញផ្សាយនៅលើគេហទំព័ររបស់ CDRI។ ការសិក្សាលើឯកសារពាក់ព័ន្ធ និងការរៀបចំឧបករណ៍ស្រាវជ្រាវ សម្រាប់អនុគម្រោងទី៤ ស្តីពី ការស្រាវជ្រាវពីពលកម្មកុមារ ដែលជាឯកសារសំយោគនៃការសិក្សាទាំងបីនៅក្រោមគម្រោង EXCEL នេះ កំពុងដំណើរការទៅមុខ។

ក្រុមស្រាវជ្រាវ ទទួលបានការអនុម័តយល់ព្រមលើសំណើស្រាវជ្រាវទាំងបី ដែលបានដាក់ស្នើឡើងកាលពីត្រីមាសមុន ហើយកំពុងអនុវត្តគម្រោងថ្មីទាំងនេះ ដែលរួមមាន *ការស្រាវជ្រាវពីអ្នកដឹកនាំ មតិមហាជនស្តីពី ការផ្តល់អាហារឲ្យទារកនិងកុមារតូចៗ (IYCF)*, *ការពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលផ្នែកអនាម័យ ដើម្បីវាយតម្លៃពីផលប៉ះពាល់ នៃការកែលំអអនាម័យនៅទីជនបទ* និង ការពិនិត្យពី*គន្លងអាជីពសម្រាប់បុគ្គលិកសុខាភិបាលនៅកម្ពុជា*។

## Cambodia Development Review—2015 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

បណ្ឌិត Srinivasa Madhur បានលាលែងពីតំណែងជាប្រធានផ្នែកស្រាវជ្រាវ នៅចុងខែមីនា២០១៥។ លោកបាននាំមកឲ្យ CDRI នូវចំណេះដឹង និងបទពិសោធន៍ជ្រៅជ្រះលើបញ្ហាខាងគោលនយោបាយអភិវឌ្ឍន៍នៅតំបន់អាស៊ី ព្រមទាំងទឹកចិត្តចង់ដឹងចង់យល់កម្រិតខ្ពស់។ ការរួមចំណែកដ៏ធំធេងរបស់លោកមានជាអាទិ៍៖ ព័ត៌មានសំខាន់ៗ ផ្នែកលើការស្រាវជ្រាវសម្រាប់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីត្រៀមធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ការរៀបចំឯកសារគោលគំនិតបង្ហាញពីបែបបទថ្មីដ៏ក្លាហាន ដើម្បីពង្រីកភាពជាដៃគូផ្នែកស្រាវជ្រាវសម្រាប់ បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) ដែលសម្របសម្រួលដោយ CDRI ហើយនិង ការផ្ដួចផ្ដើមគំនិត និងការផលិតឯកសារបោះពុម្ពផ្សាយស្នូលមួយស៊េរីថ្មីរបស់ CDRI ដែលមានជាអាទិ៍ឯកសារស្ដីពី *សន្ទុះអភិវឌ្ឍន៍របស់កម្ពុជា៖ លទ្ធផលសម្រេចបាន និងអាទិភាពកំពុងផុសឡើង*។

នៅថ្ងៃទី១៦ មករា ២០១៥ CDRI បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ ជាមួយ វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) នៅក្នុងពិធីជាផ្លូវការមួយនៅឯ NIPH។ អនុស្សារណៈនេះ នឹងជួយប្រមូលផ្ដុំសមត្ថភាពជំនាញវិជ្ជាជីវៈ និងធនធាន, កសាងសមត្ថភាពស្រាវជ្រាវពីសុខភាពសាធារណៈ, និងសម្រួលកិច្ចសហការស្រាវជ្រាវ ដែលនឹងជួយផ្ដល់ព័ត៌មានដល់ការកសាង និងអនុវត្តគោលនយោបាយសុខាភិបាលនៅកម្ពុជា។

ពីថ្ងៃទី២៦ មករា ដល់ ៣ កុម្ភៈ ២០១៥៖ លោកនាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានទៅប្រទេសចិន ដើម្បីជួបជាមួយសាស្ត្រាចារ្យ Chen Dongxiao ជាប្រធានមជ្ឈមណ្ឌលសម្រាប់ការសិក្សាពីតំបន់អាស៊ីប៉ាស៊ីហ្វិក នៃវិទ្យាស្ថានសៀងហៃសម្រាប់ការសិក្សាអន្តរជាតិ, សាស្ត្រាចារ្យ Zhang Yuyan ប្រធានវិទ្យាស្ថានសេដ្ឋកិច្ចនិងនយោបាយពិភពលោក នៃបណ្ឌិតសភាចិនផ្នែកវិទ្យាសាស្ត្រសង្គម និង សាស្ត្រាចារ្យ Li Wen នាយករងវិទ្យាស្ថានជាតិនៃការសិក្សាអន្តរជាតិ នៃបណ្ឌិតសភាចិនផ្នែកវិទ្យាសាស្ត្រសង្គម។ ទស្សនកិច្ចនេះមានគោលដៅ ពង្រឹងពង្រីកការចូលរួមការងាររបស់ CDRI ជាមួយស្ថាប័នស្រាវជ្រាវ និងបណ្ឌិតសភាចិន តាមរយៈកិច្ចសន្ទនាផ្នែកគោលនយោបាយ។ សំណើនាពេលថ្មីៗរបស់ CDRI ស្ដីពីការបង្កើតវេទិកាមួយសម្រាប់កិច្ចសន្ទនាចិន-កម្ពុជា ដោយរួមសហការជាមួយបណ្ដាស្ថាប័នចិនជាដៃគូរបស់កម្ពុជា គឺបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅ ជាពិសេសទាក់ទងនឹងគំនិតផ្ដួចផ្ដើមថ្មីៗ ដូចជា ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB), មូលនិធិផ្លូវសូត្រ និង ធនាគារ BRICS។

នៅថ្ងៃទី៥ មីនា ២០១៥ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៥ ក្រោមប្រធានបទ *សហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ និងតទៅអនាគត៖ របៀបវារៈកំណែទម្រង់* ដែលជាកិច្ចសហការជាដៃគូរវាង CDRI និង ធនាគារ ANZ Royal បានប្រារព្ធឡើងនៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួម៤៦០នាក់។ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ដល់កិត្តិយសដ៏ខ្ពង់ខ្ពស់ជាថ្មីម្ដងទៀត ដោយអញ្ជើញចូលរួមថ្លែងសុន្ទរកថាគន្លឹះផ្ដល់មតិមួយចំនួនដល់អង្គសន្និសីទ។ កម្មវិធីសន្និសីទផ្ដោតលើអនុប្រធានបទបី៖ (១) សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ - បានត្រៀមរួចរាល់ ឬមិនទាន់រួចរាល់ (២)ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា - អាទិភាពគោលនយោបាយ និងសកម្មភាព និង (៣) ការបង្ហាញរូបភាពថ្មីនៃប្រទេសកម្ពុជា៖ ការកំណត់គោលដៅយុទ្ធសាស្ត្រ សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងតទៅអនាគត។ របាយការណ៍ស្នូលប្រចាំឆ្នាំរបស់ CDRI ដែល

*តទៅទំព័រ ២៥*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៩ លេខ១ ខែមីនា ឆ្នាំ២០១៥

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
☒ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 📠 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា ខេង សេង និង ម៉េន ច័ន្ទធីតា

សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៥ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh